ប្រើប្រាស់ជាផ្លូវការតែប៉ុណ្ណោះ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# ជំរឿនទូទៅនូវប្រជារាស្ត្រ នៃប្រទេសកម្ពុជា ខែ មិនា ឆ្នាំ 1998

## អត្ថបទណែនាំអ្នកចុះសំភាសន៍

ក្រសួងផែនការ
វិទ្យាស្ថានជាតិស្ថិតិ
ភ្នំពេញ កម្ពុជា គ.ស. 1997

# មាតិការរឿង


ទំព័រ

| | | |
|---|---|---|
| ជំពូក I : | **សេចក្ដីផ្ដើម** | 1 |
| | ជំរឿនទូទៅនូវប្រជាកស្ដ្រ | 1 |
| | គោលដៅនៃជំរឿនឆ្នាំ 1998 | 2 |
| | - គោលដៅទូទៅ | 2 |
| | - គោលដៅជាក់លាក់ | 2 |
| | ការប្រើប្រាស់ទិន្នន័យជំរឿន | 2 |
| | កាលបរិច្ឆេទធ្វើជំរឿន និង ពេលវេលាកំណត់ | 3 |
| | សិទ្ធិអំណាចសំរាប់ធ្វើជំរឿន ខែ មិនា ឆ្នាំ 1998 | 3 |
| | ការរៀបចំចាត់ចែងមូលដ្ឋាននៃជំរឿន | 4 |
| | ជំរឿនទូទៅនូវប្រជារាស្ដ្រនៃកម្ពុជា ឆ្នាំ 1998 ក្រោបិករចនាសម្ព័ន្ធ | 5 |
| | ប្រការសំខាន់ៗនៃព្រះរាជក្រិត្យ ស្ដីពីជំរឿន | 6 |
| | កម្រងឯកសារសំរាប់ធ្វើជំរឿន ឆ្នាំ 1998 | 7 |
| ជំពូក II : | - **ការបំពេញតារាង ក : តារាងបញ្ជីផ្ទះ** | 9 |
| | - តារាងបញ្ជីផ្ទះ | 9 |
| | - ការរៀបចំផែនទីមណ្ឌលជំរឿនឱ្យទាន់សម័យកាល | 10 |
| | - ការដាក់លេខរៀងអគារ | 11 |
| | - អគារ | 11 |
| | - គ្រួសារ | 13 |
| | - ការដាក់លេខអគារនៅលើផែនទីមណ្ឌលជំរឿន | 14 |
| | - ការចុះបញ្ជីផ្ទះ | 14 |
| | បង្គោល 1 : លេខរៀងបន្ទាត់ | 15 |
| | បង្គោល 2 : អគារ / សំណង់លេខ | 16 |
| | បង្គោល 3-5 : សំភារៈសំខាន់សំរាប់សាងសង់អគារ / សំណង់ | 16 |
| | បង្គោល 3 : សំភារៈធ្វើជញ្ជាំង | 16 |
| | បង្គោល 4 : សំភារៈធ្វើដំបូល | 17 |
| | បង្គោល 5 : សំភារៈធ្វើកំរាល | 17 |

បង្គោល 6 : គោលដៅក្នុងការប្រើប្រាស់អគារ / សំណង់ 17

ចំណុចសំខាន់ 18

បង្គោល 7 : គ្រួសារលេខ 18

បង្គោល 8 និង 9 : ពត៌មានអំពីលក្ខណៈនៃមេគ្រួសារ 19

និយមន័យនៃមេគ្រួសារ 19

បង្គោល 8 : នាមត្រកូលនិងនាមខ្លួន 20

បង្គោល 9 : ភេទ ( 1: ប្រុស 2: ស្រី ) 20

បង្គោល 10 ដល់ 12 : ចំនួនមនុស្សពិតប្រាកដដែលរស់នៅជាប្រចាំក្នុងគ្រួសារ 20

បង្គោល 13 : សេចក្តីផ្សេងៗ 21

ពត៌មានទូទៅ 21

**ជំពូក III : ការបំពេញតារាង ខ តារាងសំណួរតាមគ្រួសារ** 23

ការណែនាំទូទៅ 23

ពេលវេលាកំណត់គឺអធ្រាត្រ ( 00 ម៉ោង ) ថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998 23

កំណត់សំគាល់សំខាន់ៗ 24

លក្ខណៈសំគាល់គំរូតារាងសំណួរតាមគ្រួសារ 25

**សេចក្តីណែនាំសំរាប់បំពេញតារាង ខ : តារាងសំណួរតាមគ្រួសារផ្នែក 1 : ពត៌មានសំគាល់ និងពត៌មានប្រជាសាស្ត្រ** 26

ពត៌មានសំគាល់ 26

ប្រភេទគ្រួសារ 26

តើត្រូវធ្វើយ៉ាងដូចម្តេច នៅពេលត្រូវប្រើតារាងសំណួរតាមគ្រួសារពី 2 ឬច្រើនឡើងទៅសំរាប់គ្រួសារមួយ ? 26

នាមត្រកូលនិងនាមខ្លួននៃមេគ្រួសារ 27

ការបំពេញតារាងសំណួរ 1.1 , 1.2 និង 1.3 27

កំណត់សំគាល់សំខាន់ៗ 27

តារាងសំណួរ 1.1 សមាជិកពិតប្រាកដដែលវត្តមាននៅយប់ថ្ងៃធ្វើជំរឿន 28

បង្គោល 1 : លេខរៀង 29

បង្គោល 2 : នាមត្រកូល និងនាមខ្លួន 29

ទារកដែលមិនទាន់បានដាក់ឈ្មោះ 29

មនុស្សដែលឈ្មោះស្រដៀងគ្នា 29
បង្គោល 3 : ទំនាក់ទំនងជាមួយមេគ្រួសារ 29
បង្គោល 4 : ភេទ 30
តារាងសំណួរ 1.2 ភ្ញៀវវត្តមាននៅយប់ថ្ងៃធ្វើជំរឿន 30
តារាងសំណួរ 1.3 សមាជិកពិតប្រាកដអវត្តមាននៅយប់ធ្វើជំរឿន 31
ចំនួនមនុស្សសរុបក្នុងតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 32
ចំនួនមនុស្សសរុបក្នុងតារាងសំណួរ 1.1 បូកនឹង 1.2 32
**សេចក្តីណែនាំសំរាប់បំពេញតារាង ខ តារាងសំណួរតាមគ្រួសារ ផ្នែក 2 ពត៌មានផ្ទាល់ខ្លួន** 33
លាតត្រដាងពីតារាង ខ តារាងសំនួរតាមគ្រួសារ ផ្នែក 2 33
សេចក្តីណែនាំពីការបំពេញបង្គោល 1 ដល់ 20 នៃតារាង ខ ផ្នែក 2 33
បង្គោល 1 : លេខរៀង 33
បង្គោល 2 ដល់ 4 34
បង្គោល 2 : នាមត្រកូល និងនាមខ្លួន 34
បង្គោល 3 : ញាតិសន្តាន 34
បង្គោល 4 : ភេទ 34
បង្គោល 5 : អាយុ 34
តើត្រូវធ្វើយ៉ាងដូចម្តេចនៅពេលដែលមនុស្សម្នាក់មិនដឹងអាយុរបស់ខ្លួន 35
បង្គោល 6 : ស្ថានភាពអាពាហ៍ពិពាហ៍ 36
បង្គោល 7 : ភាសាកំណើត 36
បង្គោល 8 : សាសនា 37
បង្គោល 9 : ទីកន្លែងកើត 38
បង្គោល 10 : លំនៅឋានពីមុន 38
បង្គោល 11 : រយៈពេលស្នាក់នៅ 39
បង្គោល 12 : មូលហេតុនៃអន្តោប្រវេសន៍ 40
បង្គោល 13 : អក្ខរភាព 40
បង្គោល 14 : រយៈពេលសិក្សាពេញលេញ 41

ឯកសារដែលត្រូវប្រគល់ដល់អ្នកត្រួតពិនិត្យ 66

**ឧបសម្ព័ន្ធ**


1 ឧបសម្ព័ន្ធ ក. តារាងក : តារាងបញ្ជីផ្ទះ 69

2 ឧបសម្ព័ន្ធ ខ : ផែនទីមណ្ឌលជំរឿនមិនទាន់កែលំអ

ខ (I) តំបន់ជនបទ 70

ខ (II) ទីប្រជុំជន 72

3 ឧបសម្ព័ន្ធ គ. ផែនទីមណ្ឌលជំរឿនបន្ទាប់ពីការកែលំអ

គ (I) តំបន់ជនបទ 74

គ (II) ទីប្រជុំជន 76

4 ឧបសម្ព័ន្ធ ឃ. តារាងសរុបសង្ខេបបញ្ជីផ្ទះ 78

5 ឧបសម្ព័ន្ធ ង. បែបបទកែតំរូវតារាង ក ក្នុងអំឡុងពេលធ្វើជំរឿននៅពេលអ្នកជួបប្រទះនឹងគ្រួសារថ្មីមួយចំនួនដែលមិនទាន់បានកត់ចូលក្នុងតារាង ក 79

6 ឧបសម្ព័ន្ធ ច. តារាងខ តារាងសំណួរតាមគ្រួសារ 81

7 ឧបសម្ព័ន្ធ ឆ. តារាងសរុបសង្ខេបរបស់អ្នកចុះសំភាសន៍ 85

8 ឧបសម្ព័ន្ធ ជ. លិខិតសុំជួបសំភាសន៍ 86

9 ឧបសម្ព័ន្ធ ឈ. បញ្ជីទទួលនិងការប្រើប្រាស់តារាងដោយមន្ត្រីចុះសំភាសន៍ ( តារាង 3 ) 87

10 ឧបសម្ព័ន្ធ ញ. លិខិតបញ្ជាក់ពីប្រធានភូមិ 88

11 ឧបសម្ព័ន្ធ ដ. ឧទាហរណ៍ ក្នុងតារាងសំណួរ ក តារាងសំណួរ ខ តារាង 1; 2 និង 3 89

| | | |
|---|---|---|
| | បង្គោល 4 (ង) និង (ច) តើក្នុងចំណោមកូនទាំងនោះមានកូនប៉ុន្មាននាក់ស្លាប់ ?(កត់ចូលក្នុងបង្គោល ( ង ) ចំនួនកូនប្រុស និងក្នុងបង្គោល ( ច )ចំនួនកូនស្រី ដាច់ដោយ ឡែកពីគ្នា) | 53 |
| | បង្គោល 5 : ពត៌មានអំពីកំណើតក្នុង 12 ខែកន្លងមក | 54 |
| | **ការបំពេញតារាង ( ខ ) : តារាងសំណួរតាមគ្រួសារផ្នែក 4 : ស្ថានភាពលំនៅដ្ឋាន និងប្រដាប់ប្រើប្រាស់ក្នុងផ្ទះ** | 55 |
| | បង្គោល 1 : តើលោក-អ្នកកាន់កាប់លំនៅដ្ឋានតាមមូលដ្ឋានណាមួយ ? | 55 |
| | បង្គោល 2 : ប្រភពបំភ្លឺសំខាន់ៗ | 56 |
| | បង្គោល 3 : ប្រភពថាមពលប្រើប្រាស់សំរាប់ចំអិនម្ហូបអាហារ | 56 |
| | បង្គោល 4 : ការប្រើប្រាស់បង្គន់នៅក្នុងបរិវេណផ្ទះ | 57 |
| | បង្គោល 5 : ប្រភពផ្គត់ផ្គង់ទឹកស្អាតសំរាប់ផឹក | 57 |
| | បង្គោល 6 : ចំនួនបន្ទប់ដែលគ្រប់គ្រងដោយគ្រួសារ | 58 |
| **ជំពូក** IV : | **ការជំរឿនសមាជិកនៃគ្រួសារស្ថាប័ន** | 59 |
| | តារាង ក តារាងបញ្ជីផ្ទះ | 59 |
| | តារាង ខ តារាងសំណួរតាមគ្រួសារ | 60 |
| | គ្រួសារស្ថាប័នមានទំហំធំ | 61 |
| **ជំពូក** V: | **ការធ្វើជំរឿនគ្រួសារគ្មានផ្ទះសំបែង ប្រជារាស្ត្រនៅតាម ទូក កាណូត កប៉ាល់ ផ្ទះទឹក និងប្រជារាស្ត្រឆ្លងកាត់** | 62 |
| | គ្រួសារគ្មានផ្ទះសំបែង | 62 |
| | តារាងខ តារាងសំណួរតាមគ្រួសារ | 62 |
| | ប្រជារាស្ត្រនៅតាមទូក កាណូត កប៉ាល់ និងផ្ទះទឹក | 63 |
| | ប្រជារាស្ត្រឆ្លងកាត់ | 64 |
| **ជំពូក** VI : | **ការរៀបចំតារាងសង្ខេបរបស់អ្នកចុះសំភាសន៍** | 65 |
| | បង្គោល 2 និង 3 : អគារលេខ និងគ្រួសារលេខ | 65 |
| | បង្គោល 4 : ចំនួនតារាងសំណួរតាមគ្រួសារបានប្រើប្រាស់ | 65 |
| | បង្គោល 5-7 : ចំនួនប្រជារាស្ត្របានពីជំរឿន | 66 |
| | បង្គោល 8 : ប្រភេទគ្រួសារ / ប្រជារាស្ត្រ | 66 |
| | បង្គោល 9 : សេចក្តីផ្សេងៗ | 66 |

ឯកសារដែលត្រូវប្រគល់ដល់អ្នកត្រួតពិនិត្យ 66

**ឧបសម្ព័ន្ធ**

1 ឧបសម្ព័ន្ធ ក. តារាងក : តារាងបញ្ជីផ្ទះ 69
2 ឧបសម្ព័ន្ធ ខ : ផែនទីមណ្ឌលជំរឿនមិនទាន់កែលំអ
ខ (I) តំបន់ជនបទ 70
ខ (II) ទីប្រជុំជន 72
3 ឧបសម្ព័ន្ធ គ. ផែនទីមណ្ឌលជំរឿនបន្ទាប់ពីការកែលំអ
គ (I) តំបន់ជនបទ 74
គ (II) ទីប្រជុំជន 76
4 ឧបសម្ព័ន្ធ ឃ. តារាងសរុបសង្ខេបបញ្ជីផ្ទះ 78
5 ឧបសម្ព័ន្ធ ង. បែបបទកែតំរូវតារាង ក ក្នុងអំឡុងពេលធ្វើជំរឿននៅពេលអ្នកជួបប្រទះនឹងគ្រួសារថ្មីមួយចំនួនដែលមិនទាន់បានកត់ចូលក្នុងតារាង ក 79
6 ឧបសម្ព័ន្ធ ច. តារាងខ តារាងសំណួរតាមគ្រួសារ 81
7 ឧបសម្ព័ន្ធ ឆ. តារាងសរុបសង្ខេបរបស់អ្នកចុះសំភាសន៍ 85
8 ឧបសម្ព័ន្ធ ជ. លិខិតសុំជួបសំភាសន៍ 86
9 ឧបសម្ព័ន្ធ ឈ. បញ្ជីទទួលនិងការប្រើប្រាស់តារាងដោយមន្ត្រីចុះសំភាសន៍ ( តារាង 3 ) 87
10 ឧបសម្ព័ន្ធ ញ. លិខិតបញ្ជាក់ពីប្រធានភូមិ 88
11 ឧបសម្ព័ន្ធ ដ. ឧទាហរណ៍ ក្នុងតារាងសំណួរ ក តារាងសំណួរ ខ តារាង 1; 2 និង 3 89

# ជំពូក I
# សេចក្តីផ្តើម

អ្នកសំភាសន៍ធ្វើជំរឿនជាអ្នកបំពេញភារកិច្ចជាតិមួយមានសារៈសំខាន់ដ៏ធំធេង ។ នៅពេលដែលគេចាត់តាំងប្រគល់សិទ្ធិឱ្យអ្នកសំភាសន៍ធ្វើជំរឿន ត្រូវទទួលខុសត្រូវបំពេញកិច្ចការឱ្យបានល្អ ។ អ្នកត្រូវបំពេញភារៈកិច្ចនេះប្រកបដោយសុភវិនិច្ឆ័យមានមោទនភាពនិងស្មោះស្ម័គ្រចំពោះភារកិច្ចនេះ ។ សូមអានសេចក្តីណែនាំនេះអោយបានហ្មត់ចត់ ដើម្បីជាជំនួយដល់ការបំពេញភារកិច្ចរបស់អ្នកបានល្អប្រសើរ ។

ជំពូកនេះផ្តល់ពីប្រវត្តិ និងគោលដៅនៃការធ្វើជំរឿនទូទៅទូវប្រជារាស្ត្រនៃប្រទេសកម្ពុជា ខែមិនា ឆ្នាំ 1998 ។ ជំពូកនេះក៏មានពន្យល់ផងដែរពីការប្រើប្រាស់ទិន្នន័យច្រើនបែបច្រើនយ៉ាងបានមកពីជំរឿន និងអំពីហេតុការណ៍ខ្លះៗស្តីពីការទទួលរាប់រងអនុវត្តធ្វើជំរឿន ។

## ជំរឿនទូទៅទូវប្រជារាស្ត្រ

I- ជំរឿនទូទៅទូវប្រជារាស្ត្រសំដៅលើវិធីសាស្ត្រទាំងមូល នៃការប្រមូល ការចងក្រង ការវាយតំលៃ ការវិភាគ និងការផ្សព្វផ្សាយទិន្នន័យអំពីប្រជារាស្ត្រនៃប្រទេសមួយ ។ ជំរឿននេះពាក់ព័ន្ធដល់ការចុះបញ្ជីមនុស្ស និងកត់ត្រាលក្ខណៈរបស់មនុស្សម្នាក់ៗក្នុងចំណោមមនុស្សទាំងអស់តាមកាលបរិច្ឆេទកំណត់មួយ ។ ហេតុនេះ នៅពេលដែលធ្វើការចងក្រង និងវិភាគពត៌មានបានស្រង់មកពីក្នុងជំរឿននោះ យើងអាចស្គាល់ទំហំ និងការបែងចែកប្រជារាស្ត្រព្រមទាំងលក្ខណៈប្រជាសាស្ត្រ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌នៃប្រជារាស្ត្រនោះ ។ ទាំងនេះសុទ្ធតែមានតំរូវការចាំបាច់បំផុតក្នុងការធ្វើផែនការ និងធ្វើកម្មវិធីដ៏សមរម្យសំរាប់អភិវឌ្ឍន៍ជាតិ និង តំបន់ ។

I.1 ពីខែកុម្ភៈ ដល់ ខែមិនា ឆ្នាំ 1998 ជំរឿនប្រជារាស្ត្រដែលមាន ឈ្មោះថា ជំរឿនទូទៅទូវប្រជារាស្ត្រនៃប្រទេសកម្ពុជា និងត្រូវបានដឹកនាំធ្វើនៅទូទាំងប្រទេស ។ ជំរឿនប្រជារាស្ត្រចុងក្រោយបង្អស់នៅប្រទេសកម្ពុជា បានធ្វើក្នុងខែមេសា ឆ្នាំ 1962 ។ ជំរឿនទូទៅទូវប្រជារាស្ត្រខែមិនា ឆ្នាំ 1998 ជាជំរឿនដែលធ្វើនៅកម្ពុជាក្រោយពីការអាក់ខានមិនបានធ្វើអស់រយៈពេលជិត 36ឆ្នាំ កន្លងមក ។ ជំរឿននេះនឹងធ្វើការប្រមូលយកពត៌មានមូលដ្ឋានអំពីប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់មនុស្សម្នាក់ៗព្រមទាំងពត៌មានខ្លះអំពីអគារដែលកាន់កាប់ដោយគ្រួសារ ស្ថានភាពលំនៅដ្ឋាន និងប្រដាប់ប្រើប្រាស់នៅតាមគ្រួសារ ។

## គោលដៅនៃជំរឿនឆ្នាំ 1998

### *គោលដៅទូទៅ*

2- ជំរឿនឆ្នាំ 1998 នឹងឈានទៅបង្កើតបញ្ជីសារពើភ័ណ្ឌប្រភពកម្លាំងពលកម្ម និងលក្ខណៈប្រជាសាស្ត្រ របស់ប្រទេសនៅពេលមួយជាកំណត់ ។ មានតែជំរឿនទេដែលអាចផ្តល់ទិន្នន័យ នៅតាមតំបន់តូចៗ ( ឧទាហរណ៍ ភូមិ )សំរាប់គោលបំណងធ្វើផែនការតាមតំបន់ ។

### គោលដៅជាក់លាក់

2.1 ជាពិសេស ជំរឿនឆ្នាំ 1998 មានគោលដៅដើម្បី :

1. ទទួលបានការរាប់ប្រជារាស្ត្រទាន់សម័យកាល តាមអាយុ និងភេទ
2. ផ្តល់ការបែងចែកប្រជារាស្ត្រ លក្ខណៈប្រជាសាស្ត្រ និងលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ច តាមលក្ខណៈភូមិសាស្ត្រ
3. ផ្តល់ជូននូវទម្រង់គ្រោងសំរាប់ធ្វើអង្កេត និងធ្វើកម្មវិធីស្ថិតិផ្សេងទៀត ។

## ការប្រើប្រាស់ទិន្នន័យជំរឿន

3. ទិន្នន័យជំរឿនមិនត្រឹមតែសំរាប់ការគ្រប់គ្រងក្នុងរដ្ឋបាលប៉ុណ្ណោះទេ តែសំរាប់ធ្វើផែនការសេដ្ឋកិច្ច និង អភិវឌ្ឍន៍ផងដែរ ។ គោលបំណងដ៏ខ្ពស់បំផុតនៃការធ្វើផែនការបែបនេះ គឺផ្តល់ដំណើរជីវិតដ៏ប្រសើរជាងគេសំរាប់មនុស្សគ្រប់រូបនៃប្រទេសកម្ពុជា ។ ទាំងនេះត្រូវរាប់បញ្ចូលការបន្ថយភាពក្រីក្រ ការបង្កើនឱកាសមានការងារធ្វើការ កែលំអកំរិតអប់រំប្រជារាស្ត្រ និងផ្តល់សុខភាពជូនមនុស្សគ្រប់រូបទៀតផង ។

3.1 ពិតមែនហើយ ក្នុងការធ្វើផែនការសំរាប់ការអប់រំនោះត្រូវស្គាល់ពីចំនួនកុមារដែលដល់អាយុចូលសាលារៀន ពីទំនាក់ទំនងក្នុងការសិក្សានៅគ្រប់កំរិត ។ យ៉ាងហោចណាស់រាជរដ្ឋាភិបាលក៏ត្រូវដឹងជាមុនថាមានកុមារប៉ុន្មាននាក់ដែលត្រូវចូលសាលារៀនមុននឹងរដ្ឋាភិបាលចាំបាច់ត្រូវសង់សាលារៀននៅកន្លែងណា និង ត្រូវបណ្តុះបណ្តាលគ្រូបង្រៀនប៉ុន្មាននាក់ ។

3.2 រាជរដ្ឋាភិបាលមានបំណងកែលំអ និងពង្រីកសេវាកម្មសុខាភិបាលក្នុងប្រទេស ដើម្បីបំបាត់ជំងឺ និងបន្ថយចំនួនកុមារស្លាប់នៅក្នុងវ័យទារក និងនៅបឋមវ័យរបស់កុមារ ។ តែបើចង់ធ្វើផែនការសេវាកម្មសុខាភិបាលត្រឹមត្រូវនោះ រាជរដ្ឋាភិបាលត្រូវស្គាល់ចំនួនមនុស្សដែលពាក់ព័ន្ធចំនួនកុមារកើតមក និងអត្រាស្លាប់នៃកុមារទាំងនោះ ។

3.3 ដើម្បីផ្តល់សេវាកម្មទាំងនេះ នោះមិនគ្រាន់តែត្រូវដឹងថា តើមានមនុស្សប៉ុន្មាននាក់នៅពេលធ្វើជំរឿននោះទេ ពីព្រោះប្រភេទតួលេខនេះងាយប្រែប្រួលយ៉ាងឆាប់រហ័ស ។ មានន័យថាយើងត្រូវស្គាល់

ផងដែរ ថាតើប្រជារាស្ត្រកំពុងកើនឡើងក្នុងល្បឿនបែបណា ដើម្បីឱ្យរាជរដ្ឋាភិបាលដឹងថានៅពេលខាងមុខអាចមានចំនួនមនុស្សប៉ុន្មាននាក់ នៅក្នុងឆ្នាំក៏ដូចជានៅឆ្នាំមុខ នៅ 5 ឆ្នាំ នៅ 10 ឆ្នាំ ខាងមុខទៀត ។ល។ ហេតុនេះយើងមិនត្រឹមតែស្រង់យកពត៌មានតែពីមនុស្សរស់នៅពេលបច្ចុប្បន្នប៉ុណ្ណោះទេ តែយើងក៏ត្រូវស្រង់ផងដែរ នូវចំនួនកុមារកើតមកនិងចំនួនកុមារស្លាប់ទៅវិញ ។

3.4 ដើម្បីធ្វើផែនការផ្តល់លំនៅដ្ឋានឱ្យបានសមរម្យ និងកែលំអប្រដាប់ប្រើប្រាស់ ដូចជា ប្រភពផ្តល់អគ្គិសនី ទឹកស្អាត ប្រព័ន្ធលូបង្ហូរទឹកសំអុយ ។ល។នោះ ទិន្នន័យជំរឿនត្រូវផ្តល់គោលការណ៍ណែនាំដល់អ្នកធ្វើផែនការ និងអ្នកគ្រប់គ្រងរដ្ឋបាល ។ ទិន្នន័យជំរឿនក៏មានសារៈប្រយោជន៍ដល់វិស័យផ្សេងៗ ដូចជាក្នុងជំនួញ ពាណិជ្ជកម្ម ឧស្សាហកម្ម និងក្នុងវិស័យសិក្សាស្រាវជ្រាវខាងប្រជារាស្ត្រ ។

## កាលបរិច្ឆេទធ្វើជំរឿន និងពេលវេលាកំណត់

4. ថ្ងៃទី 3 ខែមិនា ឆ្នាំ 1998 ត្រូវបានសន្មត់ថាជាថ្ងៃធ្វើជំរឿន ។ ពេលវេលាកំណត់សំរាប់ ជំរឿនឆ្នាំ 1998 គឺអធ្រាត (00ម៉ោង) ថ្ងៃទី 3 ខែមិនា ឆ្នាំ 1998 ។ នេះមានន័យថាជំរឿន ឆ្នាំ 1998 នឹងផ្តល់ចំនួនប្រជារាស្ត្រនៃប្រទេសកម្ពុជា នាអធ្រាតថ្ងៃទី 3 ខែមិនា ឆ្នាំ 1998 ។

4.1 យ៉ាងណាក្តីក៏ការងារដំបូងនៃការចុះបញ្ជីផ្ទះ ( ឧ ការចុះបញ្ជីផ្ទះ និង គ្រួសារ ) នឹងចាប់ផ្តើមធ្វើនៅថ្ងៃទី 27 ខែកុម្ភៈ ឆ្នាំ1998 ។ តទៅនេះ គឺជាប្រក្រតិទិននៃប្រតិបត្តិការជំរឿនឆ្នាំ 1998 ÷

| **កាលបរិច្ឆេទ** | **ឈ្មោះប្រតិបត្តិការ** |
|---|---|
| ថ្ងៃទី 27 ខែកុម្ភៈ ដល់ថ្ងៃទី 02 ខែមិនា ឆ្នាំ 1998 | ធ្វើការចុះបញ្ជីផ្ទះ |
| ថ្ងៃទី 03 ដល់ថ្ងៃទី 12 ខែ មិនា ឆ្នាំ 1998 | ការសំភាសន៍ជំរឿន |
| ថ្ងៃទី 13 ដល់ថ្ងៃទី 15 ខែមិនា ឆ្នាំ 1998 | ការប្រមូលកំរងឯកសារបំពេញរួចនៅក្នុងមន្ទីរឃុំ |

## សិទ្ធិអំណាចសំរាប់ការធ្វើជំរឿន ខែ មិនា ឆ្នាំ 1998

5. ជំរឿនឆ្នាំ 1998 ត្រូវបានដឹកនាំធ្វើតាមសិទ្ធិអំណាចនៃព្រះរាជក្រឹត្យ លេខ ជស/រកត/02-96 / 08 ចុះថ្ងៃទី 29 ខែ កុម្ភៈ ឆ្នាំ 1996 ស្តីពីការរៀបចំការធ្វើជំរឿនទូទៅនូវប្រជារាស្ត្រនៃប្រទេសកម្ពុជា ។ យោងតាមព្រះរាជក្រឹត្យនេះ ក្រសួងផែនការទទួលខុសត្រូវធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ដោយមានវិទ្យាស្ថានជាតិស្ថិតិ ( វជស ) ជាអង្គភាពអនុវត្តផ្ទាល់ ។

## ការរៀបចំចាត់តែងមូលដ្ឋាននៃជំរឿន

6. គណៈកម្មាធិការជាតិធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ត្រូវបានតែងតាំងឡើងដោយអនុក្រិត្យលេខ 12 ចុះថ្ងៃទី 31 ខែ មករា ឆ្នាំ 1997 ដែលដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃអំពីការទទួលខុសត្រូវ ណែនាំសំរេច និងយល់ព្រមអនុវត្តរាល់ការងារដែលពាក់ព័ន្ធនឹងជំរឿន ។ ក្នុងកំឡុងពេលដឹកនាំធ្វើជំរឿន ការិយាល័យជំរឿននៃវិទ្យាស្ថានជាតិស្ថិតិដែលស្ថិតក្រោមការដឹកនាំរបស់នាយកជំរឿន គឺជាអង្គភាពកណ្តាលដែលមាននាទីណែនាំធ្វើការតាមមូលដ្ឋាន ធ្វើការទាក់ទង នឹងចូលរួមសកម្មភាពសំរាប់ជំរឿន ។ ការិយាល័យជំរឿននេះមាន 7 ផ្នែក ផ្នែកនីមួយៗ ទទួលបន្ទុកសកម្មភាពមួយ ដូចជា ផ្នែករដ្ឋបាល ផ្នែកផែនការនិងពិនិត្យតាមដាន ។ល។ នៅតាមមូលដ្ឋានមន្ត្រីប្រចាំតំបន់នៃ វ.ជ.ស (RO) គឺជាមន្ត្រីសំរបសំរួលបច្ចេកទេសក្នុងតំបន់ ហើយនិងទទួលខុសត្រូវអនុវត្តលើកិច្ចប្រតិបត្តិការនៅក្នុងតំបន់នោះ ។

6.1 ប្រធានមន្ទីរផែនការខេត្ត-ក្រុង មាននាទីជាមន្ត្រីជំរឿនប្រចាំខេត្ត-ក្រុង សំរាប់ខេត្ត-ក្រុងខ្លួនហើយនឹងទទួលខុសត្រូវចំពោះកិច្ចប្រតិបត្តិការនៅក្នុងខេត្ត-ក្រុងនោះ ។ ខាងផ្នែកបច្ចេកទេសនានាលោក-លោកស្រីត្រូវបានអមដោយមន្ត្រីជំនួយការតាមតំបន់ម្នាក់ដែលជាមន្ត្រីរបស់វ.ជ.ស ។

6.2 អភិបាលស្រុកអមដោយបុគ្គលិករបស់ខ្លួន ដែលជាមន្ត្រីទទួលបន្ទុកខាងប្រតិបត្តិការជំរឿននៅក្នុងស្រុក ។ ប្រធានឃុំ គឺជាមន្ត្រីទទួលបន្ទុកជំរឿនសំរាប់ឃុំ និងមានជំនួយ បច្ចេកទេសនានាពីមន្ត្រីខេត្ត / ស្រុក និង អ្នកត្រួតពិនិត្យនៅមូលដ្ឋាននោះ ។ អ្នកចុះសំភាសន៍នឹងអាចជ្រើសរើសយកលោកគ្រូ អ្នកគ្រូ និងមន្ត្រីផ្សេងៗទៀត តាមអត្រាអ្នកសំភាសន៍ម្នាក់សំរាប់មណ្ឌលជំរឿនមួយ ( ប្រហែល 100 គ្រួសារ ឬមានប្រជារាស្ត្រ ពី 500 ទៅ 600 នាក់ ) ។ ជាទូទៅ អ្នកត្រួតពិនិត្យម្នាក់ត្រូវតែងតាំង ដើម្បីត្រួតពិនិត្យផិតដល់លើការងារអ្នកសំភាសន៍ 4 នាក់ ។ ក្រៅពី វជស អាចនឹងមានបង្កើតអង្គភាពពិសេសតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីឱ្យសំរេចបាននូវកិច្ចសហប្រតិបត្តិការ និងធ្វើការពាក់ព័ន្ធអន្តរក្រសួងការតាមតំរូវការចាំបាច់ក្នុងការដឹកនាំធ្វើជំរឿនឱ្យទទួលបានជោគជ័យ ។ រូបភាព 1 បង្ហាញជូនពីរចនាសម្ព័ន្ធនៃការតែងតាំងសំរាប់ការធ្វើជំរឿនឆ្នាំ 1998 ។

# ជំរឿនទូទៅនូវប្រជារាស្ត្រនៃកម្ពុជា ខែមិនា ឆ្នាំ 1998
## ក្រាហ្វិចនៃរចនាសម្ព័ន្ធ



## ប្រការសំខាន់ៗ នៃព្រះរាជក្រឹត្យស្ដីពីជំរឿន

7- សំរាប់ការយោងនិងជូនជាពត៌មាន ប្រការសំខាន់ៗខ្លះនៃព្រះរាជក្រឹត្យ ស្ដីពីការរៀបចំចាត់ចែងធ្វើជំរឿនទូទៅនូវប្រជារាស្ត្រនៃកម្ពុជាត្រូវបានដកស្រង់ជូនខាងក្រោមនេះ :

មាត្រា 7 ម្ចាស់លំនៅដ្ឋានគ្រប់ប្រភេទ និង អ្នកគ្រប់គ្រងទីកន្លែងនានា ត្រូវអនុញ្ញាត អោយមន្ត្រីបំពេញការងារជំរឿន បានចូលលំនៅដ្ឋាន ឬទីកន្លែងរបស់ខ្លួនក្នុងគោលដៅនៃការធ្វើជំរឿន និងអនុញ្ញាតិអោយមន្ត្រីទាំងនោះបានលាបថ្នាំពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសំគាល់នៅតាមកន្លែងចាំបាច់នានាសំរាប់បំរើការងារធ្វើជំរឿនទូទៅនូវប្រជារាស្ត្រ ។

មាត្រា 8: មន្ត្រីបំពេញការងារជំរឿនទាំងឡាយ អាចសួរមេគ្រួសារ ឬសមាជិកគ្រួសារទាំងអស់ក្នុងពេលធ្វើជំរឿនតែតាមសំណួរដូចបានគ្រោងទុកស្រាប់ ហើយនៅតែក្នុងរង្វង់មណ្ឌលដែលបានអនុញ្ញាតិអោយប្រតិបត្តិតែប៉ុណ្ណោះ ។

មាត្រា 9: ប្រជារាស្ត្រគ្រប់រូបត្រូវតែឆ្លើយ ដោយត្រឹមត្រូវទៅតាមការយល់ដឹងដ៏ប្រាកដរបស់ខ្លួនទៅនឹងសំណួរសំភាសន៍ ដែលមន្ត្រីធ្វើជំរឿនបានសួរដូចក្នុងមាត្រា 8 សំរាប់ការធ្វើជំរឿន ។

មាត្រា 12: ពត៌មានជាលក្ខណៈផ្ទាល់ខ្លួន ដែលស្រង់បានក្នុងពេលប្រតិបត្តិការជំរឿនត្រូវបានយកទៅប្រើប្រាស់សំរាប់តែការងារស្ថិតិប៉ុណ្ណោះ ។ ពត៌មានទាំងនោះ ទោះក្នុងករណីណាក៏ដោយ និងមានហេតុផលយ៉ាងណាក៏ដោយ ក៏ពុំត្រូវជូនទៅក្រុមសារពើពន្ធ សាលាជំរះក្ដី ឬ អង្គការដទៃណាទៀតបានឡើយ ។ ពាក្យបណ្ដឹងទៅសាលាជំរះក្ដី ការទារពន្ធអាករដែលសំអាងលើពត៌មានផ្ទាល់ខ្លួនទាំងឡាយដែលស្រង់បានពីប្រតិបត្តិការជំរឿនត្រូវទុកជាមោឃៈ។

7.1 មាត្រា 13 និង 14 ត្រូវផ្ដន្ទាទោសចំពោះអំពើមិនគប្បីខ្លះដែលបានប្រព្រឹត្តក្នុងការទាក់ទងនេះ ។ ឧទាហរណ៍អំពើមិនគប្បីទាំងនេះត្រូវតែផ្ដន្ទាទោស : (i) មន្ត្រីបំពេញការងារជំរឿនទាំងឡាយណា ដែលរាជការបានចាត់អោយជួយធ្វើកិច្ចការជំរឿន ហើយមិនព្រមបំពេញមុខការរបស់ខ្លួន ឬមិនព្រមបំពេញមុខការរបស់ខ្លួនអោយបានចប់សព្វគ្រប់ ។ (ii) មន្ត្រីបំពេញការងារជំរឿនទាំងឡាយណាដែលផ្ដល់ លទ្ធផលខុសណាមួយដល់ការិយាល័យជំរឿន ។ (iii) មន្ត្រីបំពេញការងារជំរឿនទាំងឡាយណាដែលលួចបញ្ចេញពត៌មានដែលខ្លួនបានទទួលពីការធ្វើជំរឿន ។ (iv) ជនណាអោយចម្លើយខុសដោយចេតនាឬមិនព្រមឆ្លើយនូវសំណួរដែលមន្ត្រីបំពេញការងារជំរឿនបានសួរ ។

7.2 សូមកត់សំគាល់ថា យោងតាមប្រការខាងលើនៃព្រះរាជក្រឹត្យ អ្នកត្រូវបំពេញភារកិច្ចជាមន្ត្រីជំរឿនឆ្នាំ 1998 ដោយយកចិត្តទុកដាក់ ហើយរក្សាសំងាត់បំផុតនូវពត៌មានដែលប្រមូលបាន ។

8. ជំរឿននឹងប្រមូលបានពត៌មានតាមរយៈនៃកំរងតារាងពីរ តារាង(ក)បញ្ជីផ្ទះ និងតារាង(ខ)តារាងសំណួរតាមគ្រួសារ ។ តារាង (ក) ត្រូវបានប្រើប្រាស់ក្នុងកំឡុងវគ្គដំបូង (ពីថ្ងៃទី 27 កុម្ភៈ ដល់ ថ្ងៃទី 02 ខែមិនា ឆ្នាំ 1998) សំរាប់បញ្ចូលពត៌មាននៅតាមអគារដែលមានគ្រួសាររស់នៅ ក្នុងនោះ : អគារ / សំណង់លេខ*. សំភារៈសំខាន់ក្នុងការសាងសង់ ជញ្ជាំង ដំបូល និងកំរាល គោលដៅក្នុងការប្រើប្រាស់អគារ / សំណង់ជាលំនៅដ្ឋានពេញ ឬជាផ្នែកៗគ្រួសារលេខ នាមត្រកូលនិងនាមខ្លួន ភេទរបស់មេគ្រួសារ ហើយនិងចំនួនមនុស្សពិតប្រាកដរស់នៅក្នុងគ្រួសារ ។

9. តារាង (ខ ) តារាងសំណួរតាមគ្រួសារមាន 4 ផ្នែកគឺ : ផ្នែកទី 1,2,3, និង 4 ។ ទាំង 4 ផ្នែកនេះត្រូវប្រើប្រាស់សំរាប់អនុវត្តការធ្វើជំរឿនក្នុងកំឡុងថ្ងៃទី 03 ដល់ថ្ងៃទី 12 មិនា ឆ្នាំ 1998 នៅតាមគ្រួសារទាំងអស់ ។ នៅក្នុងផ្នែក 1 គឺសំដៅស្រង់យកពត៌មានអំពីចំនួនសមាជិកពិតប្រាកដរស់នៅក្នុងគ្រួសារដែលវត្តមាន និងអវត្តមាន និងភ្ញៀវវត្តមានក្នុងគ្រួសារនៅយប់ធ្វើជំរឿន (ថ្ងៃទី 03 ខែមិនា ឆ្នាំ 1998 ) ។

10. ផ្នែក 2 នៃតារាង (ខ ) និងត្រូវបានប្រើសំរាប់ប្រមូលពត៌មានលំអិតពីសមាជិកគ្រួសារពិតប្រាកដម្នាក់ៗដែលវត្តមានក្នុងគ្រួសារ និងភ្ញៀវម្នាក់ៗនៅក្នុងគ្រួសារនោះដូចជា : នាមត្រកូល និងនាមខ្លួនពេញលេញ ទំនាក់ទំនងជាមួយមេគ្រួសារ ភេទ អាយុ ស្ថានភាពអាពាហ៍ពិពាហ៍ ភាសាកំណើត សាសនា ទីកន្លែងកើត លំនៅដ្ឋានមុន រយៈពេលស្នាក់នៅ មូលហេតុនៃការធ្វើអន្តោប្រវេសន៍ អក្ខរភាព រយៈពេលសិក្សាពេញលេញ និងលក្ខណៈសេដ្ឋកិច្ច ។

11. ក្នុងផ្នែក 3 នៃតារាង (ខ ) ត្រូវប្រមូលពត៌មានលំអិតពីភាពអាចបង្កើតកូនបានរបស់ស្ត្រីនៅក្នុងគ្រួសារដែល មានអាយុពី 15ឆ្នាំឡើងទៅ ។ ក្នុងផ្នែក 4 នៃតារាង (ខ ) ត្រូវប្រមូលពត៌មានពីស្ថានភាពលំនៅដ្ឋាន និង ប្រដាប់ប្រើប្រាស់នៅក្នុងផ្ទះដូចជា : មូលដ្ឋានក្នុងការគ្រប់គ្រងគេហដ្ឋានរបស់គ្រួសារ (ជាម្ចាស់ផ្ទះផ្ទាល់ ឬក៏ជួលផ្ទះគេនៅ) ប្រភពសំខាន់ៗដែលផ្តល់ពន្លឺក្នុងគ្រួសារ ឥន្ធនៈសំខាន់ៗសំរាប់ចំអិនដែលប្រើប្រាស់ដោយគ្រួសារ ស្ថានភាពបង្គន់ដែលមានក្នុងបរិវេណដីឡូត៍ ប្រភពផ្តល់ទឹកស្អាតសំខាន់ៗសំរាប់ប្រើប្រាស់ក្នុងគ្រួសារ ចំនួនបន្ទប់ដែលកាន់កាប់ដោយគ្រួសារ ។

12. ពត៌មានទាំងឡាយដែលប្រមូលបានខាងលើ គឺជាមូលដ្ឋានជួយដល់ការស្វែងយល់អំពីលក្ខណៈប្រជាសាស្ត្រ និង លក្ខណៈផ្ទះសំបែងក្នុងប្រទេសទាំងមូល ។ ហេតុនេះគឺជាការចាំបាច់ណាស់ដែលពត៌មាន

---

* ពាក្យអគារត្រូវបានប្រើចាប់ពីពេលនេះតទៅ សំដៅដល់អគារ ឬសំណង់ (អគារ /សំណង់)

ប្រមូលបាន ត្រូវតែត្រឹមត្រូវ ពិតប្រាកដតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ការងាររបស់អ្នកសំភាសន៍ និងត្រូវបានត្រួតពិនិត្យយ៉ាងដិតដល់ដោយអ្នកត្រួតពិនិត្យម្នាក់ និងមន្ត្រីត្រួតពិនិត្យផ្សេងទៀត ។

12.1 សំភារៈសំរាប់មន្ត្រីសំភាសន៍

សំភារៈសំរាប់មន្ត្រីសំភាសន៍រួមមានដូចតទៅ: 1- តារាង ក បញ្ជីផ្ទះ (6 សន្លឹក) 2- តារាង ខ តារាងសំណួរតាមគ្រួសារ (120 សន្លឹក ) 3- សេចក្តីណែនាំរបស់មន្ត្រីសំភាសន៍ (1 ច្បាប់) 4- តារាងប្តូរអាយុ ឆ្នាំ (1) 5 - ប៊ីច (5 ដើម) 6- តារាង 1 តារាងសរុបសង្ខេបបញ្ជីផ្ទះ ( 2 សន្លឹក ) 7- តារាង 2- តារាងសរុបសង្ខេបរបស់មន្ត្រីសំភាសន៍ (5 សន្លឹក ) 8- តារាង 3 ចំនួនតារាងសំណួរដែលបានទទួល (1) 9- លិខិតសុំជួបសំភាសន៍ (5 សន្លឹក) 10- សៀវភៅ (1 ក្បាល) 11- ខ្មៅដៃ (2 ដើម) 12- ជ័រលុប (1 ដុំ) 13- ប្រដាប់ចិតខ្មៅដៃ (1) 14- ប៊ិចជិត (1) 15- តារាង ក សំរាប់រៀន (2 សន្លឹក) 16- តារាងខ សំរាប់រៀន (4 សន្លឹក) 17-ផែនទីមណ្ឌលជំរឿន /ភូមិជំរឿន (1 សន្លឹក) 18-ក្រដាសលាតសំរាប់គូសផែនទី (2 សន្លឹក) 19-ក្រដាសស (5 សន្លឹក) 20- តារាង 4 លិខិតបញ្ជាក់ពីប្រធានភូមិ (1) 21- កាតាប (1) ។ សូមអ្នកទទួលដោយពេញចិត្តនូវសំភារៈ ដែលអ្នកបានទទួលដូចបាន រៀបរាប់ពីខាងលើ ។

# ជំពូក II

## ការបំពេញតារាង (ក): តារាងបញ្ជីផ្ទះ

**តារាងបញ្ជីផ្ទះ**

13. តារាង (ក ) ជាបញ្ជីសំរង់ផ្ទះដែលនឹងត្រូវបំពេញក្នុងប្រតិបត្តិការដំបូងសំរាប់រយៈពេលប្រហែល 4ថ្ងៃមុនយប់ធ្វើជំរឿន ។ មុននឹងផ្តើមធ្វើការរាប់ជំរឿននោះជាចាំបាច់ត្រូវតាមគ្រប់ទីកន្លែងធ្វើការសំគាល់ទីតាំងដែលកាន់កាប់ ឬ ប្រើប្រាស់ ឬ ដែលទំនងត្រូវបានកាន់កាប់ ឬបានប្រើប្រាស់ដោយមនុស្ស ។ ប្រតិបត្តិការចុះបញ្ជីផ្ទះគឺមានន័យជាសំខាន់សំរាប់គោលបំណងនេះ ហើយថ្វីបើការចុះបញ្ជីផ្ទះជាកិច្ចការដំបូងក៏ពិតមែន តែជាជំហានសំខាន់បំផុតក្នុងការធ្វើជំរឿន ។ បញ្ជីផ្ទះនឹងត្រូវបានជួយសំគាល់គ្រួសារជាបឋមមុនចាប់ដំណើរការធ្វើការរាប់ជំរឿន ។ ការចុះបញ្ជីផ្ទះនេះក៏ផ្តល់ពត៌មានជាបឋមផងដែរនូវចំនួនមនុស្សពិតប្រាកដដែលកំពុងរស់នៅក្នុងគ្រួសារឬសមាជិកពិតប្រាកដរបស់គ្រួសារ ។

14. បញ្ជីផ្ទះដែលស្នើឱ្យបំពេញក្នុងអំឡុងប្រតិបត្តិការចុះបញ្ជីផ្ទះ នឹងមានភ្ជាប់ជូននៅផ្នែកចុងក្រោយនៃសៀវភៅនេះ (ឧបសម្ព័ន្ធ ក ) ។ គេអាចកត់សំគាល់បានថា តារាងនេះជាតារាងងាយស្រួល ។ ចំណុចទាំងឡាយក្នុងតារាងបញ្ជីផ្ទះដែលត្រូវបំពេញនេះ ហើយនិងទស្សនៈ និងការពន្យល់អំពីទស្សនៈទាំងនេះនឹងត្រូវបានពណ៌នាជាលំអិតនៅក្នុងជំពូកនេះ ។ ជាការចាំបាច់ណាស់ដែលត្រូវយល់ឱ្យបានច្បាស់ថា ការណែនាំអំពីការចុះបញ្ជីផ្ទះនេះគឺជាការងារមួយដែលសំខាន់បំផុត ។ ក្រៅពីបញ្ជីផ្ទះនេះអ្នកនឹងប្រមូលយកទិន្នន័យដែលមានសារៈប្រយោជន៍មួយចំនួនអំពីផ្ទះសំរែងសំរាប់ក្នុងគោលដៅធ្វើផែនការ ។ ជោគជ័យនៃប្រតិបត្តិការចុះបញ្ជីផ្ទះ គឺពឹងផ្អែកយ៉ាងពិតប្រាកដទៅលើការយល់ដឹងដោយប្រាកដអំពីទស្សនៈ និយមន័យ និង ការណែនាំ ហើយនិងផ្អែកទៅលើការអនុវត្តជាក់ស្តែងនិង ដោយត្រឹមត្រូវនូវទស្សនៈ និយមន័យទាំងនេះទៅតាមការណែនាំពិតប្រាកដក្នុងការបំពេញតារាងបញ្ជីផ្ទះ ។ បើសិនអ្នកសំភាសន៍មានចំងល់ណាមួយនោះ មិនត្រូវមានការរុញរាទេ ពោលគឺត្រូវសួរដល់អ្នកត្រួតពិនិត្យឱ្យជួយធ្វើការបំភ្លឺពីចំងល់ទាំងនោះ ។

15. ប្រតិបត្តិការចុះបញ្ជីផ្ទះនឹងមានការពាក់ព័ន្ធជាមួយជំហានជាមូលដ្ឋានខ្លះៗ ដែលនឹងអធិប្បាយជាសង្ខេបដូចតទៅ :

(i) រៀបចំផែនទីមណ្ឌលជំរឿន ( ផែនទីមណ្ឌលជំរឿន ) (EA) ឱ្យទាន់សម័យកាលសំរាប់ផ្តល់ជូនដល់អ្នកសំភាសន៍តាមមណ្ឌលជំរឿន

(ii) ចុះលេខអគារ និងលេខគ្រួសារនៅក្នុងមណ្ឌលជំរឿនរបស់អ្នក ហើយនិងចុះលេខទាំងនោះលើផែនទីមណ្ឌលជំរឿន

(iii) ធ្វើការបំពេញតារាងបញ្ជីផ្ទះ

16. ដំបូងត្រូវអធិប្បាយអំពីបែបបទសំរាប់រៀបចំផែនទីមណ្ឌលជំរឿនឱ្យទាន់សម័យកាល បន្ទាប់មកត្រូវអធិប្បាយអំពីទស្សនៈមូលដ្ឋានដែលទាក់ទងទៅនឹងអគារ ហើយនិងគ្រួសារ ។ បែបបទទាំងនេះត្រូវបានបង្ហាញតាមការណែនាំជាក់ស្តែងសំដៅបំរើឱ្យការបំពេញតារាងបញ្ជីផ្ទះ ។

## ការរៀបចំផែនទីមណ្ឌលជំរឿនឱ្យទាន់សម័យកាល

17. ដើម្បីបំពេញបញ្ជីផ្ទះបានពេញលេញចាំបាច់ត្រូវកំណត់ទីតាំង និងលក្ខណៈសំគាល់របស់អគារ និងគ្រួសារ ។ កិច្ចការនេះអាចធ្វើទៅបានលុះត្រាណាតែអ្នកបានស្គាល់ពិតប្រាកដនូវមណ្ឌលជំរឿន ដែលគេបានប្រគល់ឱ្យអ្នកធ្វើប្រតិបត្តិការ ។ គោលបំណងនៃផែនទីមណ្ឌលជំរឿន គឺជួយអ្នកឱ្យយល់ច្បាស់ពីយុត្តាការរបស់អ្នកឬមណ្ឌលជំរឿនរបស់អ្នក ។ បើសិនផែនទីមណ្ឌលជំរឿននៅនឹងខ្លួនអ្នក អ្នកអាចលៃចែកលេខផ្ទះតាមបែបបទជាប្រព័ន្ធបានយ៉ាងស្រួល ។ ហេតុនេះ ជំហានដំបូងត្រូវរៀបចំផែនទីមណ្ឌលជំរឿនអោយទាន់សម័យកាលសិន ហើយដៅឱ្យច្បាស់នូវអគារប្រើជាលំនៅដ្ឋានពេញលេញ និងជាលំនៅដ្ឋានជាផ្នែកៗ ។

18. ផែនទីមណ្ឌលជំរឿនដែលផ្តល់ជូនដល់អ្នកគឺជាផែនទីដែលបានគូសមិនទៅតាមមាត្រាដ្ឋានទេ ( សូមមើលផែនទីគំរូនៅឧបសម្ព័ន្ធ ខ (i) សំរាប់តំបន់ជនបទ និង ឧបសម្ព័ន្ធ ខ (ii)សំរាប់ទីប្រជុំជន ឧ. ទីក្រុងរបស់ទីរួមខេត្ត ) ។ ដោយផែនទីមណ្ឌលជំរឿនបានរៀបចំរួចច្រើនខែកន្លងមក ហេតុនេះត្រូវមានការពិនិត្យកែតំរូវផែនទីនោះឱ្យទាន់សម័យកាល ។ មណ្ឌលជំរឿនមួយអាចជាភូមិទាំងមូលមួយ ឬ មួយផ្នែកនៃភូមិ ( ក្នុងករណីភូមិធំមានប្រជារាស្ត្រច្រើន ) ។ ការកំណត់ព្រំដែនមណ្ឌលជំរឿនទាំងឡាយ ឬបង្កើតមណ្ឌលជំរឿនទាំងឡាយត្រូវធ្វើតាមបែបបទកំណត់មួយច្បាស់លាស់ ដោយមិនមានអគារ ឬសំណង់ណាមួយដែលមានគ្រួសារមួយ ឬ ច្រើនរស់នៅទុកចោល ឬ ភ្លេចដោយមិនបានរាប់នោះទេ ។ ផែនទីមណ្ឌលជំរឿនបង្ហាញអំពីលក្ខណៈភូមិសាស្ត្រជាលំអិត ។ លក្ខណៈភូមិសាស្ត្រជាលំអិតដែលបញ្ជាក់នៅលើផែនទីមណ្ឌលជំរឿនមានរាប់បញ្ចូលនូវចំណុចពិសេសជាអចិន្ត្រៃយ៍ និងជាសញ្ញាសំគាល់ ដូចជាភូមិដ្ឋាន ផ្លូវថ្នល់ ដែលគេស្គាល់ច្រើន ផ្លូវរទេះ ផ្លូវថយន្តធុនធំ ភ្នំ ទន្លេ ស្ទឹង ព្រៃ ។ល។ ព្រមទាំងផ្លូវរថភ្លើង, មន្ទីរពេទ្យ សាលារៀន វត្តអារាម និង ស្ថានភាពមានលក្ខណៈស្រដៀងគ្នាដែលគេអាចចំណាំបាន ។ ជាបឋម អ្នកអាចរៀបចំផែនទីមណ្ឌលជំរឿនបានដោយពិភាក្សាប្តូរយោបល់ជាមួយប្រធានភូមិដែលពាក់ព័ន្ធនឹងមណ្ឌលជំរឿននេះ ។ សូមផ្ទៀងផ្ទាត់លក្ខណៈពិសេសដែលអាចសំគាល់បានឱ្យឃើញថាគេមាននៅចំកន្លែងរបស់វានៅក្នុងផែនទីមណ្ឌលជំរឿនឬទេ ។ ជាចាំបាច់អ្នកអាចធ្វើការកែសំរួលដោយបន្ថែមលក្ខណៈពិសេស

ថ្មីដែលអ្នកសំគាល់ឃើញ ឬ លុបចោលលក្ខណៈពិសេសដែលគ្មានរូប ។ បើសិនអ្នកពិនិត្យឃើញទីតាំងលំនៅដ្ឋានថ្មីដែលមិនបានដាក់ចូល អ្នកអាចបញ្ជាក់ទីតាំងនោះនៅលើផែនទីមណ្ឌលជំរឿន ។

19. ជំហានបន្ទាប់គឺកំណត់ទីតាំងអគារដាច់ដោយឡែក ដែលកាន់កាប់ដោយគ្រួសារមួយ ឬ ច្រើនគ្រួសារនៅក្នុងមណ្ឌលជំរឿន ។ អគារទាំងនោះត្រូវបានប្រើសញ្ញាសំគាល់នៅលើផែនទីមណ្ឌលជំរឿនដូចបញ្ជាក់ជូនខាងក្រោមនេះ :

☐ *អគារទាំងមូល ដែលប្រើជាលំនៅដ្ឋាន ។*

■ *អគារប្រើជាលំនៅដ្ឋានផង និងមិនមែនជាលំនៅដ្ឋានផង (ឧទាហរណ៍ ជាលំនៅដ្ឋានផងនិងជាហាងលក់ទំនិញផង ជាលំនៅដ្ឋានផងនិងជាសិប្បកម្មតំបាញផង ជាលំនៅដ្ឋានផងនិងជារោងជាងផង ។ល។ ) ។*

20. នៅពេលដែលបានធ្វើសញ្ញាសំគាល់ទីតាំងអំពីអគារនិមួយៗដែលបានប្រើប្រាស់ជាលំនៅដ្ឋានទាំងមូលឬជាផ្នែកៗ នោះត្រូវកំណត់យកគំរុយលើផែនទីមណ្ឌលជំរឿនសំរាប់ផ្តល់ភាពងាយស្រួលដល់ការដាក់លេខសំគាល់អគារ ។ គ្មានក្បួនច្បាប់ណាមួយដែលចាប់បង្ខំ ឬដែលអះអាងថាអាចធ្វើការចុះលេខកូដអគារបានហើសដោយត្រូវដើរតាមទិសដៅណាមួយជាដាច់ខាតនោះបានទេ ។ ឧទាហរណ៍ ត្រូវដើរពីឆ្វេងទៅស្តាំ ឬស្របតាមទ្រនិចនាឡិកា ពីពាយ័ព្យទៅអគ្នេយ៍ ។ល។ និង ។ល។ ទាំងអស់នេះគឺអាស្រ័យទៅលើការកត់ត្រាទាំងស្រុង ។ អ្វីដែលត្រូវធ្វើទៅឱ្យបានស្រួលនិងវៃឆ្លាតនោះគឺត្រូវអនុវត្តតាមលំដាប់របស់វានោះឯង ។

## ការដាក់លេខរៀងអគារ

21. សេចក្តីណែនាំដែលផ្តល់ជូនពីពេលនេះទៅគឺណែនាំអ្នកសំភាសន៍ ឱ្យកំណត់អគារមួយសំរាប់គោលដៅនៃការចុះបញ្ជីផ្ទះ ។ អគារមួយគឺជាសំណង់ ឬ ប្រជុំសំណង់ដាច់ដោយឡែកមួយដែលគេសន្មតយកធ្វើជាឯកតាសំរាប់ដាក់លេខរៀងផ្ទះ ។ គោលបំណងគឺធ្វើការចុះលេខឱ្យបានស្រេចបាច់ហើយនិងចុះបញ្ជីឱ្យបានអស់នូវគ្រប់ឯកតាសំណង់ ដែលបានប្រើជាគោលដៅលំនៅដ្ឋានទាំងមូល ឬជាផ្នែកៗ ។

22. **អគារ** : ជាទូទៅអគារមួយគឺជាសំណង់មួយដែលសង់ដាច់ដោយឡែកនៅលើដី ។ អគារនេះគ្របដោយដំបូល និងហ៊ុំព័ទ្ធដោយជញ្ជាំង ឬដោយជញ្ជាំងរួមជាប់គ្នាមើលទៅដូចជាសំណង់តគ្នា ។ នៅតំបន់ខ្លះ លក្ខណៈនៃការសាងសង់ផ្ទះគ្មានជញ្ជាំង ។ ឧទាហរណ៍ ដំបូលសាជីទល់ដី ហើយមានទ្វារចូលមួយដោយគ្មានជញ្ជាំងណាមួយសោះ សំណង់បែបនេះគឺចាត់ទុកថាជាអគារបានដែរ ។ ជួនកាលអគារមួយ

បានសាងសង់ឡើងដោយមានឯកតាច្រើនជាងមួយត្រូវបានប្រើ ឬមានទំនងប្រើជាផ្ទះ (លំនៅដ្ឋាន) ឬជាគ្រឹះស្ថានដូចជាហាងលក់ទំនិញ ផ្ទះពាណិជ្ជកម្ម ការិយាល័យ កម្មន្តសាល រោងជាង ឃ្លាំង សាលារៀន កន្លែងកំសាន្ត និងកន្លែងធ្វើសក្ការៈ ឬ ជារោងអ្នកតា ឃ្លាំងទំនិញ គ្រោលសត្វ ។ល។ គេអាចនិយាយបានថា អគារនោះត្រូវបានប្រើប្រាស់ក្នុងគោលដៅរួមគឺគេប្រើជា ហាងលក់ទំនិញផងជាលំនៅដ្ឋានផង ជារោងជាងផងនិងជាលំនៅដ្ឋានផង ជាការិយាល័យផងនិងជាលំនៅដ្ឋានផង ។ល។

23. ជួនកាលនៅតាមបណ្តោយផ្លូវគេឃើញផ្ទះមួយជួរសង់ប្លែកពីគ្នា ពីមួយទៅមួយដោយមានជញ្ជាំងរួមជាប់គ្នាមើលទៅដូចជាសំណង់តគ្នា ។ សំណង់ប្លែកៗគ្នាទាំងនេះអាចចាត់ទុកថាជាផ្ទះដាច់ដោយឡែកពីគ្នា ហើយហាក់ដូចជាបានសង់ឡើងនៅពេលខុសគ្នា និង មានម្ចាស់គ្រប់គ្រងខុសគ្នា ។ ក្នុងករណីនេះ ទោះបីសំណង់ទាំងមូលមានផ្ទះជាប់ៗគ្នាហើយមើលឃើញដូចជាអាគារតែមួយ ក៏គេត្រូវកំណត់ល្វែងអាគារនិមួយៗថាជាអាគារដាច់ដោយឡែកពីគ្នា និងមានលេខផ្សេងពីគ្នា ។ម្យ៉ាងទៀតអ្នកសំភាសន៍ អាចជួបប្រទះឃើញករណីដែលមានអគារខ្ពស់ច្រើនជាន់ ពិសេសនៅរាជធានីភ្នំពេញ ដែលមើលទៅ ហាក់ដូចជាអគារតែមួយ ហើយជាន់ទាំងឡាយគ្រប់គ្រងដោយមនុស្សផ្សេងគ្នា ។ ក្នុងករណីដែលសំណង់មួយមានច្រើនល្វែង ច្រើនជាន់និងកាន់កាប់ដោយមនុស្សផ្សេងគ្នានោះ អគារនោះត្រូវចាត់ទុកថាជា អគារតែមួយហើយគ្រួសារនិមួយៗនៅក្នុងអគារនោះត្រូវបានកត់ត្រា និងរាប់សំភាសន៍ ។

24. ប្រសិនបើមានសំណង់ច្រើនជាងមួយស្ថិតក្នុងបរិវេណដីឡូត៍មួយមានរបងពទ្ធ័ជុំវិញ ឬ គ្មានរបងព័ទ្ធជុំវិញ ( បរិវេណដីឡូត៍ ) និងជាកម្មសិទ្ធិរបស់មនុស្សតែម្នាក់ ឧទាហរណ៍ មានផ្ទះធំមួយ គ្រោលសត្វមួយ កន្លែងអង្គុយលេងមួយ រោងដាក់ឡានមួយ ។ល។ នោះត្រូវគិតយកតែអគារមួយ និងផ្តល់លេខសំគាល់អគារតែមួយទេ ។

25. អគារត្រូវបានផ្តល់លេខតាមប្រព័ន្ធបែបបទដូចតទៅ :

*(i) ត្រូវចុះបញ្ជីផ្ទះតែអគារដែលមានគ្រួសាររស់នៅក្នុងនោះ នឹងអគារទំនេរ ។ ដូច្នេះអគារដែលប្រើជាលំនៅដ្ឋានទាំងមូលផង និងអគារដែលប្រើជាលំនៅដ្ឋានដោយផ្នែកនិងមិនមែនជាលំនៅដ្ឋានដោយផ្នែកផង ( ដូចជាហាងលក់ទំនិញមានគ្រួសារកំពុងរស់នៅ ការិយាល័យនៅក្នុងនោះមានឆ្មាំរស់នៅ ។ល។ ) គឺត្រូវរាប់អគារនោះហើយចុះលេខផង ។ អគារទាំងមូលដែលប្រើមិនមែនក្នុងគោលបំណងជាលំនៅដ្ឋានមិនបាច់ចុះលេខទេ ។*

(ii)- បើនៅក្នុងមណ្ឌលជំរឿនមួយមានផ្លូវច្រើន អគារដែលនៅតាមផ្លូវទាំងនោះត្រូវបានរាប់និងចុះលេខរៀងតៗគ្នា ។ គេត្រូវរាប់ផ្លូវទាំងនោះតាមលំដាប់ឯកភាពគ្នាពីពាយ័ព្យទៅអគ្នេយ៍ ។ មធ្យោបាយដែលល្អបំផុតក្នុងការដាក់លេខអគារគឺត្រូវធ្វើតៗគ្នាតាមលេខរៀងពីដើមនៃម្ខាងផ្លូវរហូត

ដល់ចប់ចុងផ្លូវម្ខាងនោះ រួចបត់ទៅចុងម្ខាងទៀតនៃផ្លូវហើយចុះលេខបន្តត្រឡប់មករកដើមផ្លូវវិញ ដោយបញ្ចប់លេខចុងក្រោយបំផុតនៅទល់មុខគ្នានិងលេខចាប់ផ្តើម ។

(iii)- នៅតាមមណ្ឌលជំរឿនក្នុងទីក្រុងនិងទីប្រជុំជនការចុះលេខរៀងត្រូវចុះតាមបណ្តោយផ្លូវដោយមិនត្រូវចុះតាមទិសនៃភូមិសាស្ត្រណាមួយតាមនឹកឃើញទេ ។

(iv)- ការចុះលេខអគារត្រូវប្រើលេខបីខ្ទង់ដូចជា 001,002,.....999 ។ ត្រូវសរសេរលេខអគារចំណាំលើផ្លាកដាក់នៅតាមមាត់ទ្វារចូល ឬសរសេរលេខពណ៌លើទ្វារនៃអគារដែលអាចធ្វើអោយអ្នកផងមើលឃើញស្រួល ។ នៅពេលដែលសរសេរលេខពណ៌ ( សរសេរលើផ្លាក ) លេខអគារត្រូវសរសេរអក្សរ ជ ពីមុខលេខ 3 ខ្ទង់ ដូចជា ជ008,ជ021 ។ល។ សំរាប់បែងចែកលេខរៀងរបស់យើង ( "ជ" មានន័យថាជំរឿន ) ពីលេខរៀងផ្សេងទៀតដែលអគារនោះអាចមាន ។

26. ក្នុងករណីខ្លះគំរូលំនៅដ្ឋានអាចជាប្រជុំខ្ទមដែលតាំងនៅក្នុងបរិវេណមួយដែលមានរបង ឬ គ្មានរបងហើយកាន់កាប់ដោយគ្រួសារមួយ ។ ពេលដែលលំនៅដ្ឋានសំខាន់ស្ថិតនៅក្នុងខ្ទមមួយ ហើយខ្ទមឯទៀតបានប្រើសំរាប់ដេក ឬ ជាផ្ទះបាយ បន្ទប់ទឹក ។ល។ នោះ ទោះជាខ្ទមនិមួយៗជាសំណង់ដាច់ដោយឡែកពីគ្នាក៏ដោយក៏សំរាប់គោលបំណងជំរឿនខ្ទមទាំងនោះត្រូវរួមជាឯកតាលំនៅដ្ឋានតែមួយ ពោលត្រូវចាត់ជារួមជាអគារ / សំណង់តែមួយ ។ បើខ្ទមខ្លះនៅក្នុងចំណោមខ្ទមទាំងនោះបានប្រើប្រាស់ដោយគ្រួសារមួយហើយខ្ទមឯទៀតប្រើប្រាស់ដោយគ្រួសារទី 2 ជាលំនៅដ្ឋាននោះត្រូវបំបែកក្រុមខ្ទមទាំងនោះចេញជាចង្កោមអគារពីរដាច់ដោយឡែកគ្នា ។

## គ្រួសារ

27. គ្រួសារមួយជាមនុស្សមួយក្រុមដែលរស់នៅជាមួយគ្នាហើយបរិភោគបាយដែលចេញពីចង្ក្រានរួម លើកលែងតែអ្នកណាមួយ ដែលតម្រូវការក្នុងការងារបង្ខាំងអោយអ្នកនោះមិនបានមកដេកឬបរិភោគបាយជាមួយគ្នា ។ អាចមានគ្រួសារដែលមានសមាជិកសុទ្ធតែជាមនុស្សជាប់សាច់ញាតិគ្នា ឬគ្រួសារដែលមាន សមាជិកជាមនុស្សមិនជាប់សាច់ញាតិគ្នា និងគ្រួសារដែលមានសមាជិករាប់ទាំងមនុស្សជាប់សាច់ញាតិគ្នាផងនិងមនុស្សមិនជាប់សាច់ញាតិគ្នាផង ។ ឧទាហរណ៍ គ្រួសារដែលសមាជិកមិនជាប់សាច់ញាតិគ្នា គឺផ្ទះបាយខែ អាហារដ្ឋាន អន្តេវាសិកដ្ឋាន សណ្ឋាគារ ផ្ទះសង្គ្រោះ ពន្ធនាគារ វត្តអារាម ។ល។ គ្រួសារទាំងនេះហៅថា "គ្រួសារស្ថាប័ន" ។ អាចមានសមាជិកគ្រួសារតែម្នាក់សមាជិកគ្រួសារតែពីរនាក់ឬក៏មានសមាជិកគ្រួសារច្រើននាក់ ។ សំរាប់គោលបំណងនៃការធ្វើជំរឿនប្រភេទនិមួយៗក្នុងចំណោមប្រភេទទាំងនេះអាចចាត់ទុកថា " គ្រួសារមួយ " ។

28. បើមានមនុស្សមួយក្រុម ពីម្នាក់ទៅម្នាក់មិនមែនជាប់សាច់ញាតិគ្នាហើយមករស់នៅក្នុងអគារ / សំណង់មួយដោយមិនបានបរិភោគបាយចេញពីផ្ទះបាយរួមនោះពួកគេទាំងនោះមិនអាចបង្កើតជាគ្រួសាររួមគ្នាបានឡើយ ។ មនុស្សម្នាក់ៗនៃក្រុមជនទាំងនេះត្រូវចាត់ទុកជាគ្រួសារដាច់ដោយឡែកពីគ្នាមួយ ។ កត្តាសំខាន់ក្នុងការសន្មតថាជាគ្រួសារមួយ ឬមិនមែនជាគ្រួសារនោះគឺស្ថិតនៅត្រង់មានចង្ក្រានបាយរួមគ្នា ។

28.1 គ្រួសារនិមួយៗនៅក្នុងអគារមួយគឺត្រូវបានចុះលេខសំគាល់ដូចជា 01, 02 ។ល។ ហើយនិងត្រូវបានចុះបញ្ជីតាមការណែនាំដូចតទៅ ÷ គ្រួសារនិមួយៗត្រូវទាក់ទងទៅនឹងសំណង់នៃអគារតាមការឃើញជាក់ស្តែង ដូចនេះលេខគ្រួសារមិនត្រូវបានសរសេរដោយពណ៌ ( ឬ សរសេរលើផ្លាក ) នៅលើទ្វារនៃអគារនិមួយៗ ។ តែក្នុងករណីដែលមានគ្រួសារច្រើនរស់នៅក្នុងអគារមួយ ( ផ្ទះជាន់ល្វែង ) នោះលេខគ្រួសារអាចសរសេរលើទ្វារ ( ឬសរសេរលើផ្លាក ) នៃល្វែងផ្ទះគ្រួសារនោះដើម្បីងាយស្រួលដល់ការសំគាល់ ។

## ការដាក់លេខអគារនៅលើផែនទីមណ្ឌលជំរឿន

29 លេខសំគាល់អគារនិមួយៗ និងលេខសំគាល់ចំនួនគ្រួសារដែលមាននៅតាមអគារនិមួយៗ ត្រូវសរសេរបង្ហាញអោយច្បាស់លើផែនទីមណ្ឌលជំរឿនដូចមានបង្ហាញគំរូខាងក្រោមនេះ

( 2 )

អគារទី 1 មានពីរគ្រួសាររស់នៅក្នុងនោះ

001

( 1 )

អគារទី3 គេបានប្រើជាលំនៅដ្ឋានផងនិងមិនមែនលំនៅដ្ឋានផង ហើយដែលមានតែមួយ

003 គ្រួសារកំពុងរស់នៅក្នុងនោះ ។

29.1 ដោយមានជំនួយពីព្រួញដាក់សំគាល់តាមចន្លោះ នោះក្នុងការដាក់លេខអគារត្រូវដាក់ព្រួញ សញ្ញាសំគាល់សំរាប់កំណត់យកទិសដៅ ។

29.2 គំរូផែនទីមណ្ឌលជំរឿនទាន់សម័យកាល ក្រោយការដាក់លេខរៀងអគារនឹងបង្ហាញជូននៅក្នុងឧបសម្ព័ន្ធ គ (i) សំរាប់តំបន់ជនបទ និង ឧបសម្ព័ន្ធ គ (ii) សំរាប់ទីប្រជុំជន ( ឧ. ទីក្រុងរបស់ទីរួមខេត្ត )។

## ការចុះបញ្ជីផ្ទះ

30. ក្រោយពីបានដាក់លេខអគារនិងគូសអគារទាំងនោះលើផែនទីមណ្ឌលជំរឿនរួចត្រូវកែលំអផែនទីមណ្ឌលជំរឿនទាន់សម័យកាល ហើយជាជំហានបន្ទាប់ គឺត្រូវចុះលេខរៀងអគារនិងគ្រួសារទាំងនោះចូលក្នុងតារាង

តារាងដែលបានរៀបរៀងស្រេច "បញ្ជីផ្ទះ " ។ នៅក្នុងជំរឿនគំរោងតារាងនេះឈ្មោះថាតារាង ក : តារាងបញ្ជីផ្ទះ ( មើលឧបសម្ព័ន្ធ ក ) ដែលអ្នកសំភាសន៍ត្រូវបំពេញនៅជំហានទី 1 ។

30.1 *អ្នកសំភាសន៍ត្រូវចុះទៅមើលអគារនិមួយៗនៅក្នុង EA របស់ខ្លួនអោយឃើញច្បាស់ដើម្បីចុះបញ្ជីផ្ទះដែលនៅក្នុងនោះមានមនុស្ស ឬ គ្រួសាររស់នៅ ។ ក្នុងករណីជួបនឹងការិយាល័យ និងផ្ទះពាណិជ្ជកម្ម អ្នកសំភាសន៍ត្រូវប្រុងប្រយ័ត្នបំផុតដោយអាចមានឆ្មាំ ឬ សមាជិកខ្លះប្រើអគារទាំងនេះធ្វើជាកន្លែងស្នាក់នៅរបស់ខ្លួន ។ អ្នកសំភាសន៍ត្រូវចុះបញ្ជីអគារទាំងនោះដោយប្រើសញ្ញាសំគាល់ប្រើជាលំនៅដ្ឋានផង និងមិនមែនជាលំនៅដ្ឋានផង ។ អគារទំនេរនិងអគារចាក់សោរដែលមានមនុស្សរស់នៅត្រូវរាប់បញ្ចូលក្នុងបញ្ជីផងដែរ ។*

30.2- សេចក្តីណែនាំខាងក្រោមនឹងអាចនាំផ្លូវអ្នកសំភាសន៍ក្នុងការបំពេញបញ្ជីផ្ទះ :

នៅក្បាលទំព័រនៃតារាងបញ្ជីផ្ទះមានពត៌មានសំគាល់ឈ្មោះ ខេត្ត / ក្រុង ដោយមាន លេខកូដ ឈ្មោះស្រុក / ខ័ណ្ឌ មានលេខកូដ ឈ្មោះឃុំ / សង្កាត់ មានលេខកូដ ឈ្មោះភូមិ / មណ្ឌល មានលេខកូដ និងមណ្ឌលជំរឿនលេខ ។ ឈ្មោះអង្គភាពរដ្ឋបាលដូចជា ខេត្ត / ក្រុង ស្រុក / ខ័ណ្ឌ នឹងផ្តល់ជូនដល់អ្នកសំភាសន៍សំរាប់សំរួលការងារ ។ ឈ្មោះអង្គភាពដែលមិនអាចយកជាការបានត្រូវលុបចោល ឧទាហរណ៍ ប្រសិនបើមណ្ឌលជំរឿនរបស់អ្នកស្ថិតនៅក្នុងក្រុងមិនមែននៅក្នុងខេត្តនោះត្រូវគូសខេត្តចេញ ។ល។ ពត៌មានកត់ចូលទាំងនោះជា "ពត៌មានសំគាល់ដ៏សំខាន់ " នៅពេលក្រោយ ហេតុនេះត្រូវបំពេញដោយប្រុងប្រយ័ត្ន ។ នេះជាវិធីសាស្ត្រដែលភូមិនិមួយៗត្រូវបានដាក់លេខកូដសំរាប់សំគាល់នៅក្នុងឃុំ / សង្កាត់ ណាមួយនៅក្នុង ស្រុក / ខ័ណ្ឌនិមួយៗរបស់ខេត្ត / ក្រុង ដោយប្រជុំលេខកូដ ។ សំរាប់គោលបំណងនេះ អង្គភាពនិមួយៗត្រូវមានលេខកូដរបស់ខ្លួន ។ អ្នកត្រួតពិនិត្យត្រូវចង្អុលប្រាប់ដល់អ្នកសំភាសន៍របស់ខ្លួនពីលេខកូដត្រូវប្រើប្រាស់ ។ អ្នកសំភាសន៍ត្រូវចុះលេខកូដទាំងនេះនៅតាមកន្លែងលៃទុកដោយមានឈ្មោះអង្គភាពនៃមណ្ឌលសំភាសន៍និមួយៗ ។ ការបំពេញនៅក្នុងពត៌មានសំគាល់ក្នុងតារាងលាតនានា គួរតែធ្វើមុនការចាប់ផ្តើមចុះបញ្ជីផ្ទះ អ្នកនឹងបានចំណេញពេលក្នុងដំណាក់កាលធ្វើការចុះបញ្ជីផ្ទះនោះ ។

## បង្គោល 1: លេខរៀងបន្ទាត់

31. អ្នកសំភាសន៍ត្រូវចុះលេខរៀងតាមបន្ទាត់និមួយៗនៅក្នុងតារាងបញ្ជីផ្ទះ ។ លេខរៀងបន្ទាត់ទាំងនេះ គឺជាលេខតៗគ្នាសំរាប់តែមួយមណ្ឌលជំរឿន ។ ដើម្បីស្រួលយល់ លេខរៀង 1,2,3,4....9 និង 0 បានបោះពុម្ពស្រេចនៅក្នុងបង្គោលនេះ ។ នៅក្នុងទំព័រទី បន្ទាត់ក្រោមបំផុតអាចមាន 10ដោយសរសេរ

លេខ ។ ពីមុខលេខ 0 ។ ក្នុងទំព័រទី 2 អ្នកសំភាសន៍អាចសរសេរលេខ ។ ថែមដើម្បីបង្កើតបន្ទាត់ 11 ដោយសរសេរលេខ ។ ពីមុខលេខ ។ លេខ ។ នៅមុខលេខ 2 អាចធ្វើជាលេខ 12 ។ល។ និង ។ល។ លេខចុងក្រោយគេបំផុតនៃទំព័រ 2 អាចជាលេខ 20 ។ វិធីសាស្ត្រនេះអាចធ្វើបន្តរហូតដល់ចប់មណ្ឌលជំរឿន ។

**បង្គោល 2: អគារ / សំណង់លេខ**

32 លេខដែលបានចុះសំគាល់លើផែនទីមណ្ឌលជំរឿនគឺមានសរសេរដោយពណ៌ ( ឬសរសេរលើផ្លាក ) នៅលើអគារដែលមានគ្រួសារមួយ ឬ ច្រើនរស់នៅ ហើយត្រូវមានចុះក្នុងបង្គោលនេះដោយគ្មានអក្សរ C (ឧទាហរណ៍ 001, 002, ។ល។ ) ពីមុខឡើយ ។

**បង្គោល 3 ដល់ 5: សំភារៈសំខាន់សំរាប់សាងសង់ អគារ / សំណង់**

33. សំណួរនេះត្រូវបែងចែកជា 3 ផ្នែក : ( ក ) សំភារៈធ្វើជញ្ជាំង ( ខ ) សំភារៈធ្វើដំបូល និង (គ) សំភារៈធ្វើកំរាល ។ ដើម្បីភាពងាយស្រួលដល់អ្នកសំភាសន៍ ការពណ៌នាអំពីប្រភេទសំភារៈសំខាន់និមួយៗ សំរាប់សាងសង់ ឧទាហរណ៍ ជញ្ជាំង ដំបូល និង កំរាល ត្រូវបានចុះសំគាល់នៅលើតារាងបញ្ជីខាងក្រោមនៃតារាងបញ្ជីផ្ទះ ។ លេខលំដាប់នៃក្រុមសំភារៈសំខាន់បានបង្ហាញជូនស្រេច ។ អ្វីដែលអ្នកត្រូវធ្វើនោះគឺសួរអំពីប្រភេទសំភារៈសំរាប់ការសាងសង់អគារ ហើយចុះទៅតាមលេខកូដជាបន្តបន្ទាប់ក្នុងបង្គោល 3 ដល់ 5 តាមលក្ខណៈប្រភេទសំភារៈនិមួយៗសំរាប់ធ្វើ ជញ្ជាំង ដំបូល កំរាល ។ អ្នកសំភាសន៍ត្រូវពិនិត្យសំភារៈផ្ទាល់ភ្នែកផងដែរ ។

**បង្គោល 3: សំភារៈធ្វើជញ្ជាំង**

34. ចំពោះសំភារៈធ្វើជញ្ជាំងនោះបានផ្តល់លេខកូដចំនួន 8 លេខដូចមានចុះក្នុងតារាងស្រាប់ ។ ដើម្បី សន្និដ្ឋានប្រភេទសំភារៈសំរាប់ធ្វើ ជញ្ជាំង អគារ អ្នកសំភាសន៍ត្រូវជ្រើសរើសយកផ្នែកសំភារៈខាងក្រៅនៃជញ្ជាំងអគារដែលប្រើច្រើនជាងគេ រួចជ្រើសរើសលេខកូដតាមប្រភេទសំភារៈនោះដាក់អោយសមស្រប។ លេខកូដដែលបានជ្រើសរើសយកត្រូវចុះក្នុងបង្គោល 3 ។ ត្រូវចុះវដ្តសញ្ញា ( - ) ចំពោះសំណង់ដែលមានតែសសរគ្មានជញ្ជាំង ហើយក៏គ្មានសំណួរអំពីសំភារៈធ្វើជញ្ជាំង ក្នុងករណីបែបនេះ តែក៏ត្រូវមានបញ្ជាក់ក្នុងបង្គោលសេចក្តីផ្សេងៗអំពីប្រការនេះដែរ ។

34.1 ករណីសំភារៈធ្វើជញ្ជាំងជាប្រភេទផ្សេងទៀតក្រៅពីមានរាប់នៅក្នុងបញ្ជីពីលេខកូដ ។ ដល់ 7 នោះសរសេរលេខកូដ 8 ហើយចុះឈ្មោះសំភារៈនោះក្នុងបង្គោល 3 ឬ នៅក្នុងបង្គោលសេចក្តីផ្សេងៗ ។

## បង្គោល 4: សំភារៈធ្វើដំបូល

35. ចំពោះប្រភេទសំភារៈធ្វើដំបូលនៃអគារនោះបានផ្តល់លេខកូដចំនួន 8 លេខ ។ លេខកូដទាំងនោះដូចមានចុះនៅក្នុងតារាងស្រាប់ ។ ប្រសិនបើសំភារៈធ្វើដំបូលមានពីរ ឬច្រើនប្រភេទត្រូវកំណត់យកប្រភេទសំភារៈណាដែលមានភាគច្រើនជាកត្តាកំណត់ ។ ក្រោយពីកំណត់ច្បាស់លាស់នូវប្រភេទសំភារៈធ្វើដំបូលរួចហើយអ្នកសំភាសន៍ត្រូវដាក់លេខកូដស្របតាមប្រភេទសំភារៈនោះនៅក្នុងបង្គោល 4 ។ ករណីប្រភេទសំភារៈធ្វើដំបូលមិនស្ថិតក្នុងចំណោម លេខកូដដែលមានក្នុងបញ្ជីពីលេខកូដ 1ដល់ 7 នោះ អ្នកសំភាសន៍ត្រូវសរសេរលេខកូដ 8 ហើយចុះឈ្មោះសំភារៈក្នុងបង្គោល 4 ឬក្នុងបង្គោលសេចក្តីផ្សេងៗ ។

## បង្គោល 5: សំភារៈធ្វើកំរាល

36. ចំពោះសំភារៈធ្វើកំរាលនោះបានផ្តល់លេខកូដចំនួន 7 លេខដូចមានក្នុងតារាងស្រាប់ ។ ចំពោះប្រភេទសំភារៈធ្វើកំរាល អ្នកសំភាសន៍ត្រូវពិនិត្យយកសារជាថ្មីនូវប្រភេទសំភារៈដែលបានគ្របដណ្តប់លើផ្នែកដ៏ធំរបស់កំរាលនៃអគារ ។ ឧទាហរណ៍ បើក្នុងអគារមួយមានតែបន្ទប់ទទួលភ្ញៀវមួយដែលក្រាលឥដ្ឋក្បាច់ ហើយបន្ទប់ផ្សេងៗទៀត និងរបៀងចាក់ស៊ីម៉ងត៍នោះប្រភេទសំភារៈធ្វើកំរាលរបស់អគារនោះគឺត្រូវចុះថាធ្វើអំពីស៊ីម៉ងត៍ " ដោយប្រើលេខកូដ 3 " ។ បើអគារមួយមានកំរាលធ្វើអំពីឥដ្ឋការូនៅក្នុងបន្ទប់ទឹក ហើយបន្ទប់ទាំងអស់ផ្សេងៗទៀត មានកំរាលជាស៊ីម៉ងត៍នោះប្រភេទសំភារៈធ្វើកំរាលគឺស៊ីម៉ងត៍ ។

36.1 សូមបញ្ជាក់ថានៅពេលកត់ត្រាអំពីប្រភេទសំភារៈធ្វើជញ្ជាំង ដំបូល និង កំរាលនោះអ្នកសំភាសន៍ត្រូវចុះតែលេខកូដណាដែលជាតំណាងអោយប្រភេទសំភារៈនោះ ដូចដែលបានផ្តល់អោយ នៅតាមបង្គោលដែលពាក់ព័ន្ធដោយមិនត្រូវធ្វើការពណ៌នា លើកលែងតែប្រភេទសំភារៈផ្សេងទៀតដែលសូមឱ្យធ្វើការបញ្ជាក់។

## បង្គោល 6: គោលដៅក្នុងការប្រើប្រាស់អគារ/សំណង់

37 បើប្រើអគារមួយទាំងមូលសំរាប់គោលដៅលំនៅដ្ឋាននោះ សូមចុះលេខកូដ 1 ក្នុងបង្គោលនេះ ។ បើប្រើជាលំនៅដ្ឋានផង ជាហាងលក់ទំនិញផង សូមចុះលេខកូដ 2 ។ បើប្រើអគារជាលំនៅដ្ឋានផង ជារោងជាងផង សូមចុះលេខកូដ 3 ។ បើអគារបានប្រើជាលំនៅដ្ឋាននិងគ្រឹះស្ថាននានា សូមចុះលេខកូដ 4 ហើយមានបញ្ជាក់ឈ្មោះគ្រឹះស្ថាន ។ ឧទាហរណ៍ ចុះលេខកូដ 4 សំរាប់លំនៅដ្ឋាននិងសាលា, សំរាប់លំនៅដ្ឋាននិងការិយាល័យ ជាលំនៅដ្ឋាននិងធនាគារ ជាលំនៅដ្ឋាននិងវត្ត ។ល។ ក្នុងករណីនេះត្រូវសរសេរ 4 សាលា 4 ការិយាល័យ 4 ធនាគារ 4 វត្ត ។ល។

**ចំណុចសំខាន់**

38. បើអ្នកសំភាសន៍ទៅជួបនឹងផ្ទះទំនេរទាំងមូល ឧទាហរណ៍ គ្មានមនុស្សណាម្នាក់រស់នៅក្នុងអគារនោះ នៅពេលដែលធ្វើបញ្ជីផ្ទះពុំត្រូវបានប្រើក្នុងគោលបំណងណាមួយនោះ ។ ត្រូវសរសេរសំគាល់នៅលើផែនទីជំរឿន ហើយចុះលេខរៀង ។ ក្នុងករណីនេះ ត្រូវសរសេរ "ផ្ទះទំនេរ" ពីលើប្រអប់សំគាល់ក្នុងផែនទីជំរឿនសំរាប់អគារនេះ ។ ក្នុងតារាង ក មានចុះតែក្នុង បង្គោល 1, 2 និង 13 ប៉ុណ្ណោះដែលត្រូវបំពេញសំរាប់ផ្ទះទំនេរ ហើយទុកបង្គោលផ្សេងទៀតឱ្យនៅទំនេរ ។ ក្នុងបង្គោល 1 ត្រូវកត់ចូលលេខរៀងបន្ទាត់ និងក្នុងបង្គោល 2 ត្រូវកត់ចូលលេខអគារសំរាប់ផ្ទះទំនេរ ។ នៅក្នុងបង្គោលសេចក្តីផ្សេងៗ (បង្គោល 13) សូមសរសេរពាក្យ "ផ្ទះទំនេរ" ។ បើសិនអ្នកសំភាសន៍ជួបនឹងលំនៅដ្ឋានទាំងមូល ឬជាផ្នែកជាផ្ទះចាក់សោរ ព្រោះអ្នកម្ចាស់ផ្ទះនោះធ្វើដំណើរទៅឆ្ងាយ អ្នកសំភាសន៍មិនត្រូវចាត់ទុកថាជា "ផ្ទះទំនេរ" ទេ ។ ករណីនេះ អ្នកសំភាសន៍ត្រូវចុះលេខអគាររួចត្រូវបំពេញបង្គោល 1, 2 និង 13 នៃតារាង ក ហើយទុកបង្គោលផ្សេងទៀតឱ្យនៅទំនេរ ។ ដោយហេតុថា ម្ចាស់ផ្ទះមិននៅ អ្នកសំភាសន៍ត្រូវចុះក្នុង បង្គោលសេចក្តីផ្សេងៗថា "ផ្ទះចាក់សោរម្ចាស់ផ្ទះមិននៅ" ។

**បង្គោល 7: គ្រួសារលេខ**

39. ដូចបានឱ្យនិយមន័យរួចមកហើយថា "គ្រួសារ" គឺជាក្រុមមនុស្សដែលរស់នៅជាមួយគ្នា ហើយបរិភោគបាយដែលចេញពីចង្ក្រានរួម លើកលែងតែអ្នកណាមួយដែលត្រូវការក្នុងការងារដែលបង្ខំឱ្យ អ្នកនោះមិនបានមកបរិភោគបាយ ឬស្នាក់អាស្រ័យជាមួយ ។ គ្រួសារអាចជាក្រុមជនដែលមានជាប់ជាសាច់ញាតិមិនមានជាប់ជាសាច់ញាតិ ឬជាប់សាច់ញាតិផង និងមិនជាប់សាច់ញាតិផង ។ ចុងភៅម្នាក់ ឬអ្នកបំរើម្នាក់ដែលរស់នៅក្នុងផ្ទះនិយោជករបស់ខ្លួន ហើយហូបអាហារនៅទីនោះក៏រាប់ថាជាសមាជិកនៃគ្រួសារនោះដែរ ។ អន្តេវាសិកដ្ឋានមួយដែលមានមនុស្សមួយចំនួនមិនជាប់សាច់ញាតិគ្នាមករស់នៅជាមួយគ្នានោះគឺជាគ្រួសារស្ថាប័ន ប្រសិនបើមានផ្ទះបាយរួម ។ ពន្ធនាគារ ក៏ដូចគ្នាដែរ ។

40. ត្រូវមានលេខគ្រួសារនៅក្នុងបង្គោល 7 ព្រោះអ្នកសំភាសន៍បានចុះក្នុងបង្គោល 6 នូវអគារដែលប្រើជាលំនៅដ្ឋានពេញលេញ ឬជាផ្នែកៗ ។

41. អាចមានលើសពីមួយគ្រួសារ ដែលស្នាក់នៅក្នុងអគារមួយដូចបានបញ្ជាក់ខាងដើមស្រាប់ ។ គ្រួសារនីមួយៗ ដែលនៅក្នុងអគារមួយរួមគ្នានោះ ត្រូវចុះលេខផ្សេងពីគ្នា (01,02....។ល។) អ្នកសំភាសន៍ត្រូវមានគំនិតពីការចុះលេខរៀងអគារ និងលេខរៀងគ្រួសារ ដែលនៅក្នុងអគារនោះដូចតទៅ :

| | ពត៌មានសំគាល់ | អគារ / សំណង់លេខ | គ្រួសារលេខ |
|---|---|---|---|
| 1 | អគារលេខ 009 មានគ្រួសារ 1 | 009 | 01 |
| 2 | អគារលេខ 009 មានគ្រួសារ 2 | 009 | 01 |
| | | – | 02 |
| 3 | អគារលេខ 009 មានគ្រួសារ 3 | 009 | 01 |
| | | – | 02 |
| | | – | 03 |

*បើសិនអគារមួយមានគ្រួសារច្រើនលើសពី 1 គ្រួសារកំពុងស្នាក់នៅនោះ លេខអគារមិនត្រូវចុះដដែលៗនៅបន្ទាត់ខាងក្រោមក្នុងបង្គោល 2 ទេ ( សូមមើលឧទាហរណ៍ខាងលើ ) ។ ចំពោះប្រភេទសំភារៈសំខាន់ៗសំរាប់សាងសង់អគារ (បង្គោល 3 ដល់ 5 ) ហើយគោលដៅនៃការប្រើប្រាស់អគារ ( បង្គោល 6 ) ក៏មិនចាំបាច់បំពេញដដែលៗក្នុងបន្ទាត់ខាងក្រោម ពេលណាពត៌មាននេះបានចុះស្រេចសំរាប់គ្រួសារទី1 នៃអគារនោះរួចហើយ ។*

## បង្គោល ៨ និង ៩ : ពត៌មានអំពីលក្ខណៈនៃមេគ្រួសារ

42. បង្គោល ៨ និង ៩ ប្រើសំរាប់បំពេញតែពត៌មានរបស់មេគ្រួសារ ។ អ្នកសំភាសន៍ត្រូវសរសេរនាមត្រកូលនិងនាមខ្លួន និងភេទរបស់មេគ្រួសារ ។

## និយមន័យនៃមេគ្រួសារ

43. ចំពោះគោលបំណងនៃការធ្វើជំរឿន មេគ្រួសារគឺជាមនុស្សម្នាក់ដែលសមាជិកគ្រួសារទទួលស្គាល់ថាជាមេនៅក្នុងគ្រួសារ ។ ជាទូទៅគាត់ គឺជាមនុស្សដែលទទួលខុសត្រូវចាត់ចែងក្នុងគ្រួសារ ហើយធ្វើសេចក្ដីសំរេចនានាក្នុងនាមគ្រួសារ ។ មេគ្រួសារ មិនមែនចាំបាច់តែសមាជិកប្រុសដែលមានចំណាស់ជាងគេក្នុងគ្រួសារទេ ពោលគឺអាចជាសមាជិកស្ត្រី ឬសមាជិកក្មេងនៃភេទទាំងពីរ ។ អ្នកសំភាសន៍ មិនត្រូវពណ៌នាអំពីហេតុផលណាមួយអំពីមនុស្សនោះទេ តែសូមចុះតែនាមត្រកូល និងនាមខ្លួនរបស់មនុស្សនោះដែលសមាជិកគ្រួសារ គេបានទទួលស្គាល់ថាជាមេគ្រួសាររបស់ខ្លួន ។ ករណីមេគ្រួសារពិតប្រាកដមិននៅផ្ទះនៅពេលដែលធ្វើបញ្ជីផ្ទះនោះ មនុស្សដែលទទួលខុសត្រូវបន្តក្នុងការចាត់ចែងការងារក្នុងគ្រួសារ ដែលអ្នកសំភាសន៍បានជួបនៅពេលធ្វើការចុះបញ្ជីផ្ទះក៏អាចចាត់ជាមេគ្រួសារបានដែរ ។

**បង្គោល 8: នាមត្រកូល និង នាមខ្លួន**

44. នាមត្រកូល និង នាមខ្លួនរបស់មេគ្រួសារនៃគ្រួសារនិមួយៗត្រូវសរសេរក្នុងបង្គោលនេះ ។ ករណីគ្រួសារជាគ្រួសារស្ថាប័ន ដូចជា: អន្តេវាសិកដ្ឋាន សណ្ឋាគារ វត្តអារាម ពន្ធនាគារ ។ល។ នៅទីនោះមេគ្រួសារស្ថាប័នអាចស្គាល់បានដោយការតែងតាំងដូចជា អ្នកទទួលខុសត្រូវក្នុងអន្តេវាសិកដ្ឋាន ប្រធានគុក លោកគ្រូចៅអធិការ អ្នកគ្រប់គ្រង ។ល។ អ្នកសំភាសន៍ត្រូវចុះមេគ្រួសារស្ថាប័នតាមឋានៈតែងតាំងរបស់គេនៅក្នុងបង្គោលនេះ ក្រោយពីបានសរសេរឈ្មោះគ្រឹះស្ថាន ។ បើគ្មានឋានៈបែបនេះទេ សូមសរសេរនាមត្រកូល និងនាមខ្លួនដែលគេទទួលស្គាល់ថាជាមេនៃស្ថាប័ន ។

45. *ករណីគ្រួសារស្ថាប័នសូមសរសេរអក្សរ " ស " នៅក្នុងវង់ក្រចកនៅក្រោយនាមត្រកូល និង នាមខ្លួន ឬនាមតែងតាំងនៃមេគ្រួសារនៅក្នុងបង្គោលនេះ។ ឧទាហរណ៍ ក្នុងលេខ ( II ) សាលារៀនអន្តេវាសិកដ្ឋាន អ្នកគ្រប់គ្រង ( ស ) លោក ស្រី រដ្ឋា ( ស ) ។ សូមសរសេរថា " គ្រួសារស្ថាប័ន " នៅក្នុងបង្គោលសេចក្តីផ្សេងៗ ។*

**បង្គោល 9: ភេទ (1 : ប្រុស, 2 : ស្រី )**

46. បើមេគ្រួសារជាភេទប្រុស សរសេរលេខ 1 ។ បើមេគ្រួសារជាភេទស្រីសរសេរលេខ 2 នៅក្នុងបង្គោលនេះ ។ ចំពោះមនុស្សគ្រៀវ និង មនុស្សខ្ទើយអ្នកសំភាសន៍ត្រូវសរសេរលេខ 1 ក្នុងបង្គោលនេះ ។

**បង្គោល 10 ដល់ 12: ចំនួនមនុស្សពិតប្រាកដដែលរស់នៅជាប្រចាំក្នុងគ្រួសារ**

47. សូមកត់ចូលចំនួនមនុស្សប្រុសពិតប្រាកដដែលរស់នៅក្នុងគ្រួសារ ក្នុងបង្គោល 10 ចំនួនមនុស្សស្រីពិតប្រាកដក្នុងបង្គោល 11 និងចំនួនមនុស្សសរុបក្នុងបង្គោល 12 ( ចំនួនសរុបក្នុងបង្គោល 10 និងក្នុងបង្គោល 11) ។ សូមកត់សំគាល់ថា ដើម្បីគោលបំណងអោយតួលេខទាំងនេះមានភាពប្រាកដប្រជានោះត្រូវមានគំនិតផ្តោតជាចំបងលើចំនួនអ្នកស្នាក់នៅពិតប្រាកដក្នុងគ្រួសារ ។ ភ្ញៀវដែលមកលេងម្តងម្កាលត្រូវដកចេញដោយចាត់ទុកថា គេទាំងនោះមានលំនៅដ្ឋានស្នាក់នៅជាធម្មតារៀងៗខ្លួនរបស់គេ ។ ក៏ប៉ុន្តែមនុស្សនានាដែលបានមកអាស្រ័យនៅជាមួយនិងគ្រួសារ ដូចជា ជំនួយគ្រួសារ ភ្ញៀវឬអ្នកមកលេងកំពុងរស់នៅនិងហូបបាយជាមួយគ្រួសារក្នុងរយៈពេលពី 6 ខែឡើងទៅនោះ ត្រូវរាប់ចូលជាសមាជិកគ្រួសារឬបើសិនពួកគេគ្មានទីកន្លែងស្នាក់នៅផ្សេងទៀត ។ ទាក់ទងទៅនឹងបញ្ហានេះជាធម្មតាអ្នកស្នាក់នៅដែលអវត្តមានពីកន្លែងដែលធ្លាប់ស្នាក់នៅធម្មតាពី 6 ខែឡើងទៅនោះ ត្រូវដកចេញពីគ្រួសារដែលនៅក្នុងនោះគេធ្លាប់ស្នាក់នៅជាធម្មតា ។

47.1 *ក្រោយពីធ្វើការកត់តួលេខនានាចូលក្នុងបង្គោលទាំងបីនេះរួចហើយ អ្នកសំភាសន៍ត្រូវត្រួតពិនិត្យតាមរបៀបលេខគណិត ថាតើចំនួនបុរសនៅក្នុងបង្គោល 10 បូកនិងចំនួនស្ត្រីក្នុងបង្គោល 11 ស្មើនឹងចំនួនមនុស្សសរុបនៅក្នុងបង្គោល 12 ដែរឬទេ ។*

## បង្គោល 13: សេចក្តីផ្សេងៗ

48. បង្គោលនេះបានផ្តល់ចន្លោះសំរាប់ចុះពត៌មានដែលមានសារៈប្រយោជន៍អំពីពត៌មានណាមួយពីអគារ ឬគ្រួសារ ។ ដូចបានអធិប្បាយក្នុងសេចក្តីណែនាំទាំងឡាយសំរាប់បំពេញបង្គោល 8 ដោយត្រូវសរសេរ "គ្រួសារស្ថាប័ន " ចំពោះករណីនៃគ្រួសារបែបនេះ ។ បើអគារនៅទំនេរសូមសរសេរ ( ផ្ទះទំនេរ ) ត្រង់កន្លែងនេះដូចបានណែនាំរួច ។ បើអគារបានចាក់សោរហើយអ្នកកាន់កាប់បានធ្វើដំណើរទៅក្រៅនោះ អ្នកត្រូវកត់ត្រាបញ្ហានេះ នៅក្នុងបង្គោលសេចក្តីផ្សេងៗ ដូចបានពណ៌នារួចមកហើយ ។ ចន្លោះនេះត្រូវប្រើអោយបានសមរម្យសំរាប់ពន្យល់លេខកូដ 8 ក្នុងបង្គោល 3 និងបង្គោល 4 ឬលេខកូដ 7 នៅក្នុងបង្គោល 5 ប្រសិនចាំបាច់ ។

## ពត៌មានទូទៅ

49. ទំព័រនិមួយៗនៃបញ្ជីផ្ទះនៅតាមមណ្ឌលជំរឿន ត្រូវចុះជាលេខរៀងតៗគ្នា ដូចជា 1,2,3...។ល។ លេខទំព័រត្រូវចុះនៅត្រង់កន្លែងចន្លោះ ដែលទុកនៅក្បាលទំព័រខាងស្តាំដៃនៃបញ្ជីផ្ទះ ។ សំរាប់មណ្ឌលជំរឿនមួយនៅលើទំព័រនិមួយៗនៃបញ្ជីផ្ទះ ចំនួនទំព័រសរុបដែលបានប្រើក្នុងមណ្ឌលជំរឿននោះ ត្រូវចុះក្នុងចន្លោះដែលបានផ្តល់អោយត្រង់ក្បាលទំព័រនៅខាងស្តាំដៃ ។

50. ក្នុងទំព័រនិមួយៗត្រូវ សរុបចំនួនគ្រួសារក្នុងបង្គោល 7 នៃបញ្ជីផ្ទះ ហើយសរសេរលេខសរុបនោះនៅក្នុងប្រអប់ខាងក្រោមបង្គោលនេះ ។ ត្រូវសរុបតួលេខបុរស ស្ត្រី និងចំនួនមនុស្សនៅក្នុងបង្គោល 10,11, និង 12 ហើយចុះលេខសរុបរួមនៅក្រោមទំព័រនិមួយៗ ។ នៅក្នុងតារាងក្នុងក្រដាសដាច់ដោយឡែកមួយឈ្មោះថា " សរុបសង្ខេបបញ្ជីផ្ទះ " ( តារាង 1) ( តារាងគំរូដាក់ជូន ក្នុងឧបសម្ព័ន ឃ ) នោះអ្នកសំភាសន៍ត្រូវចំលងលេខសរុបនៃទំព័រនិមួយៗ ក្នុងបង្គោលទាំងពីរនោះ ដាក់ចូលធ្វើជាលេខសរុបរួមទាំងអស់របស់មណ្ឌលជំរឿន ។

50.1 ជាការសំខាន់ណាស់ ដែលត្រូវពិនិត្យមើលថា តួលេខដែលបានកត់ចូលនៅក្នុងតារាងសរុបសង្ខេបបញ្ជីផ្ទះនោះ បានត្រឹមត្រូវតាមលេខគណិតឬទេ ។ ផលបូកចំនួនមនុស្សប្រុសសរុបក្នុងបង្គោល 3 និង ចំនួន

មនុស្សស្រីសរុបក្នុងបង្គោល 4 ត្រូវស្មើនឹងចំនួនមនុស្សសរុបក្នុងបង្គោល 5 ។ ផលបូកទាំងនេះ ត្រូវបាន ពិនិត្យឡើងវិញមួយបន្ទាត់ម្តងៗ រួចហើយសរុបបន្ទាត់នៃតារាងសរុបសង្ខេបបញ្ជីផ្ទះ ។

51. អ្នកសំភាសន៍ត្រូវសរសេរឈ្មោះរបស់ខ្លួន ហើយចុះហត្ថលេខាលើគ្រប់ទំព័រនៃតារាងបញ្ជីផ្ទះ និងត្រូវចុះ ថ្ងៃ ខែ ឆ្នាំផងដែរត្រង់ចន្លោះដែលបានទុកអោយ ។

# ជំពូក III

# ការបំពេញតារាង ខ តារាងសំណួរតាមគ្រួសារ

## ការណែនាំទូទៅ

52. តារាង ខ តារាងសំណួរតាមគ្រួសារ នឹងត្រូវប្រើក្នុងការសំភាសន៍ជាមួយគ្រួសារទាំងអស់នៅក្នុងមណ្ឌលជំរឿនរបស់អ្នក ។ អ្នកសំភាសន៍ត្រូវយកតារាង ក ទៅជាមួយខ្លួនដើម្បីងាយស្រួលក្នុងការទៅរកគ្រួសារនិមួយៗ ហើយធ្វើសំភាសន៍យកពត៌មានដាក់ក្នុងតារាង ខ ។

## ពេលវេលាកំណត់គឺអធ្រាត្រ (00ម៉ោង) ថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998

53. ពេលវេលាកំណត់សំរាប់ធ្វើជំរឿននេះគឺអធ្រាត្រថ្ងៃអង្គារ ទី 03 ខែមិនា ឆ្នាំ 1998 ។ នេះមានន័យថាក្នុងមណ្ឌលជំរឿននោះ ជំរឿនត្រូវផ្តល់នូវការថតមួយព្រិបនៃប្រជារាស្ត្រនៅក្នុងគ្រួសារនានា នៅអធ្រាត្រថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998 ឬ 00ម៉ោង ថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998 ។ តាមន័យម្យ៉ាងទៀត ការរាប់ប្រជារាស្ត្រត្រូវទាក់ទងទៅនឹងពេលវេលាកំណត់នេះ ។ ដូចបានដឹងស្រាប់ គេមិនអាចធ្វើការសំភាសន៍ប្រមូលយកពត៌មានលំអិតបានទាំងអស់ពីមនុស្សគ្រប់រូបនៅចំណុចពេលដែលបានកំណត់ទុកនេះឡើយ។ ហេតុនេះការសំភាសន៍យកពត៌មាន មានរយៈពេលរហូតដល់ 10ថ្ងៃដោយចាប់ផ្តើមពីថ្ងៃទី 03 ខែមិនា ឆ្នាំ 1998 ហើយបញ្ចប់ នៅថ្ងៃទី 12 ខែ មិនា ឆ្នាំ 1998 ។ ក្នុងកំឡុង 10 ថ្ងៃនេះគេត្រូវប្រមូលពត៌មាននៃ មនុស្សវត្តមាននៅក្នុងគ្រួសារនៅអធ្រាត្រថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998 ( ឈ្មោះថាយប់ធ្វើជំរឿន) ។ ហេតុនេះ ការសំភាសន៍ប្រមូលយកពត៌មានទូទាំងប្រទេសត្រូវទាក់ទងនឹងពេលវេលាកំណត់នេះ ។ *សូមកត់សំគាល់ថាមានតែមនុស្សមានជីវិតនៅក្នុងគ្រួសារនៅពេលអធ្រាត្រ (ឬ 00ម៉ោង ) នៃថ្ងៃនេះទេដែលត្រូវធ្វើជំរឿន ។ សូមចងចាំថាសំណួរទាំងអស់ដែលអ្នកសំភាសន៍ចោទសួរត្រូវទាក់ទងនិងពេលយប់ធ្វើជំរឿន លើកលែងតែអ្នកសំភាសន៍បានទទួលការណែនាំពិសេសផ្សេងទៀតនៅក្នុងអត្ថបទណែនាំនេះ ( ឧទាហរណ៍ សំណួរពីលក្ខណៈសេដ្ឋកិច្ច )* ។ សូមកត់សំគាល់ផងដែរថា ចំពោះការធ្វើបញ្ជីផ្ទះ គេមិនបានកំណត់ពេលវេលាកំណត់បែបនេះទេ ព្រោះថាវាគ្រាន់តែជាការអង្កេតនាំមុខជាទូទៅមួយប៉ុណ្ណោះ ។ ក៏ប៉ុន្តែចំពោះការធ្វើជំរឿន ( នៅពេលដែលយកតារាង ខ ជាតារាងសំណួរតាមគ្រួសារដែលត្រូវយកមកប្រើ ) នោះពេលវេលាកំណត់ត្រូវសន្មតយកហើយរំពឹងថាជំរឿនអាចផ្តល់តួលេខប្រជារាស្ត្រនៅពេលវេលាកំណត់នោះ ។

**កំណត់សំគាល់សំខាន់ៗ**

54. តារាង ខ ត្រូវបានបំពេញសំរាប់គ្រួសារទាំងអស់នៅក្នុងមណ្ឌលជំរឿនរបស់អ្នក ។ គ្រួសារទាំងអស់គឺរួមមានទាំងគ្រួសារធម្មតាឬគ្រួសារប្រក្រតី គ្រួសារស្ថាប័ន និង គ្រួសារគ្មានផ្ទះសំបែង មនុស្សរស់នៅលើទូក-កាណូត ឬនាវា និងមនុស្សឆ្លងកាត់ ។ តារាង ក នឹងជួយដល់អ្នកសំភាសន៍ក្នុងការសំគាល់ពីគ្រួសារធម្មតា និង គ្រួសារស្ថាប័ននិមួយៗ ។

54.1 អ្នកសំភាសន៍អាចជួបប្រទះនិងគ្រួសារថ្មីមួយឬច្រើនដែលគ្មានក្នុងតារាង ក និងអាចឃើញអគារដែលមិនបានចុះបញ្ជីក្នុងតារាង ក ក្នុងកំឡុងពេលធ្វើបញ្ជីផ្ទះ ដោយមកពីភ្លេចនៅក្នុងកំឡុងពេលធ្វើបញ្ជីផ្ទះ ដោយអគារនោះទើបសង់រួចក្រោយការចុះបញ្ជីផ្ទះ ។ នៅក្នុងស្ថានភាពនិមួយៗនៃចំណោមស្ថានភាពទាំងនេះអ្នកសំភាសន៍ត្រូវរាប់គ្រួសារថ្មីនោះ ឬគ្រួសារទាំងឡាយថ្មីនោះថែមសំរាប់បំពេញតារាង ខ តារាងសំណួរតាមគ្រួសារ ។ អ្នកសំភាសន៍ត្រូវចងចាំថា គោលការណ៍មូលដ្ឋាននៃជំរឿន គឺមនុស្សទាំងអស់វត្តមាននៅក្នុងគ្រួសារទាំងអស់នៅក្នុងមណ្ឌលជំរឿនរបស់ខ្លួនត្រូវរាប់ដោយគ្មានភ្លេចឬរាប់ផ្ទួនឡើយ ។

54.2 មុននឹងធ្វើសំភាសន៍គ្រួសារថ្មីនីមួយៗដូចបានចែងក្នុងវគ្គមុនខាងលើ អ្នកសំភាសន៍ត្រូវកែតំរូវតារាង ក បញ្ជីផ្ទះឱ្យទាន់សម័យកាលជាមុនសិន ។ ការងារតាមករណីនេះត្រូវធ្វើដោយរាប់បញ្ចូលទាំងមានដាក់លេខអគារ លេខគ្រួសារ និងពត៌មានផ្សេងៗទៀត ដោយបញ្ជាក់បន្ថែមថា " គ្រួសារបន្ថែមដែលបានសំគាល់ក្នុងពេលធ្វើសំភាសន៍ " នៅទីបញ្ចប់នៃតារាង ក ពោលគឺគ្មានធ្វើឱ្យរំខានដល់លេខរៀងបន្ទាត់ដែលមានស្រាប់ ។ បញ្ហានេះនឹង អធិប្បាយជូនជាលំអិតនៅក្នុងឧបសម្ព័ន្ធ ង ។

54.3 អគារដែលចាក់សោរនៅក្នុងកំឡុងពេលចុះបញ្ជីផ្ទះនោះ អាចមិនចាក់សោរនៅពេលធ្វើសំភាសន៍ជំរឿន ។ អ្នកសំភាសន៍ត្រូវសំភាសន៍គ្រួសារថ្មីនេះនៅក្នុងអគារនោះ ។ ក្នុងករណីនេះ អ្នកសំភាសន៍ត្រូវកែតំរូវតារាង ក ឱ្យទាន់សម័យកាលដូចតទៅ : បើសិនមានតែមួយគ្រួសារ នៅក្នុងអគារមួយបែបនេះ អ្នកសំភាសន៍ត្រូវបំពេញក្នុងបង្គោល 3 ដល់ 12 ត្រង់បន្ទាត់ដែលលេខអគារបានចុះរួចស្រេច ។ ចំពោះការងារនេះ អ្នកសំភាសន៍បានបំពេញក្នុងតារាង ក ត្រង់បង្គោល 1 ដល់ 2 និង 13 រួចស្រេចនៅក្នុងកំឡុងពេលចុះបញ្ជីផ្ទះ ។ បើសិននៅក្នុងអគារនោះមានគ្រួសារថ្មីច្រើនជាងមួយគ្រួសារនោះ អ្នកសំភាសន៍ត្រូវបំពេញនៅទីបញ្ចប់នៃតារាង ក នូវពត៌មានរបស់គ្រួសារទី 2 គ្រួសារទី 3 ។ល។ ដូចបានធ្វើរួចមកស្រាប់ក្នុងករណីគ្រួសារបន្ថែម ដែលអ្នកសំភាសន៍បានជួបប្រទះនៅក្នុងអគារនានា ដែលបានចុះបញ្ជីរួចហើយ ។ អ្នកសំភាសន៍អាចលុបពាក្យ " ផ្ទះចាក់សោរម្ចាស់ចេញធ្វើដំណើរ " ដែលបានចុះពីមុនក្នុងបង្គោលសេចក្តីផ្សេងៗ ( បង្គោល 3 ) ត្រង់លេខអគារនេះចេញបាន ។

54.4 អគារមួយដែលនៅទំនេរនៅក្នុងកំឡុងពេលចុះបញ្ជីផ្ទះអាចមិនទំនេរនៅពេលធ្វើជំរឿន ។ អ្នកសំភាសន៍ត្រូវធ្វើសំភាសន៍គ្រួសារបែបនេះផងដែរនៅក្នុងអគារនោះ ។ ក្នុងករណីនេះ អ្នកសំភាសន៍ត្រូវកែតំរូវតារាង ក ឱ្យទាន់សម័យកាលដូចតទៅ : បើសិនមានតែមួយគ្រួសារស្នាក់នៅក្នុងអគារមួយបែបនេះ អ្នកសំភាសន៍ត្រូវបំពេញក្នុងបង្គោល 3 ដល់ 12 ត្រង់បន្ទាត់ ដែលលេខអគារនោះបានចុះរួចស្រេច ។ ចំពោះអគារនោះ អ្នកសំភាសន៍បានបំពេញក្នុងតារាង ក ត្រង់បង្គោល 1 ដល់ 2 និង 13 រួចស្រេចនៅក្នុងអំឡុងពេលចុះបញ្ជីផ្ទះ ។ បើសិននៅក្នុងអគារនោះមានគ្រួសារថ្មីច្រើនជាងមួយគ្រួសារនោះ អ្នកសំភាសន៍ត្រូវបំពេញនៅចុងបញ្ចប់នៃតារាង ក នូវពត៌មានរបស់គ្រួសារទី 2 គ្រួសារទី 3 ។ល។ ដូចដែលបានធ្វើរួចមក ក្នុងករណីគ្រួសារបន្ថែមដែលអ្នកសំភាសន៍បានជួបប្រទះនៅក្នុងអគារនានាដែលបានចុះបញ្ជីរួចស្រេច ។ អ្នកសំភាសន៍អាចលុបពាក្យ " ផ្ទះទំនេរ " ដែលបានចុះបញ្ជីពីពេលមុន ក្នុងបង្គោលសេចក្តីផ្សេងៗ ( បង្គោល 13 ) ត្រង់លេខអគារនេះចេញបាន ។

54.5 *នៅក្នុងអំឡុងជំណាក់កាលធ្វើសំភាសន៍ទាក់ទងដូចបានពន្យល់ក្នុងវគ្គនានា ពី 54.2 ដល់ 54.4 អ្នកសំភាសន៍មិនត្រូវកែទំព័រសរុបនៃតារាង ក និងកំណត់ចូលនៃតារាងសង្ខេបបញ្ជីផ្ទះ សំរាប់បញ្ជីគ្រួសារបន្ថែមនានានៅក្នុងតារាង ក នោះទេ ។*

54.6 *សេចក្តីណែនាំសំរាប់ជំរឿនគ្រួសារធម្មតា សូមផ្តល់ជូនក្នុងជំពូកនេះ ចាប់ពីពេលនេះតទៅ ។ សេចក្តីណែនាំសំរាប់ជំរឿនគ្រួសារស្ថាប័នសូមផ្តល់ជូននៅជំពូក IV ។ សេចក្តីណែនាំសំរាប់ជំរឿនគ្រួសារគ្មានផ្ទះសំបែង និងប្រជាជនផ្លាស់ប្តូរទីកន្លែងញឹកញាប់តាមទូក កាណូត កប៉ាល់ និងផ្ទះទឹក នឹងផ្តល់ជូននៅក្នុងជំពូក V ។*

54.7 តាមដែលអាចធ្វើទៅបានរវាងយប់ធ្វើជំរឿននិងពេលវេលាធ្វើសំភាសន៍នោះសមាសភាពប្រជារាស្ត្រនៅក្នុងគ្រួសារខ្លះអាចមានប្តូរ ។ បើសិនជនណាម្នាក់ស្លាប់នៅក្រោយយប់ធ្វើជំរឿនអ្នកសំភាសន៍ត្រូវរាប់បញ្ចូលអ្នកនោះនៅក្នុងការរាប់ដូចមនុស្សនោះបានរស់នៅមានជីវិតក្នុងគ្រួសារនោះនៅយប់ធ្វើជំរឿន ។ បើសិនទារកមួយរូបបានកើតក្រោយយប់ធ្វើជំរឿន មិនបានកើតទាន់អធ្រាត្រថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998 អ្នកសំភាសន៍មិនត្រូវរាប់ទារកនោះទេ ។ បើសិនភ្ញៀវបានមកស្នាក់នៅចំពេលយប់ធ្វើជំរឿន នោះត្រូវរាប់បញ្ចូលភ្ញៀវនោះ ក្នុងគ្រួសារនោះ។

## លក្ខណៈសំគាល់គំរូតារាងសំណួរតាមគ្រួសារ

55. លក្ខណៈសំគាល់តារាង ខ តារាងសំណួរតាមគ្រួសារមានផ្តល់ជូនក្នុងឧបសម្ព័ន្ធ ប ។ តារាងនេះត្រូវប្រើសំរាប់ជំរឿនចំនួនមនុស្សនៅក្នុងគ្រួសារក្នុងមណ្ឌលជំរឿន ។ ការរាប់នេះនឹងត្រូវធ្វើនៅក្នុងជំហានទីពីរចាប់ផ្តើមពីថ្ងៃទី 03 ខែ មិនា ឆ្នាំ 1998 ។

## សេចក្តីណែនាំសំរាប់បំពេញតារាង ខ តារាងសំណួរតាមគ្រួសារ

## ផ្នែក 1: ពត៌មានសំគាល់ និងពត៌មានប្រជារាស្ត្រ

**ពត៌មានសំគាល់:**

56. អ្នកសំភាសន៍ត្រូវសរសេរឈ្មោះ និងលេខកូដ ខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ ឃុំ/សង្កាត់ និងភូមិ/មណ្ឌល ដូចអ្នកសំភាសន៍បានធ្វើស្រាប់សំរាប់តារាង ក តារាងបញ្ជីផ្ទះ ។ អ្នកសំភាសន៍ត្រូវបំពេញផងដែរលេខមណ្ឌលជំរឿនតាមបែបបទដដែល ។ អ្នកសំភាសន៍ត្រូវចំលងពីតារាង ក នូវលេខអគារ និងលេខគ្រួសារដាក់នៅផ្នែកលើតារាង ។ ការបំពេញក្នុងពត៌មានសំគាល់ក្នុងតារាងលាតនានា គួតែធ្វើ (លើកលែងតែលេខអគារ លេខគ្រួសារ និងឈ្មោះមេគ្រួសារ ) នៅមុនពេលអ្នកធ្វើការចាប់ផ្តើមធ្វើសំភាសន៍ អ្នកនឹងអាចចំណេញពេលក្នុងដំណាក់កាលធ្វើការសំភាសន៍នោះ ។

**ប្រភេទគ្រួសារ**

57. ចុះលេខកូដសមស្របនៅក្នុងប្រអប់ដែលបានផ្តល់ឱ្យ ។ ចំពោះគ្រួសារធម្មតា ចុះលេខកូដ 1 ។

**តើត្រូវធ្វើយ៉ាងដូចម្តេចនៅពេលត្រូវប្រើតារាងសំណួរតាមគ្រួសារពី ពីរ ឬច្រើនឡើងទៅសំរាប់គ្រួសារមួយ ?**

58. នៅតាមតារាងសំណួរនិមួយៗ គេអាចរាប់មនុស្សបាន 10 នាក់ តាមប្រការកំណត់មួយ ។ បើអ្នកសំភាសន៍បានរាប់មនុស្សលើសពី 10 នាក់ ក្នុងគ្រួសារមួយ អ្នកសំភាសន៍ត្រូវបន្តរាប់មនុស្សលើតារាងសំណួរថ្មីមួយទៀត ។ តារាងសំណួរថ្មីនេះ ជាតារាងតពីតារាងទី 1 ហើយត្រូវអនុវត្តដូចធ្វើក្នុងតារាងទី 1 ។ សូមចងចាំថា នៅពេលណាអ្នកប្រើតារាងសំណួរលើសពីមួយសំរាប់គ្រួសារណាមួយ អ្នកសំភាសន៍ត្រូវសរសេរគ្រួសារលេខ.... ( ត ) នៅលើក្បាលទំព័រខាងស្តាំដៃនៃទំព័រទី 1 សំរាប់តារាងសំណួរទី 2 និងតារាងសំណួរនានាបន្តទៀតផងដែរ ។ អ្នកសំភាសន៍ត្រូវបំពេញពត៌មានសំគាល់ក្នុងតារាងសំណួរតាមគ្រួសារបន្តផងដែរ ។ អ្នកសំភាសន៍ត្រូវសរសេរនៅក្នុងប្រអប់ ដែលបានផ្តល់ជូននៅក្រោមទំព័រខាងឆ្វេងនៃទំព័រទី 1 (ផ្នែក 1) សំរាប់តារាងសំណួរទី 1 នូវចំនួនសរុបតារាងសំណួរ ដែលបានប្រើសំរាប់គ្រួសារនោះ ។ អ្នកសំភាសន៍ត្រូវកឹបឬ ខ្ទាស់ជាមួយគ្នានូវតារាងសំណួរទាំងអស់ចំពោះគ្រួសារជំរឿននោះ ។

58.1 លេខរៀងនានាមានស្រាប់ក្នុងបង្គោល 1 នៃតារាងសំណួរ 1.1 និង 1.2 នៃផ្នែក 1 ហើយបង្គោល 1 នៃផ្នែក 2 ក៏មានលេខដូចជា 1,2,3...0 ។ លេខរៀងក្រោយបំផុតក្នុងទំព័រ 1 អាចធ្វើបានជាលេខរៀង 10 ដោយសរសេរលេខ 1 មុខ 0 សំរាប់មនុស្សទី 10 ។ នៅក្នុងតារាងសំណួរបន្តបន្ទាប់អ្នកសំភាសន៍អាចបន្តចុះលេខរៀងដោយដាក់លេខ 1 មុខចំនួនទាំងនោះដែលមានស្រាប់លើតារាងសំណួរទី 2 នេះដើម្បី

បង្កើតបានជាលេខទី 11,12,13... ។ល។ ចំពោះបន្ទាត់ចុងក្រោយអ្នកត្រូវសរសេរលេខ 2 មុខ 0 ដើម្បីធ្វើជាលេខ 20 ។ នៅពេលដែលអ្នកបានប្រើតារាងសំណួរទី 3 អ្នកសំភាសន៍ត្រូវសរសេរលេខ 2 មុខចំនួនដែលមានស្រាប់ដើម្បីបង្កើតជាលេខ 21,22, 23... ។ល។ និង ។ល។

## នាមត្រកូល និងនាមខ្លួននៃមេគ្រួសារ

59. មេគ្រួសារត្រូវបានកំណត់និយមន័យរួចមកហើយ ។ អ្នកសំភាសន៍ត្រូវរកឱ្យឃើញឈ្មោះរបស់មេគ្រួសារនៅតាមគ្រួសារលេខដែលពាក់ព័ន្ធក្នុងបង្គោល ៥ នៃតារាង ក : បញ្ជីផ្ទះ ។ អ្នកសំភាសន៍ត្រូវកត់ឈ្មោះនោះត្រង់ចំណុចនេះ ។ ប្រសិនបើមានការផ្លាស់ប្តូរនាមត្រកូល និងនាមខ្លួនមេគ្រួសារពីបញ្ជីផ្ទះ នោះត្រូវកត់ត្រាយកនាមត្រកូល និងនាមខ្លួនថ្មីនៅពេលសំភាសន៍ធ្វើជំរឿន ។

## ការបំពេញតារាងសំណួរត្រង់ 1.1,1.2 និង 1.3

60. ដើម្បីធ្វើការបំពេញតារាងទាំងនេះ សូមអានការណែនាំដោយយកចិត្តទុកដាក់ដូចតទៅ : គេអាចចែកសមាជិកពិតប្រាកដនៃគ្រួសារជាពីរប្រភេទ : ( i ) សមាជិកដែលបានដេកនៅក្នុងផ្ទះដែលកាន់កាប់ដោយគ្រួសារនៅយប់ធ្វើជំរឿន ឧទាហរណ៍ សមាជិកដែលវត្តមាននៅយប់ធ្វើជំរឿន និង ( ii ) សមាជិកដែលចេញឆ្ងាយពីផ្ទះ និងអវត្តមាននៅយប់ធ្វើជំរឿន។ *សូមកត់សំគាល់ថា មនុស្សដែលជាប់បំពេញភារៈកិច្ចនៅពេលយប់ (ឧទាហរណ៍ : វេជ្ជបណ្ឌិត គិលានុបដ្ឋយិកា នគរបាល អ្នកយាមឬឆ្មាំ ឆ្មាំពន្ធនាគារ ។ល។ ) ដែលតាមធម្មតាត្រូវមកដេកនៅក្នុងផ្ទះ តែដោយត្រូវទៅប្រចាំការទទួលភារកិច្ចពេលយប់នៅយប់ថ្ងៃធ្វើជំរឿននោះត្រូវចាត់ទុកដូចជាសមាជិកពិតប្រាកដវត្តមាននៅក្នុងគ្រួសារនៅយប់ធ្វើជំរឿនដែរ ។*

61. អ្នកមកលេង (ឧទាហរណ៍ : ភ្ញៀវរបស់សមាជិកណាម្នាក់នៃគ្រួសារ ) ដែលបានមកដេកនៅក្នុងផ្ទះនៅយប់ធ្វើជំរឿន ហៅថា ភ្ញៀវនៃគ្រួសារដែលវត្តមាននៅយប់ធ្វើជំរឿន ។

62. នៅក្នុងតារាងសំណួរ 1.1, 1.2, និង 1.3 នៃតារាង ខ ផ្នែក I អ្នកសំភាសន៍ត្រូវបំពេញជាបន្តបន្ទាប់នូវពត៌មានអំពីសមាជិកពិតប្រាកដនៃគ្រួសារដែលវត្តមាននៅយប់ធ្វើជំរឿន ភ្ញៀវរបស់គ្រួសារដែលវត្តមាននៅយប់ធ្វើជំរឿន និងសមាជិកពិតប្រាកដរបស់គ្រួសារដែលអវត្តមាននៅយប់ធ្វើជំរឿន ។

## កំណត់សំគាល់សំខាន់ៗ

63. អ្នកសំភាសន៍អាចប្រើតួលេខចំនួនមនុស្សស្នាក់នៅពិតប្រាកដ ដែលបានកត់ចូលក្នុងបង្គោល 10, 11, និង 12 នៃបញ្ជីផ្ទះសំរាប់ការណែនាំ និងការបញ្ជាក់បំភ្លឺបើមាន ។ក៏ប៉ុន្តែសូមចងចាំថាតាមធម្មតានិងជា

ទូទៅក្លូលេខទាំងនោះទាក់ទងទៅនឹងសមាជិកពិតប្រាកដនៃគ្រួសារ ។ អ្នកសំភាសន៍ត្រូវទៅជួបមេគ្រួសារឬសមាជិកទទួលខុសត្រូវណាម្នាក់នៃគ្រួសារ ដើម្បីទទួលពត៌មានសំរាប់បំពេញនៅក្នុងកម្រងតារាងសំណួរតាមការណែនាំដូចខាងក្រោម ។ អ្នកសំភាសន៍ ត្រូវរៀបចំពេលវេលាសំរាប់ធ្វើដំណើរទៅសំភាសន៍របស់ខ្លួនទៅកាន់គ្រួសារឱ្យបានល្អនៅក្នុងមណ្ឌលជំរឿនរបស់ខ្លួនតាមបែបបទមួយដែលអាចបានជួបជាមួយមេគ្រួសារឬសមាជិកទទួលខុសត្រូវណាម្នាក់នៃគ្រួសារនីមួយៗ ។ ជួនកាលអ្នកសំភាសន៍អាចឃើញថាសមាជិកទាំងអស់នៃគ្រួសារមួយចាក់សោរផ្ទះហើយចេញទៅក្រៅផ្ទះក្នុងរយៈពេល 2 ឬ 3 ម៉ោងដើម្បីទិញឥវ៉ាន់ ទៅធ្វើការទៅសិក្សា ។ល។ ក្នុងករណីបែបនេះ អ្នកសំភាសន៍ត្រូវទុកសំបុត្រសុំណាត់ជួបមួយសំរាប់គ្រួសារនោះដោយបញ្ជាក់ថាអ្នកនឹងមកកាន់គ្រួសារនេះដើម្បីធ្វើសំភាសន៍ ( តាមម៉ោង និងថ្ងៃខែ កំណត់ ) ហើយសំណូមពរឱ្យសមាជិកទាំងនោះនៅចាំតាមពេលកំណត់នោះ ។ ចំពោះគោលបំណងនេះ អ្នកសំភាសន៍អាចប្រើលិខិតសុំជួបសំភាសន៍ ( មើលឧបសម្ព័ន្ធ ជ ) ។

## តារាងសំណួរ 1.1 : សមាជិកពិតប្រាកដដែលវត្តមាននៅយប់ធ្វើជំរឿន

64. នៅក្នុងតារាងសំណួរនេះអ្នកសំភាសន៍ត្រូវកត់ចូលនូវសមាជិកពិតប្រាកដទាំងអស់របស់គ្រួសារដែលវត្តមាននៅយប់ធ្វើជំរឿន ។ ដំបូងអ្នកសំភាសន៍ត្រូវកត់នាមត្រកូល និងនាមខ្លួនរបស់មេគ្រួសារ (តាមនិយមន័យដែលបានផ្តល់ជូនខាងដើមក្នុងកថាខណ្ឌ 43 ជំពូក 2 ) ។ បើសិនជាមេគ្រួសារអវត្តមានក្នុងយប់ធ្វើជំរឿននោះ ត្រូវរកឱ្យបានអ្នកដែលទទួលខុសត្រូវម្នាក់ទៀតដែលមានវត្តមានក្នុងយប់ធ្វើជំរឿន ហើយកត់ឈ្មោះអ្នកនោះជាតំណាងឱ្យមេគ្រួសារ បើសិនមនុស្សនោះបានដេកក្នុងគ្រួសារនៅយប់ធ្វើជំរឿន ។

65. ក្នុងការកត់យកនាមត្រកូល និងនាមខ្លួននៅក្នុងតារាងសំណួរ 1.1 នោះជាការប្រសើរ បើសិនគេអនុវត្តតាមសេចក្តីណែនាំដូចតទៅនេះ ។ ក្រោយពីបានកត់យកនាមត្រកូលនិងនាមខ្លួន និងពត៌មានឯទៀតរបស់មេគ្រួសាររួចហើយ អ្នកសំភាសន៍ត្រូវកត់សាច់ញាតិជិតបំផុតដូចជាៈ ប្រពន្ធ ឬប្តីរបស់មេគ្រួសារ កូនប្រុស និងកូនស្រី ប្រពន្ធរបស់កូនប្រុសម្នាក់ៗនិងកូន ប្តីរបស់កូនស្រីម្នាក់ៗនិងកូន រួចសាច់ញាតិផ្សេងទៀតដូចជាៈ បងប្អូនប្រុស បងប្អូនស្រី ម្តាយ ឪពុក ។ល។ របស់មេគ្រួសារ រួចបន្តទៀតអ្នកបំរើក្នុងផ្ទះបើសិនជាមាន ។ល។ ប្រព័ន្ធចុះបញ្ជីបែបនេះនិងការកត់យកពត៌មានតាមវិធីនេះធានាដោយប្រាកដថាការរំលង ឬ ការភ្លេចនឹងត្រូវបានជៀសផុត ជាពិសេសចំពោះក្មេងៗតែម្តង ។ វានឹងជាជំនួយផងដែរក្នុងការពិនិត្យខ្វែងនៃរាល់ចម្លើយដែលទាក់ទងដល់អាយុ ។

66. *ការប្រុងប្រយត្ន័ជាមុន : អ្នកសំភាសន៍ត្រូវសួរសំណួរបញ្ជាក់ដែលទាក់ទងដល់សាច់ញាតិដូចជាបងប្អូនស្រីនៅលីវ ឪពុកម្តាយ អ្នកបំរើនៅក្នុងផ្ទះ និងកុមារ ។ ម៉្យាងទៀតមេគ្រួសារអាចមិនបាន*

*ប្រាប់ពីមនុស្សបែបនោះ ជាសមាជិកពិតប្រាកដនៃគ្រួសារវត្តមាននៅយប់ធ្វើជំរឿន ។ សូមសួរផងដែរអំពីទារក និងកុមារតូចៗ ព្រោះថាគេច្រើនតែរំលង ឬ ភ្លេចកត់បញ្ចូល ។*

**បង្គោល 1 : លេខរៀង**

67. លេខរៀងដែលផ្តល់ឱ្យសំរាប់ចុះលេខរៀងមនុស្សម្នាក់ៗដូចមានស្រាប់ ។

**បង្គោល 2 : នាមត្រកូលនិងនាមខ្លួន**

68. បញ្ហានេះពិបាកនឹងរកការពន្យល់ណាមួយឱ្យបានសមស្រប ។ នាមត្រកូល និងនាមខ្លួននៃមនុស្សត្រូវចាប់ផ្តើមពីមេគ្រួសារដែលត្រូវកត់ចូលនៅទីនេះ ។ នាមត្រកូល និងនាមខ្លួនដែលអ្នកសំភាសន៍កត់ចូលនេះត្រូវមានលក្ខណៈដូចគ្នាព្រោះបើសិនជាមានការចុះសំភាសន៍លើកទី 2 ដល់ផ្ទះនោះក្នុងអំឡុងពេល ឬក្រោយសំភាសន៍គឺងាយស្រួលកំណត់ចំណាំចំពោះមនុស្សជាមេគ្រួសារនោះ ។

**ទារកដែលមិនទាន់បានដាក់ឈ្មោះ**

68.1 មានពេលខ្លះអ្នកសំភាសន៍នឹងជួបប្រទះទារកដែលកើតមុនយប់ធ្វើជំរឿន តែទារកនោះមិនទាន់បានដាក់ឈ្មោះឱ្យនៅពេលអ្នកសំភាសន៍ធ្វើជំរឿន ។ ករណីនេះ សូមសរសេរ " ទារក " មុននាមត្រកូល ។ ឧទាហរណ៍ : បើសិនទារកថ្មីកើត ហើយឪពុកឈ្មោះ សារ៉ង្ស អ្នកត្រូវកត់ចូលជា ទារក សារ៉ង្ស ។

**មនុស្សដែលមានឈ្មោះស្រដៀងគ្នា**

68.2 អ្នកសំភាសន៍ក៏អាចជួបប្រទះផងដែរ គ្រួសារដែលមានមនុស្ស 2នាក់ ឬច្រើនដែលគេហៅឈ្មោះត្រកូលដូចគ្នា (ឧទាហរណ៍ មាស ) ។ ករណីនេះអ្នកសំភាសន៍ត្រូវកត់ចូលនាមត្រកូលនិងនាមខ្លួនផងដែរដែលពួកគេអាចសំគាល់បាននៅក្នុងគ្រួសារដោយអ្នកជិតខាងឬដោយមិត្តភ័ក្តិនិយមហៅ ( ឧទាហរណ៍: មាស សារ៉ង្ស និង មាស សារ៉ាត ) ។

**បង្គោល 3 : ទំនាក់ទំនងជាមួយមេគ្រួសារ**

69. នៅក្នុងបង្គោលនេះ អ្នកសំភាសន៍ត្រូវកត់ចូលពីទំនាក់ទំនងជាមួយមេគ្រួសារជាលាយលក្ខណ៍អក្សរ ។ មនុស្សទីមួយដែលត្រូវកត់ចូលគឺមេគ្រួសារ ។ ករណីជាមេគ្រួសារសូមសរសេរ " មេគ្រួសារ " ។ ចំពោះសមាជិកផ្សេងទៀត សូមសរសេរពីទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ។ សូមកុំប្រើពាក្យដូចជា " កូនប្រុស " "កូនស្រី " " ឪពុកមា " ឬ " ម្តាយមីង " តែត្រូវសរសេរថា " កូនប្រុស ឬ កូនស្រី

របស់បងប្អូនប្រុស ឬបងប្អូនស្រី ( សំរាប់ក្មួយប្រុស ឬ ក្មួយស្រី ) ឬប្អូនប្រុស ឬបងប្រុសរបស់ឪពុក ឬប្អូនប្រុស បងប្រុសរបស់ម្តាយ ប្តីរបស់ប្អូនស្រី បងស្រីរបស់ឪពុក ឬប្តីរបស់បងស្រីប្អូនស្រីរបស់ម្តាយ ( សំរាប់ឪពុកមា ) ឬប្អូនស្រី បងស្រីរបស់ឪពុក ឬប្អូនស្រី បងស្រីរបស់ម្តាយ ឬប្រពន្ធរបស់ប្អូនប្រុស បងប្រុសរបស់ឪពុក ឬប្រពន្ធរបស់ប្អូនប្រុស បងប្រុសរបស់ម្តាយ (ម្តាយមីង) ។ កូនប្រុសឬកូនស្រី និងរាប់ បញ្ចូលកូនប្រុសចិញ្ចឹម ឬកូនស្រីចិញ្ចឹម ឬកូនប្រុស កូនស្រីដើម ឬកូនប្រុស កូនស្រីចុង ។ ចំពោះបងប្រុស ប្អូនប្រុសថ្លៃសរសេរថា ជាបងប្រុស ឬ ប្អូនប្រុសរបស់ប្រពន្ធ ឬប្តីរបស់ បងស្រី ឬប្អូនស្រីដូចតាមករណី ដែលមាន ។ ចំពោះចៅ សូមសរសេរ កូនរបស់កូនប្រុស ឬ កូនរបស់ កូនស្រីបើមាន ។ ករណីអ្នកធ្វើខ្លួន (រស់នៅបង់លុយសំរាប់ម្ហូបអាហារ ) ឬអ្នកបំរើក្នុងផ្ទះ ឬអ្នកជាំស្លួ ។ល។ ត្រូវកត់អ្នកទាំងនោះ ជាសមាជិករបស់គ្រួសារទោះបីជាមិនជាប់សាច់ញាតិក៏ដោយ ត្រូវបញ្ជាក់ដោយសរសេរថាអ្នកធ្វើខ្លួន ឬអ្នកបំរើក្នុងផ្ទះ អ្នកជាំស្លួផងបើមាន ។

**បង្គោល 4 : ភេទ**

70. កត់ចូលលេខកូដ 1 សំរាប់បុរស និងលេខកូដ 2 សំរាប់ស្ត្រី ។ វាមានសារៈសំខាន់ក្នុងការសួរភេទរបស់មនុស្សនៅពេលណាដែលគេផ្តល់ពត៌មានដល់អ្នកសំភាសន៍តាមរយៈមនុស្សទី 3 ។ សូមចងចាំថា នាមត្រកូលនិងនាមខ្លួនខ្លះអាចភ្លេចក្នុងទិដ្ឋភាពនេះ ។ ឧទាហរណ៍ : វិជាតិ ឬសុជាតិអាចប្រើសំរាប់ឈ្មោះប្រុសផង ស្រីផង តែចំពោះមនុស្សក្រៀវ និងខ្ទើយ សូមសរសេរលេខ 1 ។

**តារាងសំណួរ 1.2 : ភ្ញៀវវត្តមាននៅយប់ធ្វើជំរឿន**

71. អ្នកសំភាសន៍ត្រូវកត់ចូលក្នុងតារាង 1.2 នៃតារាង ខ ផ្នែក 1 នូវនាមត្រកូលនិងនាមខ្លួន ទំនាក់ទំនងទៅនឹងមេគ្រួសារ និងភេទ របស់ភ្ញៀវម្នាក់ៗ ដែលវត្តមាននៅក្នុងគ្រួសារនៅយប់ធ្វើជំរឿន ។ ជាថ្មីម្តងទៀត សូមអ្នកសំភាសន៍អនុវត្តតាមការណែនាំដែលបានចែងខាងលើសំរាប់បំពេញឱ្យបង្គោល 1 ដល់ 4 ។ ក៏តម្រូវឱ្យអ្នកសំភាសន៍សរសេរផងដែរក្នុងបង្គោល 5 ឬ 6 នូវអាសយដ្ឋានពិតប្រាកដរបស់ភ្ញៀវ ។ បើអាសយដ្ឋានពិតប្រាកដរបស់ភ្ញៀវស្ថិតនៅក្នុងប្រទេសកម្ពុជានោះសូមចុះឈ្មោះស្រុក និងសរសេរឈ្មោះខេត្តនៅក្នុងវង់ក្រចកក្នុងបង្គោល 5 ហើយគូសសញ្ញា ( - ) ក្នុងបង្គោល 6 ។ បើអាសយដ្ឋានពិតប្រាកដរបស់ភ្ញៀវស្ថិតនៅក្រៅប្រទេសកម្ពុជានោះសូមគូសសញ្ញា ( - ) ក្នុងបង្គោល 5 ហើយសរសេរឈ្មោះប្រទេសនោះក្នុងបង្គោល 6 ។ បើគ្មានភ្ញៀវវត្តមានក្នុងគ្រួសារនៅយប់ធ្វើជំរឿនអ្នកចុះសំភាសន៍ត្រូវគូសចោលតារាងសំណួរ 1.2 យ៉ាងស្អាត ។

**តារាងសំណួរ 1.3 : សមាជិកពិតប្រាកដអវត្តមាននៅយប់ធ្វើជំរឿន**

72. ការកត់ចូលក្នុងតារាង 1.3 ត្រូវបានប្រើសំរាប់តែសមាជិកពិតប្រាកដក្នុងគ្រួសារដែលអវត្តមានពីផ្ទះនៅយប់ធ្វើជំរឿន ។ សូមកត់សំគាល់ថាមានតែ 5 បន្ទាត់ទេដែលគេបានផ្តល់ឱ្យក្នុងបង្គោលនេះ ។ បើសិនជាមានមនុស្សលើសពី 5 នាក់ដែលត្រូវកត់ចូលទីនេះ អ្នកសំភាសន៍ត្រូវប្រើតារាងសំណួរគមួយទៀត ហើយដាក់លេខរៀងឱ្យត្រូវតាមលំដាប់ ។

72.1 ក្នុងតារាងសំណួរ 1.3 អ្នកសំភាសន៍ត្រូវកត់នាមត្រកូល និងនាមខ្លួនទំនាក់ទំនងទៅនឹងមេគ្រួសារ ភេទ អាយុ អាស័យដ្ឋាននៅយប់ធ្វើជំរឿន និងរយៈពេលអវត្តមានរបស់សមាជិកពិតប្រាកដរបស់គ្រួសារម្នាក់ៗដែលបានអវត្តមាននៅយប់ធ្វើជំរឿន ។ ដើម្បីធ្វើការបំពេញនាមត្រកូលនិងនាមខ្លួន ភេទ និងទំនាក់ទំនងទៅនឹងមេគ្រួសារ ឬមេគ្រួសារបណ្តោះអាសន្ននោះ សូមអនុវត្តតាមការណែនាំដែលបានចែងខាងលើ ។ ដើម្បីកត់ត្រាយកអាយុនោះសូមអនុវត្តតាមការណែនាំ ដែលបានផ្តល់ឱ្យសំរាប់បំពេញ បង្គោល 5 : អាយុ សំរាប់តារាង ខ តារាងសំណួរតាមគ្រួសារ, ផ្នែក 2 : ពត៌មានផ្ទាល់ខ្លួន ( កថាខ័ណ្ឌ 84, 84.1 និង 84.2 នៅក្នុងជំពូកនេះ ) ។

72.2 "អាស័យដ្ឋាននៅយប់ធ្វើជំរឿន " ( បង្គោល 6 ឬ 7 ) គឺសំដៅដល់ទីកន្លែងដែលអ្នកអវត្តមានជាសមាជិកពិតប្រាកដរបស់គ្រួសារទៅស្នាក់នៅ នៅយប់ធ្វើជំរឿន ។ បើអាស័យដ្ឋាន ឬកន្លែងដែលសមាជិកពិតប្រាកដអវត្តមាននៃគ្រួសារនោះបានទៅស្នាក់នៅស្ថិតនៅក្នុងប្រទេសកម្ពុជានោះ សូមចុះឈ្មោះស្រុក ហើយសរសេរឈ្មោះខេត្តនៅក្នុងវង់ក្រចក ក្នុងបង្គោល 6 ។ បើសិនអាស័យដ្ឋាន ឬកន្លែងនោះស្ថិតនៅក្នុងប្រទេសផ្សេងទៀតនោះ សូមចុះតែឈ្មោះប្រទេសនោះក្នុងបង្គោល 7 ។ បើសិនពត៌មានលំអិតនៃទីកន្លែងទាំងនោះមិនបានឆ្លើយប្រាប់ទេ សូមសរសេរ " មិនដឹង " ត្រង់បង្គោល 6 ឬ 7 ។

72.3 ក្នុងបង្គោល 8 អ្នកសំភាសន៍ត្រូវសរសេរជាខែពេញនូវរយៈពេលដែលសមាជិកពិតប្រាកដបានអវត្តមានរហូតដល់យប់ធ្វើជំរឿន ។ ឧទាហរណ៍ : បើសិនជាសមាជិកពិតប្រាកដបានចេញពីផ្ទះបាន 2 ខែ 3 អាទិត្យ សូមសរសេរលេខ 2 ក្នុងកន្លែងដែលគេផ្តល់ឱ្យ ។ បើសិនសមាជិកពិតប្រាកដបានអវត្តមានតិចជាង 1 ខែ សូមសរសេរលេខ 0 ។

72.4 បើសិនមេគ្រួសារពិតប្រាកដអវត្តមាននៅយប់ធ្វើជំរឿន នាមត្រកូលនិងនាមខ្លួនរបស់គាត់ នោះត្រូវកត់ចូលនៅបន្ទាត់ទី 1 ក្នុងតារាងសំណួរ 1.3 ។ សូមចងចាំថា យ៉ាងណាក៏ដោយក៏ត្រូវបញ្ជាក់ក្នុងបង្គោលទំនាក់ទំនងអំពីទំនាក់ទំនងរបស់មនុស្សនេះទៅនឹងមេគ្រួសារបណ្តោះអាសន្ន ដែលបានកត់ចូលក្នុងតារាងសំណួរ 1.1 ។ ដូច្នេះអ្នកមិនត្រូវកត់ចូលថា ជាមេគ្រួសារនៅក្នុងបង្គោលទំនាក់ទំនងក្នុងតារាងសំណួរ 1.3

ទេតែសូមបញ្ជាក់ថា មនុស្សអវត្តមាននេះ ជាប្តី ឪពុក បងប្រុស ប្អូនប្រុស ជាម្តាយ ។ល។ នៃមេគ្រួសារបណ្តោះអាសន្ន ។ បើគ្មានសមាជិកពិតប្រាកដនៃគ្រួសារអវត្តមាននៅយប់ធ្វើជំរឿន អ្នកចុះសំភាសន៍ត្រូវគូសចោលតារាងសំណួរ 1.3 យ៉ាងស្អាត ។

**ចំនួនមនុស្សសរុបក្នុងតារាងសំណួរ 1.1 និង តារាងសំណួរ 1.2**

73. នៅជ្រុងខាងស្តាំដៃនៃតារាងសំណួរ 1.3 មានប្រអប់មួយចំនួន នៅក្នុងនោះអ្នកសំភាសន៍ត្រូវកត់ចូលនូវចំនួនមនុស្សសរុប ( ប្រុស បូក ស្រី ) ក្នុងតារាងសំណួរ 1.1និងតារាងសំណួរ 1.2 ។ បើគ្មានការកត់ចូលក្នុងតារាងសំណួរ 1.2ទេ អ្នកចុះសំភាសន៍ត្រូវសរសេរ " 0 " ក្នុងប្រអប់សំរាប់ " ចំនួនមនុស្សក្នុងតារាងសំណួរ 1.2 " ។ ដោយឡែក ចំពោះចំនួនសរុបក្នុងតារាងសំណួរ 1.3 អ្នកចុះសំភាសន៍មិនត្រូវសរសេរអ្វីទាំងអស់កិច្ចការនេះនឹងធ្វើតាមក្រោយនៅការិយាល័យ ។

**ចំនួនមនុស្សសរុបក្នុងតារាងសំណួរ 1.1 បូកនិង 1.2**

74. មានប្រអប់ 1 ដែលបានផ្តល់ឱ្យសំរាប់កត់ត្រាចំនួនមនុស្សសរុបក្នុងតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 ។ អ្នកសំភាសន៍ត្រូវបូកចំនួនមនុស្សក្នុងតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 ហើយដាក់លទ្ធផលសរុបនោះក្នុងប្រអប់ដែលបានផ្តល់ឱ្យ។បានត្រឹមត្រូវ ។

75. *បើសិនអ្នកសំភាសន៍បានប្រើតារាងសំណួរលើសពីមួយតារាងសំណួរសំរាប់ 1 គ្រួសារ អ្នកសំភាសន៍ត្រូវបូកចំនួនមនុស្សដែលបានចុះក្នុងតារាង 1.1 និង តារាង 1.2 ហើយចុះផលបូកសរុបនោះនៅក្នុងប្រអប់សមស្របក្នុងតារាងសំណួរ ទី 1 សំរាប់គ្រួសារ ។ ប្រអប់ស្ថិតនៅលើតារាងសំណួរទី 2 ត្រូវទុកចំហ ។*

76. អ្នកសំភាសន៍ត្រូវចុះនាមត្រកូល និងនាមខ្លួនរបស់ខ្លួន ត្រូវចុះហត្ថលេខា និងថ្ងៃ ខែ ឆ្នាំត្រង់កន្លែងសមស្រប ។

## សេចក្តីណែនាំសំរាប់បំពេញតារាង ខ តារាងសំណួរតាមគ្រួសារ ផ្នែក2 : ពត៌មានផ្ទាល់ខ្លួន

### លាតត្រដាងពីតារាង ខ តារាងសំណួរតាមគ្រួសារ ផ្នែក 2

77. ផ្នែកនៃតារាងសំណួរនេះមានចែកជាបង្គោលនិងជួរជាច្រើន ។ មានបង្គោលចុះលេខរៀងពី 1, 2,3...,20 ។ បង្គោលនិមួយៗសំរាប់សំណួរមួយមានដាក់ចំណងជើងយ៉ាងច្បាស់នៅក្បាលបង្គោល ។

77.1 ផ្នែកនេះមាន 10 បន្ទាត់ ។ បន្ទាត់និមួយៗសំរាប់កត់ពត៌មានពីមនុស្សម្នាក់ ។ នេះមានន័យថា បើសិនអ្នកសំភាសន៍ធ្វើការសំភាសន៍យកពត៌មានពីមនុស្សម្នាក់ នោះត្រូវប្រើនិងសរសេរតែមួយបន្ទាត់ដោយចាប់ផ្តើមពីឆ្វេងដៃ ហើយបំពេញចំលើយសំណួរម្តងមួយៗតាមបណ្តោយបន្ទាត់ទៅស្តាំដៃ ។

*77.2 សូមចងចាំថា អ្នកសំភាសន៍ត្រូវបំពេញក្នុងផ្នែក 2 តែចំពោះសមាជិកពិតប្រាកដរបស់គ្រួសារ គឺអ្នកនៅ ( មនុស្សដែលបានចុះក្នុងបញ្ជីតារាងសំណួរ 1.1 និងតារាងសំណួរ 1.2 នៃផ្នែក 1 ) ដែលវត្តមាននៅក្នុងគ្រួសារនៅយប់ធ្វើជំរឿន ។ មិនត្រូវរាប់បញ្ចូលនៅទីនេះនូវសមាជិកពិតប្រាកដរបស់គ្រួសារដែលអវត្តមាននៅយប់ធ្វើជំរឿនទេ ( ឧ. មនុស្សដែលបានចុះក្នុងតារាងសំណួរ 1.3 នៃផ្នែក 1 ) ។*

### សេចក្តីណែនាំពីការបំពេញបង្គោល 1 ដល់ 20 នៃតារាង ខ : ផ្នែក 2

78. ក្នុងផ្នែក 2អ្នកសំភាសន៍ត្រូវប្រមូលយកពត៌មាននេះពីមនុស្សទាំងអស់ដែលមានក្នុងតារាងសំណួរ 1.1 និងតារាងសំណួរ 1.2នៃផ្នែក 1 ។ សំណួរខ្លះបានទទួលចម្លើយរួចហើយក្នុងផ្នែក 1 ។ ដូច្នេះគេមិនត្រូវការសួរសំណួរទាំងនេះជាថ្មីឡើងវិញទេ ។ ករណីនេះ អ្នកសំភាសន៍ទាំងអស់ត្រូវចំលងពត៌មានដែលមានដាក់ក្នុងបង្គោលសមស្រប ។

### បង្គោល 1 : លេខរៀង

79. លេខរៀងបានផ្តល់ឱ្យសំរាប់គ្រប់បន្ទាត់និមួយៗ ( ពោលគឺសំរាប់មនុស្សម្នាក់ៗនៅក្នុងគ្រួសារដែលចាប់ផ្តើមពីមេគ្រួសារ ) ។ ដើម្បីងាយស្រួលដល់អ្នកសំភាសន៍ លេខរៀងបានបោះពុម្ពមកជាស្រេចនៅក្នុងបង្គោលនេះ ដែលអ្នកសំភាសន៍អាចប្រើបានសមស្រប ។ សូមពិនិត្យមើលនៅក្នុងលេខរៀងចុងក្រោយដែលចុះគឺត្រូវស្មើនឹងចំនួនសរុបមនុស្សក្នុងតារាងសំណួរ 1.1 និង 1.2 ក្នុងតារាងខាងក្រោមខាងស្តាំដៃលើទំព័រទី 1 ( ផ្នែក1 ) ។

**បង្គោល 2 ដល់ 4**

80. សំរាប់បំពេញពត៌មាននៅក្នុងបង្គោលទាំងនេះ ដំបូងត្រូវកត់ស្រង់យកពត៌មានពីតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 នៃផ្នែក 1 រួចទើបបន្តបំពេញពត៌មានក្នុងបង្គោលផ្សេងទៀតសំរាប់មនុស្សម្នាក់ៗ ។

**បង្គោល 2 : នាមត្រកូលនិងនាមខ្លួន**

81. សូមសរសេរត្រង់កន្លែងចំហនូវនាមត្រកូលនិងនាមខ្លួនរបស់អ្នកឆ្លើយទាំងអស់នៅក្នុងគ្រួសារ ( ដូចនៅក្នុងតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 ) ។ ដំបូង នាមត្រកូល និងនាមខ្លួនក្នុងតារាងសំណួរ 1.1 ត្រូវបានចំលងដាក់ចូល ។ គេអាចអនុវត្តតាមរបៀបដោយកត់នាមត្រកូល និងនាមខ្លួនពីក្នុងតារាងសំណួរ 1.2 តាមលំដាប់ដូចគ្នា ។

**បង្គោល 3 : ញាតិសន្តាន**

82. ដោយផ្អែកលើពត៌មានដែលបានប្រមូលរួចក្នុងបង្គោល 3 នៃតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 នោះសូមចុះលេខកូដសំរាប់ទំនាក់ទំនងជាមួយមេគ្រួសាររបស់មនុស្សម្នាក់ៗ ។ គេបានផ្តល់លេខកូដស្រាប់នៅលើតារាងសំណួរក្រោមបង្គោល 3 សំរាប់សំភាសន៍ពីទំនាក់ទំនងជាមួយមេគ្រួសារ ។ សូមអានទំនាក់ទំនងជាញាតិសន្តាន ហើយជ្រើសរើសយកនិងដាក់លេខកូដសមស្រប ។ សូមកត់សំគាល់ថា លេខកូដ 1 សំរាប់មេគ្រួសារ ។ ជានិច្ចកាលមេគ្រួសារ គឺជាមនុស្សទី 1 ដែលត្រូវសំភាសន៍មុនគេនៅក្នុងគ្រួសារ ។ សូមចុះលេខកូដ 2 សំរាប់ប្រពន្ធនៃមេគ្រួសារជាប្រុស ឬប្តីនៃមេគ្រួសារជាស្រី ។ សូមប្រើ លេខកូដ 3 សំរាប់កូនប្រុស ឬកូនស្រីរបស់មេគ្រួសារ ។ សូមប្រើលេខកូដ 4 សំរាប់ឪពុក ឬម្តាយរបស់មេគ្រួសារ ។ សូមប្រើលេខកូដ 5 សំរាប់ចៅប្រុស ឬចៅស្រីរបស់មេគ្រួសារ ។ សូមប្រើលេខកូដ 6 សំរាប់សាច់ញាតិផ្សេងទៀតរបស់មេគ្រួសារ ។ កិច្ចការនេះត្រូវអនុវត្តដោយប្រុងប្រយ័ត្នដើម្បីចៀសវាងការចុះលេខកូដខុសចំពោះទំនាក់ទំនងជាមួយមេគ្រួសារ ។ ឧទាហរណ៍ កូនប្រុសរបស់ប្អូនស្រី / បងស្រី មិនត្រូវចុះលេខកូដជាកូនប្រុស ( លេខកូដ 3 ) ដោយគ្រាន់តែឮមានពាក្យកូនប្រុសត្រង់នេះទេ ។ ក្នុងករណីនេះលេខកូដត្រឹមត្រូវគឺលេខកូដ 6 ។ ចំពោះមនុស្សដែលមិនជាប់សាច់ញាតិនៃមេគ្រួសារ សូមប្រើលេខកូដ 7 ។

**បង្គោល 4 : ភេទ**

83. អាចបំពេញបង្គោលនេះដោយចម្លងយកពត៌មានពីបង្គោល 4 នៃតារាងសំណួរ 1.1 និង តារាងសំណួរ 1.2 ចំពោះមនុស្សដែលបានជំរឿន ។

**បង្គោល 5 : អាយុ**

84. អាយុរបស់មនុស្សម្នាក់ៗត្រូវឆ្លើយពីអាយុពេញដែលគិតរហូតដល់ថ្ងៃទី 03 ខែមិនា ឆ្នាំ 1998 ។ ចំពោះ អ្នកដែលដឹងថ្ងៃ ខែ ឆ្នាំ កំណើតរបស់ខ្លួន អាយុដែលត្រូវចុះ គឺអាយុនៅខួបកំណើតក្រោយបង្អស់

" អាយុពេញឆ្នាំតែប៉ុណ្ណោះ " មានន័យថា អាយុទាំងអស់ត្រូវកត់ចូលជាឆ្នាំពេញដោយផាត់ចោលប្រភាគនៃឆ្នាំ និង ខែ ។

84.1 ឧទាហរណ៍ អាយុ 15 ឆ្នាំ 11 ខែ ត្រូវចុះតែ 15 ។ សូមកុំចុះចំនួនខែ ។ ត្រូវការតែចំនួនឆ្នាំទេ ។ ទារកទាំងអស់ដែលមានអាយុតិចជាងមួយឆ្នាំ ត្រូវកត់ចូល " 00 " ។ ទាក់ទងក្នុងប្រការនេះសំណូមពរឱ្យអ្នកសំភាសន៍ធ្វើឱ្យប្រាកដថាទារកទាំងឡាយរបស់គ្រួសារ ទោះជាកើតបានមួយថ្ងៃឬអាយុតិចជាងមួយថ្ងៃក្តី នៅយប់ធ្វើជំរឿនត្រូវតែរាប់ទាំងអស់ ។ សូមបញ្ជាក់សាជាថ្មីទៀតថា អ្នកសំភាសន៍ត្រូវប្រុងប្រយ័ត្ន ដើម្បីរាប់ឱ្យបានអស់នូវកុមារ (អាយុតិចជាង 14 ឆ្នាំ ) និង ទារក ( តិចជាង 1 ឆ្នាំ )។ ដើម្បីកុំឱ្យភ្លេចជំរឿនកុមារទាំងនោះ អ្នកសំភាសន៍ត្រូវសួរបញ្ជាក់ ។ នេះជាការណែនាំដែលមានសារៈសំខាន់បំផុតដែលអ្នកសំភាសន៍ត្រូវចងចាំក្នុងចិត្តជានិច្ច ។

84.2 *តើត្រូវធ្វើយ៉ាងដូចម្តេចនៅពេលដែលមនុស្សម្នាក់មិនដឹងអាយុរបស់ខ្លួន ?*

ចំពោះមនុស្សប្រភេទនេះ សូមប្រើវិធីសាស្ត្រណាមួយក្នុងចំណោមវិធីសាស្ត្រដូចតទៅដើម្បីប៉ាន់ស្មានអាយុរបស់គាត់នោះ :

1. អ្នកសំភាសន៍អាចសួរគាត់នោះឱ្យឆ្លើយអំពីឆ្នាំកំណើតខ្លួនតាមឆ្នាំឈ្មោះសត្វ ( ជូត ឆ្លូវ ។ល។...កុរ ) ។ ដោយឈរលើពត៌មានដែលបានផ្តល់ជូន នោះអ្នកសំភាសន៍ត្រូវប្រើតារាងប្រៀបធៀបឆ្នាំសត្វនិងឆ្នាំសកលដែលបានចែកជូនដើម្បីផ្លាស់អាយុពីឆ្នាំសត្វទៅឆ្នាំសកលរបស់គេកត់យកអាយុឆ្នាំពេញ ។

2. (i). *អ្នកសំភាសន៍សួរទៅសាមីខ្លួនឱ្យរាប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយ (សំដៅដល់ព្រឹត្តិការណ៍*ដែលមាននៅក្នុងស្រុក ភូមិនោះ ) ដែលគេបាននិទានដល់គាត់ហើយដែលបានកើតឡើង មុនឬក្រោយថ្ងៃកំណើតរបស់គាត់នោះ ។ នឹងមានផ្តល់ដល់អ្នកសំភាសន៍នូវបញ្ជីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រសំរាប់គោលដៅនេះ ហើយអ្នកសំភាសន៍អាចផ្តល់យោបល់អំពីព្រឹត្តិការណ៍សមរម្យមួយដែលមានចុះក្នុងបញ្ជីនេះជូនសាមីខ្លួនផងដែរ ។

(ii). សូមសួរសាមីខ្លួនឱ្យផ្តល់ដល់អ្នកសំភាសន៍នូវការបញ្ជាក់មួយថាតើគាត់មានអាយុប៉ុន្មាននៅពេលដែលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនោះកើតមានឡើង ។

(iii). រួចប្រើពត៌មានទាំងនេះដើម្បីគិតគូរពីអាយុគាត់ ។ ឧ.បើសិនគាត់ឆ្លើយប្រាប់អ្នកសំភាសន៍ថាគាត់មានអាយុប្រហែល20ឆ្នាំនៅពេលដែលប្រទេសកម្ពុជាបានទទួលឯករាជ្យ នោះអាយុរបស់គាត់អាចស្មើនឹង 20 + 44 (កម្ពុជាបានឯករាជ្យនៅ ថ្ងៃទី 9 វិច្ឆិកា 1953 ដល់ថ្ងៃទី 3 ខែ មិនា 1998 ) = 64 ឆ្នាំ ។

3. ជួនកាលអាយុអាចត្រូវបានគេបញ្ជាក់ដោយយោងទៅតាមអាយុម្នាក់ទៀត ដែលគេស្គាល់អាយុរបស់ខ្លួនហើយដែលជាអ្នករស់នៅក្នុងគ្រួសារដដែល ឬក្នុងគ្រួសារជិតខាងឬអាយុរបស់មនុស្សដែលគេស្គាល់នៅក្នុងភូមិ ដូចជាអាយុប្រធានភូមិ ។

4. មធ្យោបាយចុងក្រោយមួយទៀត អ្នកសំភាសន៍ត្រូវប៉ាន់ស្មានអាយុម្នាក់ៗដោយផ្អែកលើលក្ខណៈវ័យរបស់មនុស្សនោះតាមដែលមើលឃើញផ្ទាល់ភ្នែក ។ បើសិនអ្នកសំភាសន៍បានទទួលពត៌មានរបស់មនុស្សអវត្តមានពីមនុស្ស ទី 3 នោះជាក់ស្តែង អ្នកសំភាសន៍ត្រូវផ្អែកលើពត៌មានដែលផ្តល់ពីមនុស្សទី 3 ដើម្បីធ្វើការប៉ាន់ស្មានអាយុរបស់មនុស្សដែលអវត្តមាន ។ ក្នុងកាលៈទេសៈណាក៏ដោយបើមិនមានការបារំាចាំបាច់ទេ អ្នកសំភាសន៍មិនត្រូវទុកអោយបង្គោលនោះនៅចំហឡើយ ។

## បង្គោល 6: ស្ថានភាពអាពាហ៍ពិពាហ៍

85. លេខកូដនានាមានដាក់នៅក្នុងក្បាលបង្គោលស្រាប់ ។ អ្នកសំភាសន៍ត្រូវសួរសំណួរពិបាកៗទាំងនេះដោយប្រុងប្រយ័ត្នហើយកត់លេខកូដចូលសមស្របទៅតាមចំឡើយដែលគេផ្តល់អោយ ។ សូមកត់ចូលលេខកូដ 1 ចំពោះមនុស្សនៅលីវ (ឧ. សំរាប់ មនុស្សដែលមិនដែលចូលក្នុងចំណងជាលក្ខណៈគ្រួសារណាមួយសោះ ) ។ សូមកត់ចូលលេខកូដ 2 ចំពោះមនុស្សរៀបការហើយ លេខកូដ 3 ចំពោះមេម៉ាយប្តីស្លាប់ឬពោះម៉ាយប្រពន្ធស្លាប់ លេខកូដ 4 លែងលះគ្នាជាផ្លូវការ លេខកូដ 5 លែងលះគ្នាតែពុំទាន់ជាផ្លូវការ ។

86. ក្នុងប្រភេទ " រៀបការហើយ " ក៏មានរាប់បញ្ចូលមនុស្សទាំងអស់ដែលបានរៀបការតាមប្រពៃណីតែមិនទាន់រស់នៅជាប្តីប្រពន្ធនៅឡើយ ។ ទោះជាអាពាហ៍ពិពាហ៍មួយត្រូវគេជំទាស់ដោយអ្នកជិតខាងក៏ដោយក៏ត្រូវសរសេរលេខកូដ 2 បើសិនអ្នកឆ្លើយនោះគាត់និយាយថា គាត់បានរៀបការហើយ ហើយឃើញនឹងភ្នែកគឺមានសុភមង្គលជាប់លាប់ជាមួយគ្នាពិតប្រាកដ ។ ប្រភេទ " លែងលះគ្នាតែពុំទាន់ផ្លូវការ " រួមមានបញ្ចូលទាំងការលែងលះគ្នាស្របច្បាប់និងការរស់នៅផ្សេងគ្នាតាមការយល់ព្រមរៀងខ្លួន ។ មនុស្សដែលមេម៉ាយ ប្តីស្លាប់, ពោះម៉ាយប្រពន្ធស្លាប់ ឬ លែងលះគ្នា តែបានរៀបការសារជាថ្មីត្រូវចុះថាបានរៀបការ។

## បង្គោល 7 : ភាសាកំណើត

87. ភាសាកំណើតរបស់មនុស្សម្នាក់ គឺជាភាសាដែលម្តាយរបស់មនុស្សនោះនិយាយទៅកាន់គាត់តាំងពីគាត់នៅវ័យកុមារ ។ បើម្តាយស្លាប់នៅក្នុងវ័យទារក ភាសាដែលគេនិយាយភាគច្រើននៅក្នុងផ្ទះ នៅពេលគាត់មានវ័យកុមារគឺសន្មតថាជាភាសាកំណើតរបស់គាត់ ។ ក្នុងករណីនៅជាទារក មនុស្សថ្លង់និងគ ភាសា

ប្រើធម្មតាដែលម្តាយប្រើត្រូវកត់ចូល ។ ក្នុងករណីមានការសង្ស័យភាសាដែលប្រើនិយាយក្នុងគ្រួសារអាចកត់ចូលបានដែរ ។

87.1 អ្នកសំភាសន៍ត្រូវប្រើលេខកូដដូចតទៅ សំរាប់កត់ចូលចំលើយចំពោះសំណួរនេះ : លេខកូដភាសាកំណើត

1 ខ្មែរ
2 វៀតណាម
3. ចិន
4 ឡាវ
5 ថៃ
6 បារាំង
7 អង់គ្លេស
8 ភាសាកំណើតផ្សេងៗទៀត ( ត្រូវបញ្ជាក់ )

87.2 ទាក់ទងនឹងបញ្ហានេះ សូមកត់សំគាល់តាមថាការណែនាំមានផ្តល់ជូនដូចខាងក្រោមនេះ : អ្នកសំភាសន៍ ត្រូវពន្យល់ដល់អ្នកឆ្លើយថា ពត៌មានដែលត្រូវការនៅទីនេះគឺភាសាកំណើត មិនមែនភាសានិយាយណាមួយទេ ។ សូមបញ្ជាក់ផងដែរថា គេត្រូវការពត៌មាននេះសំរាប់តែគោលបំណងស្ថិតិសុទ្ធសាធតែប៉ុណ្ណោះ ។

(i)- យ៉ាងណាក៏ដោយអ្នកសំភាសន៍ត្រូវតែកត់ចូលនូវភាសាដែលផ្តល់អោយដោយអ្នកឆ្លើយដែលជាភាសាកំណើតរបស់គាត់ ហើយអ្នកសំភាសន៍មិនត្រូវផ្តល់យោបល់ណាមួយដល់គេឡើយ និងកុំព្យាយាមកត់ចូលភាសាណាមួយក្រៅពីអ្វីដែលគេបានប្រាប់ ។

(ii)- បើសិនអ្នកសំភាសន៍មានការសង្ស័យថា ភាសាកំណើតគេមិនឆ្លើយដោយពិតប្រាកដទេអ្នកសំភាសន៍ត្រូវកត់ចូលនូវលេខកូដភាសាកំណើតនោះ ដូចដែលគេបានឆ្លើយប្រាប់ហើយធ្វើរបាយការណ៍មួយជូនដល់អ្នកត្រួតពិនិត្យរបស់ខ្លួនសំរាប់ធ្វើការផ្ទៀងផ្ទាត់ ។

(iii)- អាចមានភាសាកំណើតខុសប្លែកពីគ្នាចំពោះមនុស្សខុសគ្នានៅក្នុងគ្រួសារមួយ ។ ហេតុនេះចាំបាច់ត្រូវសួរមនុស្សម្នាក់ៗ អំពីភាសាកំណើតរបស់គេ ។

**បង្គោល 8 : សាសនា**

88. សូមកត់ចូលនូវលេខកូដសាសនាឱ្យសមស្របទៅតាមចំឡើយរបស់អ្នកឆ្លើយអំពីសាសនាដែលគេកាន់ ។ត្រង់នេះគ្មានត្រូវការផ្ទៀងផ្ទាត់ទេ ។ អ្នកសំភាសន៍ត្រូវទទួលយកអ្វីជាចំលើយពីអ្នកឆ្លើយ ។ ចំពោះមនុស្ស

ខ្លះដែលបានប្រាប់ថាគាត់បានចូលសាសនាដែលស្ថិតក្នុងប្រភេទផ្សេងៗនោះ សូមកត់ចូលលេខកូដ 4 ហើយបញ្ជាក់ពីឈ្មោះសាសនាដែលគេឆ្លើយប្រាប់នោះ ឧ. 4 សាសនាហិនឌូ ។ ចំពោះអ្នកដែលឆ្លើយថាគាត់មិនមានចូលសាសនាណាមួយឡើយ សូមសរសេរលេខកូដ 4 ( គ្មានសាសនា ) ។

## បង្គោល ៩ : ទីកន្លែងកើត

89. បើសិនមនុស្សម្នាក់ឆ្លើយថា គេបានកើតនៅក្នុងភូមិនេះ សូមកត់ចូលលេខកូដ 1 ត្រង់ចន្លោះពណ៌ស (មិនមែនក្នុងប្រអប់ផាត់ខ្មៅដែលរក្សាទុកសំរាប់ចុះលេខកូដនៅការិយាល័យកណ្តាលទេ ) ។ មនុស្សដែលបានឆ្លើយថាបានកើតនៅក្នុងភូមិនេះ នោះគឺជាអ្នកកើតនៅក្នុងភូមិដដែល ដែលអ្នកសំភាសន៍កំពុងដឹកនាំការជំរឿនរបស់ខ្លួន ។ ទីកន្លែងកើតរបស់មនុស្សម្នាក់គឺជាកន្លែង ឬ អាស័យដ្ឋានពិតប្រាកដរបស់ម្តាយសាមីខ្លួននោះនៅពេលកើតគាត់ ។ ឧ. ចំពោះមនុស្សម្នាក់កើតក្នុង (ក ) ពេទ្យ ឬ មន្ទីរសម្ភព ក្រៅពីកន្លែងអាស័យដ្ឋានពិតប្រាកដរបស់ម្តាយឬ (ខ) នៅភូមិកំណើតរបស់ម្តាយដែលមិនមែនជាភូមិដែលម្តាយរស់នៅសព្វថ្ងៃ ឬ (គ ) ទីកន្លែងផ្សេងណាមួយដែលម្តាយគ្រាន់តែទៅលេងមួយរយៈពេលខ្លីនោះ ទីកន្លែងកំណើតរបស់មនុស្សនេះគឺកន្លែងដែលម្តាយគាត់រស់នៅធម្មតា ពោលគឺមិនមែនមន្ទីរពេទ្យដែលមិនមែនភូមិរបស់ម្តាយ ឬក៏កន្លែងដែលម្តាយទៅលេងទេ ។ ទោះបីយ៉ាងណាក៏ដោយ បើការស្នាក់នៅរយៈពេលវែងក្រៅពីអាស័យដ្ឋានពិតប្រាកដរបស់គាត់បានមួយខែ ឬ ច្រើន ឬ ម្តាយមានបំណងស្នាក់នៅកន្លែងថ្មីក្នុងរយៈពេលមួយខែ ឬច្រើន "ទីកន្លែងកើតថ្មីពិតប្រាកដ " នោះត្រូវបានចាត់ទុកជាទីកន្លែងកើតរបស់មនុស្សនោះ ឧ. ឈ្មោះ បុស្បាឌីន ស្នាក់នៅធម្មតាជាមួយប្តីគាត់ នៅបាក់ខែង បានទៅកណ្តាលកោះ ដើម្បីសំរាលកូននៅផ្ទះម្តាយរបស់គាត់ ហើយបានត្រឡប់មកវិញក្នុងរយៈពេល 15ថ្ងៃ ទីកន្លែងកំណើតរបស់ទារកគឺបាក់ខែងមិនមែនកណ្តាលកោះទេ ។

89.1 ផ្ទុយទៅវិញ បុស្បាឌីន ស្នាក់នៅកណ្តាលកោះក្នុងរយៈពេលមួយខែ ឬ ច្រើនខែមុនសំរាលកូន ដូច្នេះទីកន្លែងកើតនៃទារករបស់គាត់គឺកណ្តាលកោះ មិនមែនបាក់ខែងទេ ។

89.2 ចំពោះមនុស្សទាំងឡាយដែលបានឆ្លើយថា គាត់បានកើតនៅក្រៅភូមិដែលអ្នកសំភាសន៍កំពុងធ្វើជំរឿននោះសូមកត់ចូលឈ្មោះស្រុកនៃភូមិកំណើតនោះ ហើយសរសេរឈ្មោះខេត្តនៃស្រុកនោះនៅក្នុងវង់ក្រចក ។ ចំពោះអ្នកកើតក្រៅប្រទេសកម្ពុជាយើង សូមសរសេរឈ្មោះប្រទេសត្រង់កន្លែងកើត ។

## បង្គោល 10 : លំនៅដ្ឋានពីមុន

90. ក្នុងកន្លែងចន្លោះ (មិនមែនក្នុងប្រអប់ផាត់ខ្មៅ ) សូមកត់ចូលលេខកូដ 1 បើអ្នកឆ្លើយបានប្រាប់ថាគាត់រស់នៅក្នុងភូមិដែលកំពុងតែធ្វើជំរឿននេះជាបន្តបន្ទាប់តាំងពីគាត់កើតមក ( លើកលែងតែមានការផ្លាស់ទៅ

នៅកន្លែងមួយទៀតជាបណ្ដោះអាសន្នក្រៅពីភូមិជំរឿននេះ ) រួចរំលងទៅបង្គោល 13 ។ បើសិនមនុស្សម្នាក់បានរស់នៅក្នុងភូមិមួយផ្សេង មុនគាត់មករស់នៅភូមិបច្ចុប្បន្នដែលធ្វើសំភាសន៍ ដូច្នេះភូមិនៅមុននោះគឺជាលំនៅដ្ឋានពីមុន ។ បើមនុស្សនោះបានរស់នៅភូមិថ្មីផ្សេងទៀតច្រើនជាងមួយភូមិ លំនៅដ្ឋានចុងក្រោយរបស់គាត់គឺជាភូមិដែលយើងចាប់អារម្មណ៍ជាងគេ ។ ឧទាហរណ៍: មនុស្សម្នាក់បានធ្វើសំភាសន៍នៅក្នុងភូមិ ក ដែលពីមុនគាត់បានរស់នៅភូមិ ខ ហើយមុននឹងមករស់នៅភូមិ ខ គាត់បានរស់នៅក្នុងភូមិ គ ដូច្នេះ លំនៅដ្ឋានចុងក្រោយរបស់គាត់គឺភូមិ ខ មិនមែនភូមិ គ ទេ ។ សូមសរសេរឈ្មោះស្រុកនៃលំនៅដ្ឋានមុនហើយសរសេរឈ្មោះខេត្តនៃស្រុកនោះក្នុងវង់ក្រចក ។ បើអ្នកឆ្លើយបានឆ្លើយថាបានស្នាក់នៅក្រៅប្រទេសកម្ពុជា សូមសរសេរឈ្មោះប្រទេសនោះ ។ *ត្រូវកត់សំគាល់ថា ទោះបីមនុស្សម្នាក់បានកើតនៅទីកន្លែងជំរឿន តែបានផ្លាស់កន្លែងជាបន្តបន្ទាប់ទៅនៅភូមិផ្សេងទៀតដើម្បីធ្វើការឬសិក្សា ហើយបានត្រឡប់មកវិញជាថ្មីមកនៅត្រង់ទីកន្លែងជំរឿនវិញក៏ដោយ ក៏គាត់ត្រូវបានចាត់ទុកថាមានកន្លែងស្នាក់នៅមួយទៀតមុនជំរឿនគាត់នៅទីនេះ ។*

## បង្គោល 11 : រយៈពេលស្នាក់នៅ

១1. សំណួរអំពីរយៈពេលស្នាក់នៅ សំដៅដល់រយៈពេលស្នាក់នៅក្នុងភូមិធ្វើជំរឿនតាំងពីមកពីអាស័យដ្ឋានមុននិងចុងក្រោយ ។ សំណួរនេះ "តើលោក-អ្នកបានស្នាក់នៅក្នុងភូមិនេះបានប៉ុន្មានឆ្នាំហើយ ? "ត្រូវលើកមកសួរផ្ទាល់ បើនៅក្នុងបង្គោល 10 មានបញ្ជាក់ទីកន្លែងនៃលំនៅដ្ឋានចុងក្រោយ គឺភូមិណាមួយនៅក្នុងប្រទេសកម្ពុជា ឬ ក្នុងប្រទេសមួយក្រៅប្រទេសកម្ពុជា ។ ម្យ៉ាងទៀតចំឡើយក្នុងបង្គោល 10 មិនមែនលេខកូដ 1 ទេ ។ ត្រូវកត់ចូលបង្គោល 11 ដោយប្រើលេខកូដសំរាប់រយៈពេលស្នាក់នៅក្នុងបង្គោល 11 តាមលេខកូដដែលបានផ្ដល់ក្នុងតារាងសំណួរ ។ បើចំលើយក្នុងបង្គោល 10 ជាលេខកូដ 1 អ្នកចុះសំភាសន៍ត្រូវសរសេរ (-) ក្នុងបង្គោល 11 ។

១1.1 បើមនុស្សម្នាក់បានឆ្លើយថា បានមកស្នាក់នៅក្នុងភូមិធ្វើជំរឿននេះ (តាំងពីបានត្រឡប់មកពីលំនៅដ្ឋានចុងក្រោយបង្អស់ ) មានរយៈពេលតិចជាង 1 ឆ្នាំ សូមសរសេរលេខកូដ " 00" ។ បើរយៈពេលស្នាក់នៅក្នុងភូមិនេះពី 1 ឆ្នាំទៅតិចជាង 2ឆ្នាំ សូមកត់លេខកូដ " 01 " ។ បើរយៈពេលស្នាក់ក្នុងភូមិនេះពី 2 ឆ្នាំទៅតិចជាង 3 ឆ្នាំ នោះសូមកត់លេខកូដ " 02 " ...។ល។ ចំពោះរយៈពេលស្នាក់នៅពី ៩8 ឆ្នាំឡើងទៅសូមកត់ចូលតែ ៩8 ឆ្នាំតែប៉ុណ្ណោះ ។

## បង្គោល 12: មូលហេតុនៃអន្តោប្រវេសន៍

92. "អន្តោប្រវេសន៍ " អន្តោប្រវេសន៍នៅពេលនេះមានន័យថាបានផ្លាស់ពីភូមិ ( ឬប្រទេស ) ដែលជាទីកន្លែងស្នាក់នៅចុងក្រោយបង្អស់មករស់នៅភូមិដែលធ្វើជំរឿន ។ ចំពោះមនុស្សដែលអ្នកសំភាសន៍បានអោយលេខកូដក្រៅពី 1 ក្នុងបង្គោល 10 ហើយអ្នកសំភាសន៍ក៏បានកត់ចូលលេខកូដរយៈពេលស្នាក់នៅក្នុងបង្គោល 11 នោះអ្នកសំភាសន៍ត្រូវកត់ចូលនូវមូលហេតុនៃអន្តោប្រវេសន៍របស់មនុស្សនោះ ដោយចុះលេខកូដមួយក្នុងចំណោមលេខកូដពិតប្រាកដដែលមានក្នុងបញ្ជីលេខកូដសំរាប់បង្គោល 12 ដូចដែលបានផ្តល់អោយនៅខាងក្រោមបង្គោលចំពោះមនុស្សម្នាក់ដែលអ្នកចុះសំភាសន៍បានឱ្យលេខកូដ 1 ក្នុងបង្គោល 10 អ្នកចុះសំភាសន៍ត្រូវគូសសញ្ញា (-) ក្នុងបង្គោល 12 ។ មូលហេតុដែលបានផ្តល់សុទ្ធតែស្រួលហើយងាយយល់ ។ លេខកូដ 5 ( គ្រួសារផ្លាស់ទីកន្លែង ) ត្រូវមានសេចក្តីអធិប្បាយមួយ ។ បើសមាជិកនៃគ្រួសារមួយបានផ្លាស់ទីកន្លែងមករស់នៅត្រង់ភូមិធ្វើជំរឿន ដោយមូលហេតុគ្រួសារទាំងមូលបានផ្លាស់ទីកន្លែងនោះលេខកូដសំរាប់ចំលើយនេះគឺមានស្រាប់ ។ ឱ. បើ វត្ថា បានផ្លាស់ប្តូរទីលំនៅដោយសារការផ្ទេរការងាររបស់គាត់នោះ សូមចុះលេខកូដ 1 សំរាប់គាត់។ ចំពោះប្រពន្ធនិងកូនគាត់ដែលត្រូវផ្លាស់ទីកន្លែងមកជាមួយគាត់ដែរនោះ មូលហេតុអន្តោប្រវេសន៍ គឺគ្រួសារបានផ្លាស់ប្តូរទីកន្លែង (5) មិនមែនផ្ទេរទីកន្លែងការងារទេ (1) ។ តែបើប្រពន្ធគាត់ឬកូនប្រុស ឬ កូនស្រីគាត់បានផ្តល់មូលហេតុដាច់ដោយឡែកពីគ្នាពីការប្តូរទីលំនៅមកនៅកន្លែងនេះដូចជា " រកការងារធ្វើ " ឬ " ការសិក្សា " អ្នកសំភាសន៍ត្រូវចុះលេខកូដសមស្របដល់លោក អ្នកនោះ ។ កត់ចូលលេខកូដ 7 ( មាតុភូមិនិវត្តន៍ ឬមកស្រុកកំណើតវិញ ) ដល់ជនណាដែលបានធ្វើមាតុភូមិនិវត្តន៍ដោយភ្នាក់ងារផ្លូវការណាមួយ ឬ ដល់ជនណាដែលបានត្រឡប់មកស្រុកកំណើតខ្លួនវិញបន្ទាប់ពីបានចាកចេញពីមុនមកដោយសារជំលោះផ្ទៃក្នុងឬដោយហេតុផលនយោបាយ ។ ចំពោះមូលហេតុណាមួយក្រៅពីលេខកូដទាំង 8 នោះ សូមចុះលេខកូដ �9 ហើយសរសេរមូលហេតុក្នុងបង្គោលនេះ ។ សូមកត់សំគាល់ថាប្រើលេខកូដ 9 សំរាប់តែមូលហេតុណាមួយនៃអន្តោប្រវេសន៍ដែលមិនស្ថិតក្នុងចំណោមលេខកូដ 1 ដល់លេខកូដ 8 ដែលមានក្នុងបញ្ជីនេះ ។ ឧទាហរណ៍: បើមនុស្សម្នាក់ធ្វើមាតុភូមិនិវត្តន៍ឬត្រឡប់មកស្រុកកំណើតវិញ អ្នកសំភាសន៍ត្រូវចុះលេខកូដ 7 ជូនគាត់និងសូមកុំសរសេរលេខកូដ 9 ( មាតុភូមិនិវត្តន៍ )។

## បង្គោល 13: អក្ខរភាព

93. អក្ខរភាពគឺភាពដែលអាចអាន សរសេរនិងយល់ដឹងនូវភាសាណាមួយ ។ មនុស្សម្នាក់ជាមនុស្សចេះអក្សរនៅពេលដែលគាត់អាចអានសរសេរសំបុត្រស្រួលៗក្នុង ភាសាណាមួយ ឬ ភាសាគ្រាមហ៍ណាមួយ ។ មនុស្សម្នាក់ដែលមិនអាចអាន និងសរសេរសំបុត្រស្រួលៗបានចាត់ទុកជាអនក្ខរជន ។ គេចាត់ទុកជា

អនក្ខរជនផងដែរចំពោះមនុស្សដែលអាចមើលបានតែឈ្មោះខ្លួន ឬលេខ និងមនុស្សដែលអាចអានបានតែសរសេរមិនកើត ឬសរសេរកើតតែអានមិនបាន ។

93.1 មនុស្សម្នាក់ដែលអាចអាន និងសរសេរបាន តែនៅពេលធ្វើជំរឿនគាត់មិនអាចអាន និងសរសេរបានយូរដោយហេតុមកពីរាងកាយទ្រុឌទ្រោម ឬមានជំងឺនោះក៏នៅតែចាត់ទុកថាអ្នកចេះអក្សរដែរ ។ ខ. មនុស្សចាស់ជរាម្នាក់តាមពិតគាត់ចេះអានសរសេរ តែពេលធ្វើជំរឿនគាត់មិនអាចសំដែងសកម្មភាពនេះបាន ដោយហេតុមកពីគាត់ងងឹតភ្នែកនោះចាត់ទុកថាគាត់ជាអក្ខរជនដែរ ។

93.2 ជនពិការដែលអាចអាន និងសរសេរបានតាមមធ្យោបាយណាមួយដូចជាប្រព័ន្ធ (Braille) សំរាប់មនុស្សខ្វាក់ក៏ចាត់ទុកជាអ្នកចេះអក្សរដែរ ។

93.3 ចំពោះសំណួរនេះសូមកត់ចូលលេខកូដ 1 សំរាប់មនុស្សដែលបានឆ្លើយថា "ចេះ" ហើយលេខកូដ 2 សំរាប់មនុស្សដែលឆ្លើយថា "មិនចេះ"។ ចំពោះកុមារដែលមានអាយុ 6 ឆ្នាំ ឬតិចជាងត្រូវចាត់ទុកជាអនក្ខរជនទោះបីជាកុមារនោះកំពុងទៅសាលារៀនឬចេះអាន ឬចេះសរសេរពាក្យ ពីរ បីម៉ាត់ ក៏ដោយ ។

**បង្គោល 14 : រយៈពេលសិក្សាពេញលេញ**

94 រយៈពេលសិក្សាពេញលេញ សំដៅដល់ការអប់រំក្នុងស្ថាប័នអប់រំណាមួយដូចជា សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ ។ល។

**បង្គោល 14 "ក" : តើលោកអ្នកធ្លាប់បានចូលសិក្សាក្នុងសាលារៀន /គ្រឹះស្ថានអប់រំណាមួយដែរឬ ទេ ?**

95. សំណួរនេះអនុវត្តបានទាំងអ្នកចេះអក្សរនិងអ្នកមិនចេះអក្សរ ។ ចំលើយចំពោះសំណួរនេះត្រូវកត់ចូលដូចតទៅ :

ក. មិនដែលសោះ : សូមកត់ចូលលេខកូដ 1 បើមនុស្សនោះមិនដែលបានទទួលការសិក្សានៅក្នុងពេលណាមួយសោះ ។

ខ. បច្ចុប្បន្ន : សូមចុះលេខកូដ 2 បើមនុស្សនោះនៅកំពុងរៀន នៅពេលធ្វើជំរឿន ។

គ. អតីតកាល : សូមកត់ចូលលេខកូដ 3 បើមនុស្សនោះបានទទួលរយៈពេលសិក្សាពីអតីតកាល ហើយមិនបានបន្តនៅពេលបច្ចុប្បន្ន ។

សូមកត់សំគាល់ថា អាចមានមនុស្សម្នាក់ដែលចេះអក្សរ (លេខកូដ 1 ក្នុងបង្គោល 13 ) តែមិនដែលបានចូលសាលារៀនណាមួយសោះ (ឧ. គាត់បានរៀនអាន សរសេរនៅសាលាវត្ត ) ហេតុនេះត្រូវចុះលេខកូដ 1 ក្នុងបង្គោល 14 "ក" ។

### បង្គោល 14 "ខ" : តើអ្នកបានទទួលកំរិតវប្បធម៌ខ្ពស់បំផុតត្រឹមណាដែរ?

96. សូមគូសសញ្ញា (-) ក្នុងបង្គោលតូចៗក្នុងករណីមនុស្សម្នាក់មិនធ្លាប់បានចូលសិក្សាក្នុងសាលារៀន / គ្រឹះស្ថានអប់រំណាមួយ ( លេខកូដ 1 ក្នុងបង្គោល 14 ( ក ) ) ។ គេបានផ្តល់ប្រភេទកំរិតវប្បធម៌ខ្ពស់បំផុតដែលបានសិក្សាក្នុងសាលាបឋមសិក្សា អនុវិទ្យាល័យ ឬ វិទ្យាល័យ ឬ គ្រឹះស្ថានអប់រំផ្សេងទៀតណាមួយ ដែលអ្នកឆ្លើយបានចូលរៀនសំរាប់ធ្វើការកត់ចូល ។ ប្រភេទលេខកូដចុងក្រោយមួយ " កំរិតសិក្សាផ្សេងទៀត (បញ្ជាក់) " (លេខកូដ 17 ) ត្រូវគេរាប់បញ្ចូលដើម្បីកត់យកប្រភេទអប់រំផ្សេងទៀតដែលមិនបានបញ្ជាក់ ។ ជាទូទៅ អ្នកសំភាសន៍ត្រូវពិនិត្យថាតើកំរិតសិក្សាដែលទទួលបានរបស់មនុស្សម្នាក់សមស្របនិងអាយុរបស់លោក អ្នក នោះទេ ។ ឧទាហរណ៍ កុមារា ឬ កុមារី មានអាយុ 8 ឆ្នាំមិនសមទទួលបានកំរិតសិក្សាថ្នាក់ទី 11 ទេ ។ បើមានការមិនសមស្របបែបនេះ សូមសួរសំណួរបញ្ជាក់និងបញ្ជាក់យកចំលើយត្រឹមត្រូវ ។

### បង្គោល 15 ដល់ 20 ស្តីពីលក្ខណៈសេដ្ឋកិច្ចនៃប្រជារាស្ត្រ

97. បង្គោលទាំងនេះទាក់ទងទៅនឹងលក្ខណៈសេដ្ឋកិច្ចរបស់ប្រជារាស្ត្រទាំងប្រុសទាំងស្រី ។ សំណើដែលសុំឱ្យប្រមូលយកពត៌មានស្តីពីលក្ខណៈសេដ្ឋកិច្ចប្រជារាស្ត្រ នោះរាប់ទាំងពត៌មានពីសកម្មជនសេដ្ឋកិច្ច និងអសកម្មជនសេដ្ឋកិច្ច ។ សកម្មជនសេដ្ឋកិច្ចរួមមាន : អ្នកដែលមានការងារធ្វើ និង អ្នកគ្មានការងារធ្វើ។ អសកម្មជនសេដ្ឋកិច្ចរួមមាន: អ្នកធ្វើការផ្ទះ សិស្ស និស្សិតរៀនពេញពេល អ្នកនៅក្នុងបន្ទុក អ្នករស់នៅដោយការជួលអចលនវត្ថុ ជនចូលនិវត្តន៍ និង អ្នកទទួលប្រាក់ចំណូល ផ្សេងទៀត និង អ្នកផ្សេងទៀតដែលមិនមែនជាអ្នកមានការធ្វើ ឬ ក៏គ្មានចូលក្នុងប្រភេទអសកម្មជនណាមួយដែលបានចែងខាងលើ ។ រយៈពេលកំណត់ចំពោះសំណួរនេះគឺសួរពី 12 ខែកន្លងមក ។

### បង្គោល 15 សកម្មភាពសំខាន់ៗក្នុងឆ្នាំកន្លងមក

98. ដំបូងយើងចង់ដឹងអំពីអ្វីដែលជាសកម្មភាពសំខាន់ៗរបស់មនុស្សក្នុងកំឡុងពេលមួយឆ្នាំមុនយប់ធ្វើជំរឿន ។ សកម្មភាពសំខាន់ៗមានន័យថាជាសកម្មភាពចំបងដែលគេបានធ្វើក្នុងរយៈពេល 6 ខែ (183 ថ្ងៃ) ឡើងទៅក្នុងមួយឆ្នាំកន្លងមក ( ឧទាហរណ៍ ជាសកម្មភាពដែលបានប្រើពេលវេលាដ៏ច្រើនក្នុងមួយឆ្នាំកន្លងមក) ។ តារាងលេខកូដមានផ្តល់ជូនស្រាប់ដែលអ្នកសំភាសន៍ត្រូវប្រើនៅពេលបានទទួលចំលើយពីសំនួរនេះ ។

## អ្នកមានការងារធ្វើ

98.1 " អ្នកមានការងារធ្វើ " គឺជាមនុស្សទាំងអស់ ដែលស្ថិតក្នុងប្រភេទខាងក្រោមហើយដែលបានធ្វើការក្នុងរយៈពេល 6 ខែ (183 ថ្ងៃ ) ឬ រយៈពេលច្រើនជាងក្នុងកំឡុងពេល 1 ឆ្នាំ កន្លងមក :

ក. មនុស្សដែលបានទទួលប្រាក់បៀវត្សពីការងារ (ឧ. កំពុងធ្វើការងារនៅក្នុងអង្គភាពសាធារណៈ ឬ ឯកជន ។ល។ )

ខ. មនុស្សដែលបានធ្វើការងារខ្លះក្នុងរយៈពេលកំណត់ ដោយមានប្រាក់បំណាច់ មានប្រាក់បៀវត្ស មានផលចំណេញ ឬ ប្រាក់កំរៃក្នុងគ្រួសារជាប្រាក់ ឬ ជាវត្ថុ ។

គ. មនុស្សដែលមិនបានធ្វើការណាមួយដើម្បីប្រាក់បំណាច់ ឬ ប្រាក់កំរៃក្នុងរយៈពេលកំណត់ ទោះបីជាគេមានការងារដែលគេគួរតែទទួលប្រាក់កំរៃ ( ឧ. អ្នកធ្វើការតាមរដូវ ដូចជា អ្នកស្រែចំការ ឬ អ្នកនេសាទ ) ជនមានជម្ងឺទទួលការសំរាកព្យាបាល ឬ ទទួលការសំរាក ដោយគ្មានទទួលប្រាក់បៀវត្ស ជនដែលមិនអាចធ្វើការបានដោយហេតុមកពីកុប្បកម្ម ឬ ការបិទទ្វារអង្គភាពដែលពួកគេកំពុងធ្វើការ ។

ឃ. មនុស្សដែលធ្វើការងារសំរាប់ខ្លួនឯង (ឧ. បើកហាង១ដោយខ្លួនឯងលក់គ្រឿងបរិភោគ បើកអនុវត្តវិជ្ជាជីវៈផ្ទាល់ខ្លួន ជាវេជ្ជបណ្ឌិត ជាមេធាវី ។ល។ ) ។

98.2 គេបានអោយនិយមន័យ " ការងារ " គឺជាសកម្មភាពផលិតកម្មក្នុងសេដ្ឋកិច្ចដែលមនុស្សម្នាក់ធ្វើដើម្បីប្រាក់បំណាច់ (ជាប្រាក់ ឬ ជាវត្ថុ នៅក្នុងគ្រឹះស្ថាន ការិយាល័យ ទីផ្សារ ស្រែចំការ ផ្ទះឯកជនណាមួយ ) ឬ ដើម្បីប្រាក់ចំណេញ ឬ មិនទទួលប្រាក់បំណាច់នៅលើស្រែចំការ ឬ សហគ្រាសប្រចាំគ្រួសារ ។ អ្នកធ្វើការងារ ( ផ្សេងពីករណីអ្នកធ្វើការប្រចាំគ្រួសារ ឬផ្ទះពាណិជ្ជកម្មប្រចាំគ្រួសារមិនទទួលប្រាក់បំណាច់ប្រាក់បៀវត្ស) ត្រូវទទួលប្រាក់បំណាច់ឬប្រាក់ចំណេញជាប្រាក់ ឬ ជាវត្ថុសំរាប់សកម្មភាពរបស់គេ ។ សកម្មភាពដែលមិនទទួលប្រាក់បៀវត្សហើយដែលមិនរួមចំណែកដល់ពាណិជ្ជកម្មប្រចាំគ្រួសាររបស់ខ្លួនដូចជា ការងារសង្គមកិច្ចស្ម័គ្រចិត្ត ឬ ជំនួយដល់សហគមន៍ស្ម័គ្រចិត្តនោះមិនត្រូវបានចាត់ទុកជា " ការងារ " សំរាប់គោលបំណងជំរឿននេះទេ ។ តាមសារជាតិ ការងារអាចជាការងារដោយកំលាំងកាយ ឬ ដោយកំលាំងបញ្ញា ។ ការងារមិនគ្រាន់តែទាក់ទងទៅនឹងការងារជាក់ស្តែងប៉ុណ្ណោះទេ តែថែមទាំងមានការងារត្រួតពិនិត្យ ការងារដឹកនាំផងដែរ ។ មានសារៈប្រយោជន៍ណាស់ដែលត្រូវកត់សំគាល់ថា ត្រូវរាប់បញ្ចូលទាំងការងារអត់ទទួលប្រាក់កំរៃលើស្រែចំការ ឬ សហគ្រាសប្រចាំគ្រួសារ ។ អ្នកសំភាសន៍ត្រូវសួរសំណួរបញ្ជាក់ ដើម្បីធ្វើអោយប្រាកដនូវភាពមានការងារធ្វើ ឬបានបំរើការងារ ឬ ការងារដោយមិនទទួលប្រាក់កំរៃលើស្រែចំការរបស់គ្រួសារ ឬ លើសហគ្រាសក្នុងកំឡុងពេល១ឆ្នាំកន្លងមក ។ សូមកុំសន្មតថា ស្ត្រីជាទូទៅជាអ្នកធ្វើការនៅផ្ទះ ។ អ្នកសំភាសន៍ត្រូវសួរបញ្ជាក់សំណួរដល់ស្ត្រីថា តើស្ត្រីទាំង

នោះកំពុងធ្វើការឬទេ ។ សូមចងចាំថា នៅជនបទ បុរសភាគច្រើនបានបំរើការងារក្នុងការដាំដុះ ជាមួយនោះប្រពន្ធ និង កូនស្រីរបស់គេក៏ចូលរួមជាអ្នកធ្វើការប្រចាំគ្រួសារមិនទទួលប្រាក់បំណាច់ក្នុងការដាំដុះដែរ ។ ស្ត្រីបែបនោះត្រូវចាត់ទុកថាកំពុងធ្វើការងារ ទោះបីគេជាអ្នកធ្វើការនៅផ្ទះ ឬ ជាមេផ្ទះដែលជាកាតព្វកិច្ចបំរើនៅក្នុងផ្ទះក៏ពិតមែន ។ អ្នកសំភាសន៍ ត្រូវប្រុងប្រយ័ត្នបំផុតកុំធ្វើកំហុសនេះ ។ ដូចគ្នាដែរចំពោះកុមារដែលបានធ្វីការ ត្រូវចាត់ទុកជាអ្នកមានការងារធ្វើ ។

98.3 តើមានលក្ខណៈដូចម្តេចដែរចំពោះបុរស ឬ ស្ត្រីបានធ្វើការក្នុងផលិកម្មទំនិញសំរាប់ប្រើប្រាស់ និង បរិភោគខ្លួនឯងផ្ទាល់ខ្លួន ? សូមកត់សំគាល់ថាសកម្មភាពសំរាប់ការប្រើប្រាស់ខ្លួនឯងផ្ទាល់ដូចតទៅនេះក៏ត្រូវបានចាត់ទុកថាជាការងារដែរ:

(i) ផលិតផលិតផលដំបូងសំរាប់ប្រើប្រាស់ និង បរិភោគខ្លួនឯងផ្ទាល់ដូចជាការដាំដុះគ្រាប់ធញ្ញជាតិ ឬ បន្លែបង្កាសំរាប់ប្រើប្រាស់ និង បរិភោគខ្លួនឯងផ្ទាល់ ។

(ii) ការដងទឹកនិងរកឧសសំរាប់ប្រើប្រាស់ខ្លួនឯងផ្ទាល់ ។

(iii) ការកែរបស់ប្រើប្រាស់ដំបូងសំរាប់ប្រើប្រាស់និងបរិភោគខ្លួនឯងផ្ទាល់នៃមុខផលិតផលទាំងនេះ ( ដូចជាការហាលបន្លែផ្ទាល់ខ្លួនដែលដាំសំរាប់ទុកប្រើប្រាស់និងបរិភោគនៅពេលខាងមុខ ) ។

(iv) ផលិតទ្រព្យសម្បត្តិសំរាប់ប្រើប្រាស់ខ្លួនឯងផ្ទាល់ ( ដូចជាការសង់អគារ ផ្ទះ ឬ សង់ភ្លឺស្រែឬទប់ទំនប់សំរាប់ដាំស្រូវ ) ។

98.4 សកម្មភាពនានាសំរាប់ការប្រើប្រាស់និងខ្លួនឯងផ្ទាល់ផ្សេងទៀតក្រៅពីសកម្មភាពខាងលើនេះមិនចាត់ទុកថាជាការងារទេ (ឧ. ចំអិនម្ហូបអាហារសំរាប់ខ្លួនឯង និង គ្រួសារ បោកអ៊ុតសំលៀកបំពាក់សំរាប់ខ្លួនឯង និង គ្រួសារ ។ល។ ) ។ បើសិនមនុស្សម្នាក់ត្រូវបានគេជួលឱ្យធ្វើការតែនៅជាមួយគ្នាគាត់ក៏បានធ្វើការនៅផ្ទះដូចជា បោសសំអាតអោយគ្រួសារ ឬ នៅសាលារៀន ។ល។ ជាមូលដ្ឋានចាត់អ្នកនោះថាមានការងារធ្វើ ។

98.5 បើសិនអ្នកសំភាសន៍កត់ចូលកូដលេខ 1 សំរាប់មនុស្សម្នាក់ក្រោយពីបានអនុវត្តតាមការណែនាំខាងលើ អ្នកសំភាសន៍ត្រូវបំពេញបង្គោល 16 ដល់ 20 ដែលមានការពណ៌នាដូចតទៅនេះ ។

## អ្នកគ្មានការងារធ្វើ

98.6 បើសិនមនុស្សម្នាក់ ( ប្រុសឬស្ត្រី ) ជាមនុស្សគ្មានការងារធ្វើ អ្នកសំភាសន៍ត្រូវសួរថា ក្នុងរយៈពេលមួយឆ្នាំកន្លងមក តើលោក_អ្នកឥតមានការងារធ្វើដល់ទៅ 6ខែ ( ឬ 183ថ្ងៃ ) ឬច្រើនជាង 6 ខែ ? អ្នកគ្មានការងារធ្វើសំដៅដល់អ្នកមិនមានការងារតែកំពុងរកការងារ ឬ នៅទំនេរដើម្បីការងារ ។

98.7 សូមកត់សំគាល់ថា អ្នកធ្វើការក្នុងផ្ទះ (មេផ្ទះ ) សិស្ស និស្សិត និង អ្នកផ្សេងទៀតដែលបានចូលរួមក្នុងសកម្មភាពមិនមែនសេដ្ឋកិច្ចក្នុងរយៈពេលកំណត់ ហើយអ្នកដែលមិនបានបំពេញលក្ខខ័ណ្ឌដូចខាងលើត្រូវចាត់ទុកជាអ្នកគ្មានការងារធ្វើ គឺមិនមែនជាអ្នកធ្វើការក្នុងផ្ទះ សិស្ស និស្សិតទេ ។ល។ បើមនុស្ស ឆ្លើយថាគាត់គ្មានការងារធ្វើទេ ចំពោះផ្នែកសំខាន់មួយឆ្នាំកន្លងមក តាមលក្ខណ្ឌអ្នកគ្មានការងារធ្វើអ្នកសំភាសន៍ត្រូវសួរមនុស្សនោះ ថាតើគាត់មានបានបំរើការងារពីមុនមកដែរឬទេ មុនដែលគាត់ក្លាយខ្លួនជាអ្នកគ្មានការងារធ្វើនៅពេលបច្ចុប្បន្ននេះ ។ បើគាត់ឆ្លើយថា “មានធ្វើការពីមុន ” អ្នកសំភាសន៍ត្រូវចុះលេខកូដ 2 សំរាប់មនុស្សនោះ ក្នុងបង្គោល 15 ។ ម្យ៉ាងទៀតបើមនុស្សនោះឆ្លើយថាគាត់មិនដែលបំរើការងារសោះ កំពុងតែរកការងារធ្វើជាលើកដំបូង ហើយមិនដែលបានបំរើការងារនៅពេលណាមួយពីមុនមក អ្នកសំភាសន៍ត្រូវចុះលេខកូដ 3 ក្នុងបង្គោល 15 ។ ក្នុងករណីនៃអ្នកគ្មានការងារ តែអ្នកនោះបានបំរើការងារនៅពេលណាមួយពីមុនមក ( កូដលេខ 2 ក្នុងបង្គោល 15 ) អ្នកសំភាសន៍ត្រូវបំពេញក្នុងបង្គោល 16-20អំពីលក្ខណៈមុខរបរចុងក្រោយ ។ ក្នុងករណីលេខកូដ 3 ក្នុងបង្គោល 15 សូមគូសសញ្ញា (-) ក្នុងបង្គោលនីមួយៗពីបង្គោល 16 ដល់ 20 ។

## ប្រជាពលរដ្ឋអសកម្ម ( អសកម្មជន)

98.8 អ្នកមានការងារធ្វើ និង អ្នកគ្មានការងារធ្វើរួមគ្នាមកបានជាសកម្មជនសេដ្ឋកិច្ច ។ មនុស្សដែលមិនបានចូលបំរើការងារ ឬ គ្មានការងារធ្វើហើយបានចំណាយពេលវេលាជាអ្នកធ្វើការក្នុងផ្ទះ សិស្ស និស្សិត ។ល។ នោះមិនចាត់ទុកថា សកម្មជនសេដ្ឋកិច្ចទេ ពោលគឺចាត់ទុកថាជាអសកម្មជន ។ សូមប្រើលេខកូដនៅក្នុងតារាងដែលមានស្រាប់សំរាប់ធ្វើការកត់ចូលនូវប្រភេទមនុស្សអសកម្មក្នុងរយៈពេល 6ខែ (ឬ 183ថ្ងៃ ) ឬក៏ច្រើនជាងកាលពីមួយឆ្នាំកន្លងមក ។

98.9 ប្រភេទអសកម្មជនមានបញ្ជាក់ខាងក្រោមនេះ :

- **អ្នកធ្វើការផ្ទះ** ជាអ្នកដែលបំរើការងារតែម្នាក់ឯងក្នុងរយៈពេលមួយជាកំណត់ ហើយកិច្ចការនោះជាកិច្ចការគ្រួសារក្នុងផ្ទះរបស់ខ្លួន ។ ចំពោះប្រភេទនេះ សូមចុះលេខកូដ 4 ក្នុង បង្គោល 15 ។
- **សិស្ស និស្សិត** គឺជាអ្នកដែលកំពុងសិក្សាក្នុងសាលារៀន / ស្ថាប័នអប់រំ ។ ចំពោះប្រភេទនេះ សូមចុះលេខកូដ 5 ក្នុងបង្គោល 15 ។
- **អ្នកស្ថិតក្នុងបន្ទុក :** ប្រភេទនេះរាប់បញ្ចូលអ្នកដែលរស់នៅដោយពឹងពាក់អាស្រ័យទាំងស្រុងក្នុងគ្រួសារដូចជាទារក កុមារមិនទាន់ចូលរៀន មនុស្សពិការជាអចិន្ត្រៃ ដែលមិនអាចប្រកបការងារអ្វីបាននឹងមនុស្សដែលធ្វើការមិនកើតដោយហេតុមានជំងឺ ឬ ជរា ។ អ្នកស្ថិតនៅក្នុងបន្ទុក ក៏រួមមានអ្នកដែលមានរាងកាយគ្រប់គ្រាន់ តែគេមិនអាចចាត់បញ្ចូលក្នុងប្រភេទអសកម្មជនណាមួយ ហើយជាអ្នករស់នៅដោយ

ស្ថិតនៅក្នុងបន្ទុកអ្នកឯទៀត ។ យ៉ាងណាក្តី មនុស្សបានរកការងារធ្វើ ឬ នៅទំនេររង់ចាំមានការងារធ្វើ ត្រូវរាប់បញ្ចូលក្នុងអ្នកគ្មានការងារធ្វើ មិនមែនជាអ្នកនៅក្នុងបន្ទុកទេ ។ ចំពោះមនុស្សដែលស្ថិតក្នុងបន្ទុក សូមចុះលេខកូដ 6 ក្នុងបង្គោល 15 ។

- **អ្នករស់នៅដោយការជួលអចលនវត្ថុ ជនចូលនិវត្តន៍ ឬ អ្នកទទួលប្រាក់ចំណូលផ្សេងទៀត :** មនុស្សម្នាក់ដែលបានចូលនិវត្តន៍ពីសេវាកម្ម ហើយគ្មានធ្វើការអ្វីផ្សេងទៀត ឧ. មិនបានបំរើការងារថ្មីក្នុងការងារខ្លះ ឬមិនបានចូលបំរើក្នុងការងារខ្លះផ្សេងទៀត ដូចជាដាំដុះ ពាណិជ្ជកម្ម ជំនួញលក់ដូរ ។ល។ ឬ មនុស្សនេះជាអ្នករស់ដោយការជួលអចលនវត្ថុ ឬ រស់ដោយថ្លៃឈ្នួលខាងកសិកម្ម ឬមិនមែនខាងកសិកម្ម ជួល ឬ ប្រាក់ចំណេញ ដែលមិនបានធ្វើការងារ ឬ អ្នកគ្មានការងារធ្វើ ឬ មនុស្សផ្សេងទៀតណាមួយនៃអ្នកមិនពឹងពាក់គេ មានន័យថាអ្នកទាំងនោះគ្មានខ្វះខាតអ្វីដោយមិនបានធ្វើការងារនឹងត្រូវរាប់បញ្ចូលក្នុងប្រភេទនេះ ។ អ្នកត្រូវចុះលេខកូដ 7 ក្នុង បង្គោល 15 ចំពោះប្រភេទនៃអសកម្មជននេះ។

- **ផ្សេងៗទៀត (សូមបញ្ជាក់)** : ប្រភេទនេះនឹងរាប់បញ្ចូលអសកម្មជនទាំងអស់ ដែលមិនអាចចូលក្នុងប្រភេទទាំងបួនខាងលើនៃអសកម្មជន ។ ចំពោះមនុស្សបែបនេះ ( ឧ. អ្នកសុំទាន ) អ្នកត្រូវចុះលេខកូដ 8 ហើយបញ្ជាក់ (ឧ. 8 អ្នកសុំទាន ) ក្នុងបង្គោល 15 ។

## បង្គោល 16 ដល់ 20

99. ពត៌មានក្នុងបង្គោលនេះត្រូវបំពេញតែចំពោះមនុស្សដែលមានការងារធ្វើ ( លេខកូដ 1 ក្នុងបង្គោល 15 ) ឬ គ្មានការងារធ្វើ ( មានការងារធ្វើពីមុន ) ឧ. លេខកូដ 2 ក្នុងបង្គោល 15 ។ ចំពោះអ្នកគ្មានការងារធ្វើ ( មិនបានបំរើការងារពីមុន ) ឧ. លេខកូដ 3 ក្នុងបង្គោល 15 ហើយជាអសកម្មជន ឧ.លេខកូដណាមួយពីលេខកូដ 4 ដល់ 8 ក្នុងបង្គោល 15 គេមិនត្រូវបំពេញពត៌មានទេក្នុងបង្គោល 16 ដល់ 20 តែត្រូវគូសសញ្ញា (-) ក្នុងបង្គោលនីមួយៗក្នុងចំណោមបង្គោលទាំងនេះវិញ ។ សូមអនុវត្ត តាមសេចក្តីណែនាំបំពេញបង្គោល 16 ដល់ 20 សំរាប់មនុស្សដែលមានលេខកូដ 1 ឬ 2 ដែលបានផ្តល់ជូនក្នុងបង្គោល 15 ។ ពត៌មានដែលត្រូវបំពេញគឺទាក់ទងទៅនឹងភាពលំអិតនៃការងាររបស់មនុស្សដែលមានការងារធ្វើ ( លេខកូដ 1 ក្នុងបង្គោល 15 ) ។ ក្នុងករណីអ្នកគ្មានការងារធ្វើ ( មានការងារធ្វើពីមុន ) ឧ. លេខកូដ 2 ក្នុង បង្គោល 15 ពត៌មានត្រូវបំពេញគឺទាក់ទងទៅនឹងការងារចុងក្រោយដែលបានធ្វើដោយមនុស្សនោះ ។

## បង្គោល 16 : រយៈពេលបំរើការងារ

100. សូមចុះចំនួនខែ (បំពេញនូវខែដែលជិតជាងគេ) ដែលអ្នកឆ្លើយបានបំរើការងារក្នុងកំឡុងកាលបរិច្ឆេទក្នុង 12 ខែកន្លងមក ។ ក្នុងករណីលេខកូដ 1 ក្នុងបង្គោល 15 កត់ចូលក្នុងបង្គោល 16 ត្រូវសរសេរ 06, 07, 08, 09, 10, 11 ឬ 12 ខែក្នុងកាលបរិច្ឆេទ 12 ខែកន្លងមក ។ ក្នុងករណីលេខកូដ 2 ក្នុងបង្គោល 15 សូមកត់សំគាល់ថាអ្នកចុះសំភាសន៍ត្រូវកត់ចូលចំនួនខែដែលបានបំរើការងារក្នុងកាលបរិច្ឆេទ 12 ខែកន្លងមកក្នុងបង្គោល 16 ។ កត់ចូលត្រូវសរសេរ 00 ក្នុងបង្គោល 16 បើជននោះមិនបានបំរើការងារក្នុងកាលបរិច្ឆេទ 12 ខែកន្លងមក ។ កត់ចូល 01, 02, 03, 04, ឬ 05 បើជននោះបានបំរើការងារបាន 1, 2, 3, 4, ឬ 5 ខែក្នុងកាលបរិច្ឆេទ 12 ខែកន្លងមក ។

## បង្គោល 17 : អាជីព

101. អាជីពសំដៅដល់ឈ្មោះការងារដែលមនុស្សបានធ្វើ (ឧ. ហិរញ្ញិក គ្រូបឋមសិក្សា គិលានុបដ្ឋាក ជាងដែក ឆ្មាំ អ្នកគ្រប់គ្រង ។ល។ )

101.1 *អ្នកសំភាសន៍ត្រូវសរសេរអាជីពរបស់មនុស្សម្នាក់អោយបានច្បាស់និងពេញលេញតាមដែលអាចធ្វើទៅបាន ។ អ្នកសំភាសន៍មិនត្រូវសរសេរតែ "បុគ្គលិក" ។ សូមបញ្ជាក់បន្ថែមទៀត ដើម្បីរកអោយឃើញថា តើគាត់នោះ ជាស្មៀន អ្នកស្ថិតិ ឬ អ្នកវាយបញ្ចូលពត៌មាន ។ល។ និង ។ល។ សូមកុំសរសេរ "កម្មកររោងចក្រ" ដែលមិនច្បាស់នោះ ។ សូមរកអោយឃើញថាតើគាត់ជាជាងសំណង់ឬជាងកម្បាញ ។ល។ បើសិនមនុស្សម្នាក់និយាយថាគាត់បានប្រកបការងារផ្ទាល់ 2 ឬ 3 ការងារនោះ សូមរកអោយឃើញថាតើការងារណាដែលគាត់បានធ្វើច្រើនជាងគេ ហើយកត់យកការងារនោះ ។*

## បង្គោល 18 : ស្ថានភាពការងារ

102. ប្រភេទ 5 យ៉ាងត្រូវបានផ្តល់ចំពោះស្ថានភាពការងារ ឬ ថ្នាក់ ។ កាលណាអ្នកឆ្លើយគេឆ្លើយប្រាប់ពីស្ថានភាពការងាររបស់គេមួយក្នុងចំណោមស្ថានភាពការងារទាំងនេះ អ្នកសំភាសន៍ត្រូវកត់លេខកូដចូលឱ្យសមស្រប ។ សូមកត់សំគាល់ថា អ្នកសំភាសន៍ត្រូវកត់ចូលតែមួយលេខកូដចំពោះអ្នកឆ្លើយនិមួយៗ ។

(ក)- **និយោជក:** សូមកត់ចូលលេខកូដ 1 សំដៅមនុស្សម្នាក់ដែលបើកដំណើរការសហគ្រាសខ្លួនឯងដោយផ្ទាល់ ឬ តាមរយៈមនុស្សម្នាក់ទៀត (ឧ. អ្នកចាត់ការ ឬ អ្នកគ្រប់គ្រង) ហើយក្នុងកិច្ចដំណើរការសហគ្រាសគាត់ជាអ្នកដែលជួលនិយោជិកម្នាក់ ឬ ច្រើននាក់និងចំណាយប្រាក់បៀវត្សដល់អ្នកទាំងនោះ ។ សូមកត់សំគាល់ថាមនុស្សដែលចាត់ជានិយោជិក នៅទីនេះ គឺមិនសំដៅទៅលើអ្នកធ្វើការប្រចាំគ្រួសារមិនទទួលប្រាក់បៀវត្ស និង កូនជាងរៀនធ្វើការឡើយ ។

(ខ )- **និយោជិកទទួលប្រាក់បៀវត្ស** : សូមកត់ចូលលេខកូដ 2 ចំពោះមនុស្សម្នាក់ដែលធ្វើការអោយនិយោជកសាធារណៈ ឬ ឯកជន ហើយបានទទួលប្រាក់បៀវត្សពីនិយោជករបស់ខ្លួន។ អ្នកបំរើការងារវជ្ជាភិបាលទាំងអស់គឺជានិយោជិក ។ ការចំណាយដោយនិយោជកដល់និយោជិកអាចជាវត្ថុផងដែរ ។

(គ)- **អ្នកធ្វើការងារដោយប្រើខ្លួនផ្ទាល់ខ្លួន** : សូមដាក់ចូលលេខកូដ 3 ចំពោះមនុស្សម្នាក់ដែលបើកដំណើរការសហគ្រាសផ្ទាល់ខ្លួន (ឧ.អ្នកស្រែចំការដាំដុះលើដីរបស់ខ្លួន, អ្នកលក់ដូរ, វេជ្ជបណ្ឌិតឯកជន មេធាវី ដែលជាអ្នកអនុវត្តការងារដោយឯករាជ្យ ) ដោយគ្មានប្រើអ្នកណាម្នាក់ឱ្យធ្វើការងារសំរាប់គេនៅក្នុងកិច្ចដំណើរការសហគ្រាសរបស់គេ ។ គាត់មិនបានប្រើអ្នកណាមួយ ឬ មិនបានជួលអ្នកណាម្នាក់ (ឧ.អ្នកលក់ផ្លែឈើជាអ្នកធ្វើការលក់ដូររបស់ខ្លួនតែម្នាក់ឯង ) ។

(ឃ ) - **អ្នកធ្វើការងារសំរាប់គ្រួសារមិនយកប្រាក់បំណាច់** : សូមកត់ចូលលេខកូដ 4 ចំពោះមនុស្សម្នាក់បានជួយក្នុងការចាត់ចែងសហគ្រាសសេដ្ឋកិច្ចដែលបើកដំណើរការដោយសមាជិកនៃគ្រួសាររបស់ខ្លួន ដោយគ្មានទទួលយកប្រាក់ថ្លៃឈ្នួល ប្រាក់បៀវត្ស (ឧ.ប្រពន្ធដែលបានជួយប្ដីក្នុងការងារស្រែចំការ កូនស្រីដែលជួយក្នុងការងារត្បាញ ) ។

(ង) - **ផ្សេងទៀត ( សូមបញ្ជាក់** ): ចូលក្នុងប្រភេទនេះគឺសំដៅទៅលើគ្រប់មនុស្សដែលមិនធ្លាក់ចូលក្នុងក្រុមណាមួយក្នុងចំណោមក្រុមខាងលើ ។ អ្នកសំភាសន៍ត្រូវសរសេរចូលនូវស្ថានភាពការងាររបស់មនុស្សនោះ ក្នុងកន្លែងទំនេរទុកស្រាប់បន្ទាប់មកធ្វើការកត់ចូលកូដលេខ 5 ( ឧ - 5 កូនជាងរៀនធ្វើការ ) ។

## **បង្គោល 19 : សកម្មភាពសេដ្ឋកិច្ច ( ឧស្សាហកម្ម ពាណិជ្ជកម្ម ឬ សេវាកម្ម)**

103. អ្នកសំភាសន៍ត្រូវកត់ចូលនូវផ្នែកសកម្មភាពសេដ្ឋកិច្ចដែលមនុស្សម្នាក់ៗបានធ្វើការ ។ ឧទាហរណ៍: ការដាំដុះ នេសាទ ការចិញ្ចឹមសត្វ ការលក់ដូរបន្លែ ជួសជុលរថយន្ត កម្មន្តសាលប្រដាប់លេងសេវាកម្មដឹកជញ្ជូន សេវាកម្មប្រចាំសាលារៀន ឬ សេវាកម្មអប់រំ លក់សំពត់ ( លក់រាយ ) កម្មន្តសាលគ្រឿងបរិភោគ ។ល។ បើមនុស្សម្នាក់ធ្វើការជាអ្នកជំនួយលក់ដូរក្នុងស្ថានីយ៍ឧស្ម័នមួយ អាជីពគាត់ គឺអ្នកជួយលក់ ហើយលក្ខណៈ ពាណិជ្ជកម្មរបស់គាត់គឺលក់ប្រេងសាំង ( លក់រាយ ) ។ ផ្នែកក្រុមការងារនៃសេដ្ឋកិច្ចគឺ : (i) ការដាំដុះ នេសាទ ការចិញ្ចឹមសត្វ (ii) ការជីករ៉ែឬការជីកដីយកថ្ម (iii) កម្មន្តសាលកែច្នៃ សេវាកម្ម (iv) ការជួសជុល (v) សំណង់ (vi) ការផ្គត់ផ្គង់អគ្គិសនី ឧស្ម័ន ឬទឹក (vii) ដឹកជញ្ជូន និងទូរគមនាគមន៍ (viii) ពាណិជ្ជកម្មនិងជំនួញ និង.....(ix) សេវាកម្ម ដូចជា សេវាកម្មបំរើគ្រួសារ សេវាកម្មសាធារណៈ ។ល។ សូមប្រុងប្រយ័ត្នចំពោះចំលើយដូចជា រស្មីអង្គរនិងក្រុមហ៊ុន

ពាយ័ននិងក្រុមហ៊ុន ។ល។ ពីព្រោះបើត្រឹមតែឈ្មោះទាំងនេះប៉ុណ្ណោះ អ្នកសំភាសន៍មិនអាចកត់ចូលនូវប្រភេទសកម្មភាពសេដ្ឋកិច្ចនៃក្រុមហ៊ុនបានទេ ។ សូមសួរសំនួរនានាដើម្បីទទួលបានពត៌មានទាក់ទងទៅនឹងប្រភេទនៃផលិតផល (ឧ.កម្មន្តសាល បារី ) ឬ ប្រភេទពាណិជ្ជកម្ម ( លក់កាសែត ) ឬប្រភេទសេវាកម្ម (ឧ.កាត់សក់ អ៊ុតសក់) ដែលគ្រឹះស្ថាននោះ ឬ ក្រុមហ៊ុននោះបានបំរើការងារ ។ បើមនុស្សម្នាក់កំពុងធ្វើការក្នុងក្រុមហ៊ុនមួយដែលធ្វើសកម្មភាពច្រើននោះ សូមរាយការណ៍ពីប្រភេទសាខារបស់ក្រុមហ៊ុនដែលមនុស្សនោះកំពុងធ្វើការ ។ បើមនុស្សម្នាក់បានបំរើការងារក្នុងការិយាល័យរដ្ឋាភិបាល ឬ ស្ថាប័ននោះ ឈ្មោះរបស់ការិយាល័យ ទីភ្នាក់ងារ សាលារៀន ។ល។ ត្រូវបានកត់ចូល (ឧ ក្រសួងផែនការ នាយកដ្ឋានកសិកម្ម តុលាការកំពូល វិទ្យាល័យភ្នំពេញ ។ល។ )

## បង្គោល 20 : ផ្នែកការងារ

104. ក្នុងបង្គោលនេះអ្នកសំភាសន៍ត្រូវកត់ចូលលេខកូដនៃផ្នែកការងាររបស់អ្នកឆ្លើយ ។ នៅក្នុងតារាងសំណួរមាន 5 ផ្នែកដែលមានលេខកូដជាប់មកជាមួយស្រាប់ ។ បើអ្នកឆ្លើយថា: បំរើការងាររដ្ឋាភិបាល ត្រូវចុះលេខកូដ 1 ក្នុងបង្គោលនេះ ។ បើគាត់ធ្វើការក្នុងសហគ្រាស ( ពាក់កណ្តាលរដ្ឋពាក់កណ្តាលឯកជន ) (parastatal) ត្រូវកត់ចូលលេខកូដ 2 (ឧ ការផ្គត់ផ្គង់អគ្គិសនី ការផ្គត់ផ្គង់ទឹក ) ។ បើអ្នកឆ្លើយបានធ្វើការក្នុងគ្រឹះស្ថានសហករណ៍ (ឧ.សហករណ៍ ធនាគារ ) សូមកត់ចូលលេខកូដ 3 ហើយមនុស្សទាំងអស់ដែលបានធ្វើការក្នុងគ្រឹះស្ថានឯកជន ជាអ្នកធ្វើការងារដោយប្រើទុនផ្ទាល់ខ្លួន ត្រូវទទួលបានលេខកូដ 4 ។ បើមនុស្សម្នាក់ធ្វើការនៅក្នុងគ្រឹះស្ថានមួយដែលមិនចូលក្នុងប្រភេទណាមួយក្នុងចំណោមប្រភេទទាំង 4 ខាងលើ អ្នកសំភាសន៍ត្រូវកត់ចូលលេខកូដ 5 *រួចសូមបញ្ជាក់ផ្នែកនៃការងារនោះ (ឧ. 5 U.N.D.P )* ។

## សេចក្តីណែនាំទូទៅសំរាប់បំពេញសំណួរសេដ្ឋកិច្ច

105. មានប្រយោជន៍ណាស់ក្នុងការពិភាក្សាជាមួយមនុស្សម្នាក់ ហើយបំពេញជាលំអិតអំពីសំណួរដែលគ្របដណ្តប់ពីបង្គោល 15 ដល់ 20 ។ ឧទាហរណ៍ បើកំពុងសំភាសន៍ជាមួយស្ត្រីម្នាក់ដែលនិយាយថា គាត់លក់បន្លែខ្លួនឯងនៅផ្សារ សូមសួរថាតើគាត់បានលក់ដូរប៉ុន្មានខែកាលពីមួយឆ្នាំកន្លងមក ។ គាត់អាចនិយាយថា ពេញមួយឆ្នាំ ។ ចំពោះគាត់នោះ អ្នកសំភាសន៍អាចកត់ត្រាដូចតទៅ: 1 ក្នុងបង្គោល 15 , 12 ក្នុងបង្គោល 16 ," អ្នកលក់បន្លែ " ក្នុងបង្គោល 17 , 3 ក្នុងបង្គោល 18 ,"លក់បន្លែរាយ" ក្នុងបង្គោល 19 និង 4ក្នុងបង្គោល 20។

105.1 *សូមកត់សំគាល់ថាបើអ្នកណាម្នាក់មានលេខកូដ 1 ក្នុងបង្គោល 15 អ្នកនោះត្រូវតែមានពត៌មានបំពេញក្នុងបង្គោល 16 ដល់ 20 ។ បើអ្នកណាម្នាក់មានលេខកូដ 2 ក្នុងបង្គោល 15អ្នកនោះត្រូវ*

*តែមានពត៌មានបំពេញក្នុងបង្គោល 16 ដល់ 20 សំរាប់ការងារចុងក្រោយរបស់គាត់ ។ បើអ្នកណាម្នាក់មានលេខកូដណាមួយ ក្នុងចំណោមលេខកូដពី 3 ដល់ 8 ក្នុងបង្គោល 15 សូមគូសសញ្ញា (-) ក្នុងបង្គោល 16 ដល់ 20 ។*

## ការបំពេញតារាង ខ តារាងសំណួរតាមគ្រួសារផ្នែក 3 : ពត៌មានអំពីភាពបង្កើតកូនបានរបស់ស្ត្រីមានអាយុពី 15ឆ្នាំឡើងទៅ ដែលបានចុះបញ្ជីក្នុងបង្គោល 2 ផ្នែក 2

106. តារាងសំណួរផ្នែកនេះទាក់ទងទៅនឹងពត៌មានអំពីភាពបង្កើតកូនបានរបស់ស្ត្រី ។ អ្នកសំភាសន៍ត្រូវសួរសំណួរទាំងនេះ ក្នុងករណីស្ត្រីមានអាយុពី 15ឆ្នាំ ឡើងទៅនៅក្នុងគ្រួសារដែលអ្នកសំភាសន៍បានកត់ត្រាក្នុងផ្នែក 2 នៃតារាង ខ តារាងសំណួរតាមគ្រួសារ ។ *សូមកត់សំគាល់ថា ពត៌មានពីភាពបង្កើតកូនបានត្រូវប្រមូលពីស្ត្រីទាំងអស់ឱ្យតែមានអាយុពី 15 ឆ្នាំឡើងទៅ នៅក្នុងគ្រួសារ ដោយមិនគិតអំពីអាយុ ឬស្ថានភាពអាពាហ៍ពិពាហ៍ឡើយ ។ ម៉្យាងទៀត ពត៌មាននេះត្រូវរាប់បញ្ចូលទាំងអ្នកចាស់ និងស្ត្រីដែលមិនដែលបានរៀបការសោះ បានរៀបការហើយ មេម៉ាយប្តីស្លាប់ មេម៉ាយលែងលះគ្នាឬរស់នៅផ្សេងគ្នា ( កំពុងលែងលះគ្នា) ។*

106.1 អ្នកសំភាសន៍បានចុះបញ្ជីឈ្មោះសមាជិកពិតប្រាកដ និងភ្ញៀវវត្តមាននៅក្នុងគ្រួសារនៅយប់ធ្វើជំរឿនក្នុងបង្គោល 2 ផ្នែក 2 ។ អ្នកសំភាសន៍បានទទួលពត៌មានអំពីមនុស្សទាំងនេះក្នុងបង្គោល 3 ដល់ 20 នៃផ្នែក 2 ។ ឥឡូវ ដំបូងអ្នកសំភាសន៍ត្រូវសំគាល់ឱ្យឃើញពីបង្គោល 2 ,4, និង 5 នៃផ្នែក 2 នូវស្ត្រីមានអាយុពី 15 ឆ្នាំឡើងទៅនៅក្នុងគ្រួសារគឺជាការចង្អុលបង្ហាញមួយដែលអ្នកត្រូវតែបញ្ជាក់លើគ្រប់ស្ត្រីទាំងអស់ដោយគូសសំគាល់លើលេខរៀងក្នុងបង្គោល 1 ផ្នែក2 ។ អ្នកសំភាសន៍ត្រូវយកពត៌មានអំពីភាពបង្កើតកូនបានពីស្ត្រីទាំងនោះ ហើយចុះក្នុងបង្គោល 4 និង 5 នៃតារាង ខ ផ្នែក 3 នៃតារាងសំណួរតាមគ្រួសារ ។

សូមអនុវត្តតាមសេចក្តីណែនាំសំរាប់ បំពេញបង្គោល 1 ដល់ 5 នៃតារាងខ ផ្នែក 3 នៃតារាងសំណួរតាមគ្រួសារ :

### បង្គោល 1 : លេខរៀង

107. អ្នកសំភាសន៍ត្រូវប្រើមួយបន្ទាត់សំរាប់ចុះពត៌មានពីស្ត្រីម្នាក់ ។ សូមចុះលេខរៀងថ្មី 1,2,3 ។ល។ សំរាប់បន្ទាត់នីមួយៗ ។

### បង្គោល 2: នាមត្រកូល និងនាមខ្លួន

108. សូមចំលងឈ្មោះស្ត្រីដែលមានអាយុពី 15ឆ្នាំឡើងទៅមួយម្តងមួយម្តងនៅក្នុងគ្រួសារតាមលំដាប់ដដែលដូចដែលបានចុះក្នុងបង្គោល 2 នៃផ្នែក 2 ។ ការងារនេះអាចធ្វើទៅបានដោយផ្អែកទៅលើនាមត្រកូល និងនាមខ្លួន (បង្គោល 2) ភេទ ( បង្គោល 4 ) និង អាយុ ( បង្គោល 5 ) នៃផ្នែក 2 ។ សូមកុំចុះឈ្មោះបន្ថែមណាមួយដែលមិនបានចុះក្នុងបង្គោល 2 ផ្នែក 2 ព្រោះយើងប្រមូលពត៌មានពីភាពបង្កើតកូនបានរបស់ស្ត្រីមានអាយុពី 15 ឡើងទៅ នៅក្នុងគ្រួសារតែប៉ុណ្ណោះ ។ សូមកុំភ្លេចចម្លងឈ្មោះស្ត្រីមានអាយុពី 15 ឆ្នាំឡើងទៅឱ្យអស់ ទោះជាស្ត្រីនោះនៅលីវ ឬគ្មានកូន ឬគាត់មានអាយុលើស 50 ឬ 60 ឆ្នាំក៏ដោយ ។ អ្នកសំភាសន៍ត្រូវចម្លងឈ្មោះស្ត្រីទាំងអស់ដែលមានអាយុពី 15 ឆ្នាំឡើងទៅនៅក្នុងគ្រួសារក្នុងផ្នែក 3 ហើយស្រង់យកពត៌មានចាំបាច់ពីភាពបង្កើតកូនបានរបស់ស្ត្រីតាមករណីនីមួយៗ ។ម្យ៉ាងទៀត ទោះបីក្នុងករណីស្ត្រីមានអាយុ 15 ឆ្នាំឡើងទៅដែលមិនត្រូវសួរសំណួរពីការបង្កើតកូនរបស់គាត់ក៏ដោយ ក៏អ្នកសំភាសន៍ត្រូវចម្លងឈ្មោះស្ត្រីទាំងនោះ ក្នុងបង្គោល 2 រួចសរសេរ 00 ក្នុងបង្គោល 4 នឹង 5 ។

### បង្គោល 3: លេខរៀងក្នុងបង្គោល 1 នៃផ្នែក 2

109. សូមចុះឈ្មោះស្ត្រីម្នាក់ៗតាមលេខរៀងរបស់គាត់ក្នុងបង្គោល 1 ផ្នែក 2 ។ ឧទាហរណ៍ បើស្ត្រីទី 1 មានលេខរៀង 4 ក្នុងបង្គោល 1 ផ្នែក 2 អ្នកសំភាសន៍ត្រូវចុះ 4 ក្នុងបង្គោលនេះ ( បង្គោល 3 ) ឱ្យចំឈ្មោះគាត់ ។ល។ និង ។ល។ អ្នកនឹងពេញចិត្តពីវិធីសាស្ត្រនេះដែលមានលក្ខណៈងាយស្រួលក្នុងការផ្ទៀងផ្ទាត់គ្នា ។

### បង្គោល 4: ចំនួនក្មេងកើត

110. គេបានរៀបចំសំនួរតាមរបៀបមួយដើម្បីចំរាញ់យកពត៌មាន សំខាន់ចាំបាច់បំផុតដែលយើងត្រូវការដោយគ្មានធ្វើឱ្យអ្នកឆ្លើយមានការអៀនខ្មាស់ ។ យើងត្រូវរកអោយឃើញនូវចំនួនកុមារកើត ចំនួនកុមារកំពុងរស់នៅសព្វថ្ងៃនិងចំនួនកុមារស្លាប់ក្នុងចំនួននោះ ។ សូមចងចាំថា ធាតុពិតតាមទ្រង់ទ្រាយណាក៏ដោយ ចម្លើយដែលអ្នកសំភាសន៍ទទួលបាន នោះគឺ អាស្រ័យទៅនឹងភាពប៉ិនប្រសប់របស់អ្នកសំភាសន៍ដែលចេះចោទឡើងនូវសំនួរទាំងនោះ ។ ហេតុនេះត្រូវតែមានការប្រុងប្រយ័ត្នក្នុងការជ្រើសរើសយកពាក្យពេជ្រឱ្យចំន័យពិតប្រាកដរបស់សំនួរមកប្រើដោយមិនបង្កអារម្មណ៍មិនពេញចិត្តណាមួយដល់អ្នកឆ្លើយ ។ នៅក្នុងសំនួរទាំងអស់នៅទីបញ្ចប់សូមកត់សំគាល់ពាក្យ " កុមារ " សំដៅដល់កូនដែលកើតចេញពីផ្ទៃរបស់ស្ត្រីផ្ទាល់ខ្លួន ទោះជាមានអាយុប៉ុន្មាននិងភេទណាក៏ដោយ ហើយក៏មិនមែនកូនរបស់បងប្រុសប្អូនប្រុស បងឬប្អូនស្រី

ឬ ប្តី ឬ សាច់ញាតិផ្សេងទៀត ឬមិន មែនជាសាច់ញាតិ ឬ កូនចិញ្ចឹមដែលកំពុងរស់នៅជាមួយស្ត្រី នោះ ។ អ្នកត្រូវសំគាល់ដែរថា អ្នកឆ្លើយខ្លះអាចចាស់ ហើយការចងចាំរបស់គាត់ក៏អន់ ។ ហេតុនេះ អ្នកត្រូវមានភាពអំណត់និងជួយគាត់ដើម្បីកត់ត្រាឱ្យបានត្រឹមត្រូវនូវចំនួនកូនដែលគាត់បានបង្កើត ។ បើគេឆ្លើយថាគ្មានកូនក្នុងផ្នែក នៃសំណួរណាមួយ សូមសរសេរ 00 នៅក្នុងបង្គោលដែលពាក់ព័ន្ធនានា ។

ចំណាំ ៖ នេះគឺជាពិសោធន៍រួមដោយកំណើតរបស់ក្មេងដែលមិនបានរស់នៅក្នុងពេលធ្វើសំភាសន៍នោះច្រើនមិនបាននឹកគិតដល់ឡើយ ។ នេះនាំឱ្យមានចំនួនមានការប្រែប្រួលដោយសារករណីភ្លេចភ្លាំងនេះដែលត្រូវតែសាកសួរជាពិសេស ។ ជាការចាំបាច់ណាស់ដែលត្រូវតែកត់ត្រាយកចំនួនឱ្យបានអស់នូវរាល់កំណើតរស់ទោះបីជាទារកបានកើតមកស្លាប់វិញភ្លាម ឬ ក៏មិនបានរស់ដល់ពេលធ្វើសំភាសន៍ក៏ដោយ ។ បើស្ត្រីបានឆ្លើយជាដំបូងថា គាត់មិនបានបង្កើតកូនមួយណាទេ នោះអ្នកអាចសួរទៅគាត់ដូចតទៅៈ " គេ បានឃើញ ។ នៅតាមផ្ទះមួយចំនួនក្មេងបានកើតហើយក៏បានស្លាប់វិញភ្លាម ឬក្រោយមកពីរបីថ្ងៃក៏ស្លាប់ ឬក្រោយមកពីរបីខែក៏ស្លាប់ ហើយករណីបែបនេះក៏មិនបានគិតគូរកត់ត្រាផង " ។ ខ្ញុំគិតថារបៀបនេះ បែបមិនមាននៅទីនេះទេ ។ តើខ្ញុំនិយាយនេះត្រូវ ឬ ខុស ? ។ នេះអាចជាសំណួរមួយទៅលើអ្នកឆ្លើយ ។ បើគាត់ថា " ទេ " នោះអ្នកអាចប្រាកដក្នុងខ្លួនថាពិតជាមិនភ្លេចចំនួនក្មេងកើតឡើយ ។

**បង្គោល 4 : ( ក ) និង (ខ) តើអ្នកស្រីបានបង្កើតកូនរស់បានប៉ុន្មាននាក់ ? (កត់ចូលក្នុងបង្គោល ក ចំនួនកូនប្រុស និង ក្នុងបង្គោល ខ ចំនួនកូនស្រី ដាច់ដោយឡែកពីគ្នា )**

111. សូមកត់ចូលក្នុងបង្គោលនូវចំនួនកូនកើតនៅរស់ពីអ្នកឆ្លើយនៅតាមចន្លោះ ដែលបានទុកអោយសំរាប់កូនប្រុសក្នុងបង្គោល ( ក ) កូនស្រីនៅក្នុងបង្គោល ( ខ ) ។ សូមចុះចំនួនជាលេខពីរខ្ទង់ដូចបានណែនាំនៅដើមបង្គោលនេះ ។ នៅពេលសួរពីសំណួរនេះអ្នកសំភាសន៍ត្រូវសួរដោយប្រុងប្រយ័ត្ននិងធ្វើអោយប្រាកដថាខ្លួនយើងកត់ចូលតែចំនួនកុមារកើតរស់ពីអ្នកឆ្លើយ ។ ទារកមួយដែលកើតមកស្លាប់ ( ស្លាប់នៅពេលកំពុងកើត ) គេហៅថា ទារកស្លាប់ក្នុងពោះ ។ ទារកស្លាប់ក្នុងពោះមិនត្រូវរាប់បញ្ចូលនៅពេលស្រង់ពត៌មានសំរាប់បង្គោល 4(ក )ឬ4(ខ) ឡើយ។

112. ជាការចាំបាច់សំរាប់អ្នកសំភាសន៍ត្រូវស្គាល់និយមន័យពីទារកកើតរស់ (ឬក្មេងកើតរស់ ) ។ និយមន័យនោះ មានដូចតទៅ ៖

ទារកកើតរស់គឺទារកដែលបានសំរាលចេញពេញលេញ (សំរាលកូន ) ឬ ស្រូបទាញយកពីម្តាយរបស់គេដែលមានផ្ទៃពោះ (ទារក ) ដោយមិនគិតដល់រយៈពេលពរពោះ ។ ក្រោយពីផ្តាច់ចេញពីផ្ទៃម្តាយតាមវិធីសាស្ត្រទាំងនេះ ទារកមានដកដង្ហើម ឬ បានបង្ហាញភស្តុតាងផ្សេងទៀតដែលបញ្ជាក់ថា មានជីវិតដូចជាបេះដូងដើរ ជីពចរនៃទងផ្ចិតឬ កាយវិការពិតប្រាកដនៃសាច់ដុំគំរើកដោយចេតនា ទោះបីគេបានកាត់

ឬ មិនបានកាត់ទងផ្ចិត ឬ ទងសុក ។ ភស្តុតាងនីមួយៗនៃកំណើតបែបនេះត្រូវបានចាត់ទុកថាទារកកើតរស់ ។

សូមកត់សំគាល់ថា កុមារកើតរស់ពីស្ត្រីម្នាក់ត្រូវរាប់បញ្ចូលកុមារដែលបានកើតហើយកំពុងរស់នៅ និង កុមារដែលបានកើតរស់ តែបានស្លាប់នៅពេលធ្វើជំរឿន ។

ដើម្បីឱ្យងាយស្តាប់ ក្មេងកើតរស់គឺក្មេងកើតមកមានសំលេងយំ ។

**បង្គោល 4: (គ) និង (ឃ) តើក្នុងចំណោមកូនទាំងនោះមានកូនប៉ុន្មាននាក់រស់នៅសព្វថ្ងៃ ? (កត់ចូលក្នុងបង្គោល ( គ ) ចំនួនកូនប្រុសនិងក្នុងបង្គោល ( ឃ )ចំនួនកូនស្រី ដាច់ដោយឡែកពីគ្នា)**

113. សូមកត់ចូលក្នុងចន្លោះទុកស្រេចនូវចំនួនកូនផ្ទាល់ខ្លួនរបស់ស្ត្រីតាមភេទដែលកំពុងរស់នៅ ។ ក្នុងចំណោមកូនទាំងនោះមានកូនខ្លះរស់នៅក្នុងគ្រួសារនិងកូនខ្លះរស់នៅកន្លែងផ្សេងទៀត ។ អ្នកសំភាសន៍ត្រូវកត់ចូលនូវកុមារទាំងអស់នោះ ។ សូមចងចាំថា រាប់បញ្ចូលក្នុងប្រភេទនេះ ក៏រួមមានកូនណាមួយរបស់ស្ត្រីផ្ទាល់ ដែលតាមធម្មតារស់នៅក្នុងគ្រួសារនេះ តែអវត្តមានក្នុងពេលចុះសំភាសន៍ ។ ករណីខ្លះ ពេលកូនទៅឆ្ងាយពីខ្លួនម្តាយមិនដឹងថាតើកូនគាត់នៅរស់ ឬ ក៏អត់ទេ ។ ករណីនេះ សូមសរសេរថា " មិនដឹង " ក្រោមបង្គោល 4 ( គ ) និង 4 ( ឃ ) ។

**បង្គោល 4: (ង) និង (ច) តើក្នុងចំណោមកូនទាំងនោះមានកូនប៉ុន្មាននាក់ស្លាប់ ? (កត់ចូលក្នុងបង្គោល ( ង ) ចំនួនកូនប្រុស និងក្នុងបង្គោល ( ច )ចំនួនកូនស្រី ដាច់ដោយឡែកពីគ្នា)**

114. សូមកត់ចូលក្នុងចន្លោះទុកស្រេចនូវចំនួនកូនផ្ទាល់ខ្លួនរបស់ស្ត្រីតាមភេទដែលបានស្លាប់ទៅវិញ ។ សូមចំណាំថា មានស្ត្រីខ្លះគាត់ពិបាកនឹកពីចំនួនកូនគាត់ដែលបានស្លាប់ទៅវិញ ។ ហេតុនេះ អ្នកត្រូវជួយអ្នកឆ្លើយ ដើម្បីរកឱ្យបានចំនួនត្រឹមត្រូវ ដូចជាការរាប់ម្រាមដៃរបស់អ្នកទៅតាមឈ្មោះក្មេងស្លាប់ដែលគាត់និយាយប្រាប់ ។ នេះជាសំណួរដែលប៉ះពាល់ដល់អារម្មណ៍មិនរីករាយរបស់អ្នកឆ្លើយ ហើយអ្នកសំភាសន៍ត្រូវសំរួលដល់ការឆ្លើយដោយមិនបង្កអារម្មណ៍ទុក្ខសោកដល់អ្នកឆ្លើយ ។

ចំណាំ : ត្រូវធ្វើឱ្យប្រាកដថា គ្មានក្មេងណារាប់ជួន ឬភ្លេចមិនបានរាប់ ។ សូមចងចាំថា ចំនួនសរុបកុមារកើតរស់របស់ស្ត្រីត្រូវស្មើនឹងផលបូកសរុបចំនួនសរុបកុមារដែលកំពុងរស់នៅ និងចំនួនសរុបកុមារដែលបានស្លាប់ទៅវិញ ។

បង្គោល 4 ( ក ) = បង្គោល 4( គ ) + បង្គោល 4( ង )

បង្គោល 4 ( ខ ) = បង្គោល 4( ឃ ) + បង្គោល 4( ច )

## បង្គោល ៥ : ពត៌មានអំពីកំណើតកូនក្នុង 12 ខែកន្លងមក

115 សំនួរនេះប្រាថ្នាប្រមូលយកពត៌មានអំពីកំណើតកូន (ជាកំណើតកូនប្រុស ឬជាកំណើតកូនស្រីដាច់ដោយឡែកពីគ្នា) ក្នុង 12 ខែមុនកាលបរិច្ឆេទនៃការសំភាសន៍ចំពោះស្ត្រីទាំងអស់ដែលមានអាយុ 15 ឆ្នាំឡើងទៅសូមបញ្ជាក់ថា ចំនួនក្មេងកើតរស់បានកត់ត្រារួចហើយនៅក្នុងបង្គោល 4 ( ក ) និង 4 ( ខ ) គឺរាប់រួមទាំងក្មេងដែលបានកើតរស់ក្នុងរយៈពេល 12 ខែកន្លងមក ។ ក្នុងករណីមនុស្សចាស់ (មានអាយុលើសពី 50 ឆ្នាំ) ឬស្ត្រីមេម៉ាយ ឬ ស្ត្រីលែងលះគ្នាជាទូទៅមិនអាចមានទារកកើតក្នុង 12 ខែកន្លងមកទេ ។ ក្នុងករណីស្ត្រីទាំងនេះ អ្នកសំភាសន៍ក៏ត្រូវបំពេញបង្គោលនេះ ដោយលេខ 0 ។ ទោះយ៉ាងណាក្តី សូមចងចាំថាកំណើតដែលកើតមានឡើងមិនត្រូវទាត់ចោលទាំងស្រុងក្នុងករណីបែបនេះទេ ។ អ្នកសំភាសន៍ត្រូវកត់ចូល ( តែកូនណាកើតនៅរស់ស្រី ឬប្រុសតាមករណីដែលអាចមាន ។ ចំពោះគោលបំណងនេះ ទារកកើតស្លាប់ចេញពីផ្ទៃម្តាយ ពោលគឺទារកដែលបានកើតតែស្លាប់ពីក្នុងផ្ទៃម្តាយមិនត្រូវយកមកគិតគូរទេ ។ ដូចនេះ អ្នកត្រូវធ្វើអោយប្រាកដថា ករណីនីមួយៗនៃកំណើតរបស់ទារកកើតរស់ ទោះបីទារកនោះមិននៅរស់នៅពេលកំណត់ធ្វើជំរឿនក៏ដោយក៏ត្រូវរាប់តាមការប្រាប់ដែរ ។ អ្នកសំភាសន៍មិនត្រូវទទួលស្គាល់កូននោះប្រសិន បើជាទារកបានកើតតែអត់មានជីវិតពីក្នុងផ្ទៃម្តាយ ។ ឧបមាថា ទារកបានកើតរស់រួចស្លាប់ភ្លាមទៅវិញ ក្រោយពីបានសំរាលមកកូននោះ ជាកូនកើតរស់ដែលគេត្រូវឆ្លើយប្រាប់ ។ អ្នកត្រូវធ្វើឱ្យប្រាកដថា កុមារកើតរស់ក្នុងមួយឆ្នាំកន្លងមករបស់ស្ត្រីត្រូវបានកត់ត្រាយកទាំងអស់ ទោះជាកុមារនោះកំពុងរស់នៅពេលធ្វើសំភាសន៍ ឬមិនបានរស់នៅពេលធ្វើសំភាសន៍ក៏ដោយ ។

115.1 *បើសិនចំលើយថា "មានទារកកើត" អ្នកត្រូវសួរថាទារកកើតមកនោះ ជាប្រុស ឬ ស្រី ។ បើប្រុសសូមចុះ 1 ត្រង់ប្រុស ហើយចុះ 0 ត្រង់ស្រី ។ បើស្រីសូមចុះ 0 ត្រង់ប្រុស និង 1 ត្រង់ ស្រី ។ បើសិនចំលើយថាគ្មាន ទារកបានកើតសូមចុះ 0 ត្រង់ប្រុស និងស្រី ។ ក្នុងករណីដែលស្ត្រីបានបង្កើតកូនភ្លោះសូមសរសេរ 2 តាមករណីដែលអាចមាន ។ បើសិនកូនភ្លោះនោះមាន ប្រុសមួយ ស្រីមួយ សូមចុះតាមនោះដូចគំរូខាងលើ។ បើសិន មានកូនកើត 3 ឬច្រើនសូមចុះលេខឱ្យសមស្របតាមវិធីសាស្ត្រនេះ ។*

## ការបំពេញតារាង (ខ) តារាងសំនួរតាមគ្រួសារផ្នែក 4: ស្ថានភាពលំនៅឋាននិងប្រដាប់ប្រដារប្រើប្រាស់ក្នុងផ្ទះ

116. នេះជាផ្នែកនៃកំរងសំនួរពីស្ថានភាពផ្ទះ ហើយដែលត្រូវបំពេញក្រោយពីបានបញ្ចប់សំនួរសំខាន់ៗតាមគ្រួសារ ( តារាង ខ ផ្នែក 2 និង 3 ) ។ ផ្នែកនេះត្រូវបំពេញបញ្ចប់ដោយបានជំនួយពីមេគ្រួសារឬសមាជិកទទួលខុសត្រូវណាម្នាក់ក្នុងគ្រួសារ ។

117. ករណីដែលនៅក្នុងមួយគ្រួសារ សមាជិកគ្រួសារនានាបានប្រើប្រដាប់ប្រដារច្រើនមុខនោះ សូមស្ទង់រកដើម្បីវែងវែកប្រដាប់ប្រដារណាដែលសមាជិកគ្រួសារភាគច្រើនបានប្រើ រួចកត់ចូលប្រដាប់ប្រដារនោះសំរាប់គ្រួសារ ។ ឧទាហរណ៍ បើសិនសមាជិកនានានៃគ្រួសារមួយប្រើប្រាស់ប្រភពពន្លឺណាភាគច្រើនជាងប្រភពមួយផ្សេងទៀត អ្នកសំភាសន៍ត្រូវកត់ចូលតែប្រភពសំខាន់នោះ ដែលបានប្រើដោយសមាជិកភាគច្រើន ។

118. សូមកត់សំគាល់ថាក្នុងផ្នែកនេះ គេត្រូវការអោយអ្នកសរសេរតែលេខកូដសមស្របទៅនឹងចម្លើយសមរម្យចុះក្នុងប្រអប់មាននៅក្រោមបង្គោលនីមួយៗ ។ ករណីណោះដោយអ្នកមិនត្រូវសរសេរលេខកូដច្រើនជាងមួយលេខកូដដែលមានចំពោះសំណួរនីមួយៗទេ ។

**បង្គោល 1 តើលោក-អ្នកកាន់កាប់លំនៅដ្ឋានតាមមូលដ្ឋានណាមួយ ?**

119. គេបានផ្តល់លេខកូដបំនួន ( លេខកំរប់កត់ចូលចម្លើយចំពោះសំណួរនេះ ។ ផ្ទះនៅទីនេះសំដៅដល់បន្ទប់ ( ឬ មានបន្ទប់ច្រើនកាន់កាប់ដោយគ្រួសារតែមួយ ។

119.1 **ម្ចាស់ផ្ទះផ្ទាល់ :** សូមចុះលេខកូដ 1 បើសិនគ្រួសារមានផ្ទះជាកម្មសិទ្ធរបស់មេគ្រួសារឬជាកម្មសិទ្ធរបស់សមាជិកដែលគេស្នាក់នៅពុំបានត្រូវបង់ថ្លៃឈ្នួល ។ សូមកត់សំគាល់ថាក្នុងក្រុមនេះរាប់ទាំងអ្នកកាន់កាប់ផ្ទះ ឬ អគារដោយផ្អែកលើមូលដ្ឋានទិញបណ្តាក់ ឬ កំពុងរស់នៅក្នុងផ្ទះដែលទិញដោយខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុដើម្បីទិញ ផ្ទះនោះក៏បានត្រូវកត់ត្រាចូលខាងលើដែរ ។ សូមកត់សំគាល់ផងដែរថា ទោះបីជាមេគ្រួសារ ឬ សមាជិកណាម្នាក់របស់គ្រួសារគេកាន់កាប់ផ្នែកណាមួយនៃផ្ទះ ដែលបានកាន់កាប់ហើយដោយគ្រួសារ នោះអ្នកត្រូវចុះលេខកូដ 1 ។

119.2 **ផ្ទះជួល :** សូមចុះកូដលេខ 2 បើសិនគ្រួសារនោះបានបង់ថ្លៃឈ្នួលផ្ទះដែលកំពុងស្នាក់នៅ ។ សូមចងចាំថាផ្ទះជួលនៅទីនេះបញ្ជាក់ពីការបង់ប្រាក់ទៅបំណាច់តេះពេលណាមួយជាកំណត់ ។

119.3 **មិនមែនជាម្ចាស់ផ្ទះតែរស់នៅដោយមិនបាច់បង់ប្រាក់ឈ្នួល** សូមចុះលេខកូដ 3 បើសិនគ្រួសារបានប្រើប្រាស់ផ្ទះដោយមិនបានបង់ថ្លៃឈ្នួល ទោះបីជាផ្ទះឬអគារនោះមិនមែនជាកម្មសិទ្ធិរបស់មេគ្រួសារ ឬ សមាជិកណាម្នាក់នៃគ្រួសារនោះក៏ដោយ ។ ឧ.គ្រួសារមួយកំពុងស្នាក់នៅក្នុងផ្ទះរបស់គ្រួសារមួយផ្សេងទៀតដោយមិនបាច់បង់ថ្លៃឈ្នួល ។

119.4 **មូលដ្ឋានផ្សេងទៀត** (សូមបញ្ជាក់ ) សូមចុះលេខកូដ 4 ចំពោះចម្លើយណាមួយដែលមិនមានស្ថិតក្នុងប្រភេទចំណោមប្រភេទបីណាមួយដែលបានបញ្ជាក់ខាងលើ ។ សូមបញ្ជាក់ពីមូលដ្ឋានដែលបានកាន់កាប់ផ្ទះ ។

## **បង្គោល 2 : ប្រភពបំភ្លឺសំខាន់ៗ**

120. សូមកំណត់ប្រភេទប្រភពបំភ្លឺដែលបានប្រើក្នុងគ្រួសារទៅតាមរយៈពេលច្រើនជាងគេរួចសូមចុះលេខកូដសមស្រប ។ ប្រភេទនៃប្រភពបំភ្លឺនិងលេខកូដមានដូចតទៅ :

1.អគ្គិសនីបណ្ដាញ

2.ម៉ាស៊ីនភ្លើង

3.អគ្គិសនីបណ្ដាញ និងម៉ាស៊ីនភ្លើង

4.ប្រេងកាត

5.ទៀន

6.អាគុយ ថ្មពិល

7.ផ្សេងៗទៀត ( សូមបញ្ជាក់ )

សូមកត់សំគាល់ថា អគ្គិសនីបណ្ដាញ (លេខកូដ 1) មានន័យថាអគ្គិសនីដែលបានចែកចាយដោយក្រុមហ៊ុនអគ្គិសនីរដ្ឋ ឬ ក៏ក្រុមហ៊ុនឯកជន ។ ម៉ាស៊ីនភ្លើង (លេខកូដ 2) យោលទៅលើម៉ាស៊ីនភ្លើងឯកជនដែលប្រើប្រាស់ដោយគ្រួសារ ។

## **បង្គោល 3 : ប្រភពថាមពលសំខាន់ប្រើប្រាស់សំរាប់ចំអិនម្ហូបអាហារ**

121. សូមកំណត់ឱ្យច្បាស់ពីអ្នកឆ្លើយនូវប្រភេទថាមពលដែលបានប្រើប្រាស់ច្រើនជាងគេក្នុងគ្រួសារសំរាប់ចំអិនអាហារ ។ សូមចុះលេខកូដឱ្យត្រូវនឹងលេខកូដ 1 ប្រភេទថាមពលសមស្រប ។ បើសិនគេប្រើថាមពលពីរមុខឬច្រើនមុខ ឧ. អគ្គិសនីនិងឧស្ម័ន ហ្គាស ឧស្ម័នហ្គាស និងអុស ប្រេងកាតនិងធ្យូង ។ល។ សូមចុះលេខ កូដចំពោះប្រភេទថាមពលណាដែលគេប្រើច្រើនជាងគេសំរាប់ចំអិន ។

លេខកូដរបស់ប្រភេទថាមពលប្រើសំរាប់ចំអិនមានដូចតទៅ :

1.អុស

2.ធ្យូងឬធ្យូងថ្ម

3.ប្រេងកាត

4.ឧស្ម័នហ្គាស

5.អគ្គិសនីបណ្ដាញ

6.គ្មាន

7. ផ្សេងៗទៀត ( សូមបញ្ជាក់ )

## បង្គោល 4 : ការប្រើប្រាស់បង្គន់នៅក្នុងបរិវេណផ្ទះ

122. ត្រូវកត់ចូលលេខកូដតែមួយ (1 សំរាប់មានបង្គន់ និងលេខកូដ 2 សំរាប់គ្មានបង្គន់ ) ។ សូមកត់សំគាល់ថា បង្គន់នៅទីនេះសំដៅដល់ការតម្លើងណាមួយដែលគេប្រើសំរាប់ដាក់លាមកមនុស្ស ។ បរិវេណនេះសំដៅដល់ផ្ទះឬអគារដែលមានគ្រួសារកំពុងរស់នៅនឹងមិនសំដៅដល់បរិវេណដែលគ្មានគ្រួសាររស់នៅនោះទេ ។ បើសិនគ្មានបង្គន់នៅក្នុងផ្ទះឬអគារដែលគ្រួសារកំពុងរស់នៅទេនោះអ្នកត្រូវចុះលេខកូដ 2 ។

## បង្គោល 5 : ប្រភពផ្គត់ផ្គង់ទឹកស្អាតសំរាប់ផឹក

123. សូមចុះលេខកូដសមស្របសំរាប់ប្រភពផ្គល់ទឹកស្អាតសំខាន់ៗ ។ បើសិនជាមានប្រភពផ្គល់ទឹកស្អាតពីរ ឬ ច្រើន សូមចុះលេខកូដនៃប្រភពទឹកស្អាតដែលបានប្រើប្រាស់ច្រើនជាងគេ ។ ខាងក្រោមនេះគឺលេខកូដសំរាប់ប្រភពផ្គល់ទឹកស្អាតផ្សេងៗ :

1.ទឹកបណ្ដាញ

2.អណ្ដូងស្នប់ អណ្ដូងខួង

3.អណ្ដូងជីក

4.ទឹកចេញក្រោមដី ទន្លេ ស្ទឹង អូរ បឹង ត្រពាំង ទឹកភ្លៀង

5.ទឹកទិញ

6.ប្រភពផ្សេងទៀត ( សូមបញ្ជាក់ )

សូមកត់សំគាល់ថាទឹកទិញ (កូដលេខ 5) យោលទៅតាមការទិញទឹកពីកន្លែងផ្គត់ផ្គង់ទឹក ឬក៏អ្នកលក់នៅតាមផ្លូវ ។ ក្នុងករណីនេះផ្តល់លេខកូដ 5 ។ បើសិនគ្រួសារប្រើប្រាស់ទឹកផឹកតាមរយៈបណ្ដាញបំពង់ និងតាមការបង់ប្រាក់ចុះលេខកូដ 1 មិនមែនលេខ 5 ទេ ។

## បង្គោល 6 : ចំនួនបន្ទប់ដែលគ្រប់គ្រងដោយគ្រួសារ

124. សូមកត់ចូលក្នុងប្រអប់ដែលទុកស្រាប់នៅក្នុងបង្គោលនេះ នូវចំនួនបន្ទប់ដែលកាន់កាប់ដោយគ្រួសារ ដូចបានគូសបញ្ជាក់នៅក្នុងបង្គោលស្រាប់ ។ បើសិនគ្រួសារមួយកាន់កាប់បន្ទប់ច្រើនពីប្រាំបីឡើងទៅ អ្នកត្រូវកត់ចូលតែលេខកូដ 8 ។

124.1 បន្ទប់មួយត្រូវមានជញ្ជាំង 4 មានដំបូលមួយ និងទ្វារចេញចូលមួយ ។ បន្ទប់នេះត្រូវទូលាយ ហើយវែងគ្រប់គ្រាន់ សំរាប់មនុស្សដេកនៅក្នុងនោះ ។ ក្នុងការរាប់ចំនួនបន្ទប់ដែលកាន់កាប់ដោយគ្រួសារ អ្នកត្រូវដកចេញនូវ ផ្ទះបាយ ឃ្លាំង បន្ទប់ទឹក និងបង្គន់ ដែលធម្មតាជាបន្ទប់មិនមានប្រយោជន៍សំរាប់រស់នៅ ឬ ដេក ។ បន្ទប់ទទួលភ្ញៀវមួយដែលបានចែកគ្នាប្រើប្រាស់ច្រើនជាងមួយគ្រួសារ បន្ទប់ទទួលភ្ញៀវនេះពុំបានរាប់បញ្ចូលជារបស់គ្រួសារណាមួយឡើយ ។

# ជំពូក IV
## ការធ្វើជំរឿនសមាជិកនៃគ្រួសារស្ថាប័ន

125. ដូចបានពណ៌នានៅវគ្គ 27 នៃជំពូក 2 គ្រួសារស្ថាប័នមួយគឺជាគ្រួសារមួយដែលមានសមាជិកគ្មានជាប់សាច់ញាតិអ្វីឡើយរស់នៅជាមួយគ្នា ដូចជាផ្ទះនៅលើនាវា: អាហារដ្ឋាន អន្តេវាសិកដ្ឋាន សណ្ឋាគារ ផ្ទះសង្គ្រោះ ពន្ធនាគារ វត្តអារាម ។ល។ ត្រូវកត់សំគាល់ថាបើមានមនុស្សមួយក្រុមដែលពីម្នាក់ទៅម្នាក់គ្មានជាប់សាច់ញាតិហើយរស់នៅក្នុងអគារ / សំណង់ជាមួយគ្នាមិនបានបរិភោគបាយចេញពីផ្ទះបាយរួមនោះ ពួកគេទាំងនោះ មិនអាចបង្កើតជាគ្រួសារស្ថាប័នឡើយ ។ មនុស្សម្នាក់ៗនៃក្រុមជនទាំងនោះត្រូវចាត់ទុកជាគ្រួសាររស់នៅដាច់ដោយឡែកពីគ្នា ។

126 នៅកំឡុងពេលធ្វើការចុះបញ្ជីផ្ទះ ( មើលវគ្គ 45 ជំពូក 2 ) អ្នកបានសំគាល់ឃើញជាស្រេចហើយនូវគ្រួសារស្ថាប័ន ។ ជំពូកនេះ ពាក់ព័ន្ធទៅនឹងការធ្វើជំរឿនសមាជិកនៃគ្រួសារស្ថាប័នទាំងនេះ ។ គេត្រូវធ្វើជំរឿនតែសមាជិកដែលវត្តមាននៅក្នុងគ្រឹះស្ថានមួយនៅយប់ធ្វើជំរឿន ។ មន្ត្រីនៃគ្រឹះស្ថាននោះដូចជា អ្នកយាម អ្នកគ្រប់គ្រង អ្នកជំនួយការ អ្នកបោសសំអាត ។ល។ ដែលគ្រាន់តែមកធ្វើការនៅក្នុងគ្រឹះស្ថាននេះ តែមិនបានស្នាក់នៅក្នុងគ្រឹះស្ថានគឺត្រូវគេជំរឿននៅតាមលំនៅដ្ឋានរបស់ពួកគាត់មិនមែននៅគ្រឹះស្ថាននេះទេ ។ មន្ត្រីបែបនេះ ដែលមានភារកិច្ចនៅពេលយប់នៅគ្រឹះស្ថាននឹងមិនត្រូវជំរឿនដូចសមាជិកនៃគ្រឹះស្ថាននោះ ទោះបីពួកគេបានចំណាយពេលវេលានៅពេលយប់ធ្វើជំរឿននៅគ្រឹះស្ថាននោះក៏ដោយ ។ ដែលចាត់ដូចនេះពីព្រោះពួកគេជាធម្មតាបានស្នាក់នៅតាមលំនៅដ្ឋានរបស់ពួកគេរៀងខ្លួន តែនៅពេលនេះគេគ្រាន់តែមកគ្រឹះស្ថានដើម្បីធ្វើការតែប៉ុណ្ណោះ ។

127. សេចក្តីណែនាំសំរាប់បំពេញតារាង ក តារាងបញ្ជីផ្ទះនិងតារាង ខ តារាងសំណួរតាមគ្រួសារសំរាប់គ្រួសារស្ថាប័នមានផ្តល់ជូនខាងក្រោមនេះ :

### តារាង ក តារាងបញ្ជីផ្ទះ

(i) នៅក្នុងបង្គោល ៨ នៃតារាង ក អ្នកត្រូវសរសេរឈ្មោះគ្រួសារស្ថាប័នដោយមានសរសេរអមជាមួយនូវឋានៈតែងតាំងនៃមេគ្រួសារស្ថាប័ននោះ ។ បើសិនគ្មានឋានៈតែងតាំងទេនោះ អ្នកអាចសរសេរឈ្មោះមេគ្រួសារស្ថាប័នដែលគេស្គាល់ជាងគេ ។

*ករណីគ្រួសារស្ថាប័នសូមសរសេរអក្សរ " ស " ក្នុងវង់ក្រចកពីក្រោយឈ្មោះឬឋានៈតែងតាំងនៃមេគ្រួសារនៅក្នុងបង្គោលនេះ ។ ឧទាហរណ៍ កូលាប (II) អន្តេវាសិកដ្ឋានសាលា អ្នកគ្រប់គ្រង (ស) ។ លោក ស្រី ផ្កា ( ស ) ។ សូមសរសេរផងដែរ " គ្រួសារស្ថាប័ន " ក្នុងបង្គោលសេចក្ដីផ្សេងៗ ( បង្គោល 13 ) ។*

(ii) អ្នកត្រូវបំពេញគ្រប់បង្គោលផ្សេងទៀតដូចគ្នាក្នុងករណីគ្រួសារធម្មតា ឬ គ្រួសារប្រក្រតី ។

## តារាង ខ តារាងសំណួរតាមគ្រួសារ

### ផ្នែក 1

(i) សូមចុះលេខកូដ 2 នៅក្នុងប្រអប់ខាងក្រោម " ប្រភេទនៃគ្រួសារ / ប្រជារាស្ត្រ "។

(ii) ចំពោះឈ្មោះមេគ្រួសារ ត្រង់ពត៌មានសំគាល់ សូមអនុវត្តតាមសេចក្ដីណែនាំដូចបានផ្ដល់ជូនក្នុង (i) នៅតារាង ក តារាងបញ្ជីផ្ទះខាងលើ ។

(iii) សេចក្ដីណែនាំសំរាប់បំពេញពត៌មានផ្សេងទៀតនៅផ្នែក 1 គឺដូចគ្នាចំពោះគ្រួសារធម្មតា លើកលែងតែគ្រួសារស្ថាប័ន អ្នកមិនត្រូវបំពេញតារាងសំណួរ 1.1 , 1.2, 1.3 និង តារាងសរុបតារាងសំណួរក្នុងផ្នែក 1 ។ ហេតុនេះ អ្នកត្រូវទុកផ្នែកនេះឱ្យស្អាតនៅក្នុងកំរងតារាងសំណួរតាមគ្រួសារដែលបានប្រើសំរាប់សំភាសន៍គ្រួសារស្ថាប័នមួយ ។

### ផ្នែក 2

(i) ការធ្វើជំរឿនសមាជិកនៃគ្រួសារស្ថាប័នក្នុងផ្នែកនេះនៃតារាងសំណួរតាមគ្រួសារត្រូវអនុវត្តតាមវិធីសាស្ត្រដែលដូចបានធ្វើចំពោះគ្រួសារធម្មតាឬគ្រួសារប្រក្រតី ។

(ii) យ៉ាងណាក្ដីនៅពេលបំពេញបង្គោល 2 ( នាមត្រកូលនិងនាមខ្លួនពេញលេញ ) និងបង្គោល 3 ( ញាតិសម្ពន្ធ ) សូមអនុវត្តតាមការណែនាំដូចផ្ដល់ជូនខាងក្រោមនេះ :

( ក ) ដំបូងសូមចំលងនាមត្រកូលនិងនាមខ្លួននៃមេគ្រួសារស្ថាប័នដូចបានផ្ដល់ជូនក្នុងផ្នែក 1 ត្រង់នាមត្រកូល និងនាមខ្លួននៃមេគ្រួសារ ។

( ខ ) ចំពោះសមាជិកម្នាក់ៗ ( ផ្សេងពីមេគ្រួសារស្ថាប័ន ) សូមចុះលេខកូដ 7 ( គ្មានជាប់សាច់ញាតិ ) ក្នុងបង្គោល 3 ។

**ផ្នែក 3**

(i) ការធ្វើជំរឿនស្រង់ពត៌មានពីភាពបង្កើតកូនបានរបស់សមាជិកស្ត្រីដែលមានអាយុ 15 ឆ្នាំឡើងទៅ នៃគ្រឹះស្ថានមួយក្នុងផ្នែកនេះនៃតារាងសំណួរតាមគ្រួសារនិងអនុវត្តតាមវិធីសាស្ត្រដូចគ្នាចំពោះគ្រួសារធម្មតា ឬគ្រួសារប្រក្រតី ។

**ផ្នែក 4 :**

(i) ផ្នែកនេះនៃតារាងសំណួរតាមគ្រួសារស្តីពីស្ថានភាពលំនៅដ្ឋាននិងប្រដាប់ប្រើប្រាស់ក្នុងផ្ទះមិនត្រូវបំពេញចំពោះគ្រួសារស្ថាប័នឡើយ ។ ដូច្នេះ អ្នកត្រូវរក្សាទុកឱ្យផ្នែកនេះស្អាតបំផុត ។

## គ្រួសារស្ថាប័នមានទំហំធំ

128. បើមានគ្រឹះស្ថានណាមួយនៅក្នុងមណ្ឌលជំរឿនរបស់អ្នក មានចំនួនសមាជិកច្រើន ( លើសពី 10 នាក់ ) នៅពេលដើរធ្វើបញ្ជីផ្ទះ អ្នកត្រូវជួបប្រាស្រ័យជាមួយប្រធានគ្រឹះស្ថាននោះ ដោយសុំឱ្យគាត់រៀបចំនិងថែរក្សាបញ្ជីឈ្មោះសមាជិកគ្រួសារស្ថាប័នរបស់គាត់ដែលស្ថិតនៅក្នុងគ្រឹះស្ថាននៅយប់ធ្វើជំរឿន ។

128.1 នៅថ្ងៃទី 3 ខែ មិនា ឆ្នាំ 1998 អ្នកសំភាសន៍ត្រូវចុះទៅកាន់គ្រឹះស្ថានជាថ្មីម្តងទៀតដើម្បីផ្ទៀងផ្ទាត់បញ្ជីសមាជិកគ្រួសារស្ថាប័នដែលបានរៀបចំដោយប្រធានស្ថាប័ន ។ ឈ្មោះសមាជិកដែលមិនបានស្នាក់នៅ នៅយប់ធ្វើជំរឿននៅក្នុងគ្រឹះស្ថាននោះ ត្រូវលុបចេញពីបញ្ជីដែលបានរៀបចំហើយ ឯចំណែកអ្នកដែលមិនមានឈ្មោះក្នុងបញ្ជីរៀបចំមុន តែនៅយប់ធ្វើជំរឿនបែរជាបានមកស្នាក់នៅក្នុងគ្រឹះស្ថាននោះត្រូវរាប់បញ្ចូល ។ អ្នកត្រូវសំភាសន៍ជាមួយមនុស្សគ្រប់រូបដែលមានឈ្មោះក្នុងបញ្ជីដែលទើបតែកែតំរូវថ្មីៗ ។

# ជំពូក V

# ការធ្វើជំរឿនគ្រួសារគ្មានផ្ទះសំបែង

# ប្រជារាស្ត្រនៅតាម ទូក កាណូត កប៉ាល់ ផ្ទះទឹក និង ប្រជារាស្ត្រឆ្លងកាត់

## គ្រួសារគ្មានផ្ទះសំបែង

129. គ្រួសារប្រភេទនេះរាប់បញ្ចូលទាំងអ្នកមិនរស់នៅក្នុងអគារ ឬសំណង់ ( ឧ. អ្នកដែលរស់នៅចិញ្ចើមថ្នល់ ទីក្រោលថ្ម ឬ បេតុង នៅក្នុងទីល្ហល្ហេវ នៅក្រៅទីវត្តអារ៉ាម ឬទីផ្សារ ។ល។ ) ។ គ្រួសារបែបនេះ មាននៅក្នុងមណ្ឌលជំរឿនរបស់អ្នក ត្រូវរាប់នៅពេលជិតអធ្រាតថ្ងៃទី 3 ខែ មិនា ឆ្នាំ 1998 ឧទាហរណ៍ នៅយប់ធ្វើជំរឿននោះ ។ ដើម្បីសំរេចការងារនេះបាន អ្នកត្រូវកត់សំគាល់អំពីទីកន្លែងដែលអាចធ្វើទៅបានដែលតាមពម្មតាគ្រួសារប្រភេទនេះនិយមមកស្នាក់នៅក្នុងមណ្ឌលជំរឿនរបស់អ្នក ។ អ្នកអាចកត់សំគាល់ទីកន្លែងទាំងនេះនៅពេលធ្វើបញ្ជីផ្ទះ ។ យ៉ាងណាក៏ដោយ សូមកត់សំគាល់ថា ប្រជារាស្ត្រប្រភេទនេះរស់នៅតាមទីល្ហល្ហេវ គ្មានអគារ ឬសំណង់ ហេតុនេះពួកគេមិនត្រូវបានចុះក្នុងបញ្ជីផ្ទះទេ (តារាងក ) ។ អ្នកត្រូវកត់សំគាល់ទីតាំងដែលប្រជារាស្ត្រគ្មានផ្ទះសំបែងគេនិយមមកស្នាក់នៅឱ្យបានអស់ ហើយរាប់ពួកគេនៅក្នុងតារាង ខ នៅយប់ធ្វើជំរឿន ។ បើមានជនគ្មានផ្ទះសំបែងច្រើនក្នុងមណ្ឌលជំរឿនរបស់អ្នកនោះ អ្នកមិនអាចរាប់បានអស់ តែម្នាក់ឯងក្នុងមួយយប់ដោយគ្មានជំនួយបានឡើយ ។ អ្នកត្រូវរាយការណ៍ហេតុផលនេះជូនដល់អ្នកត្រួតពិនិត្យរបស់អ្នកជាមុន ដើម្បីសូមជំនួយអ្នកសំភាសន៍បន្ថែមឱ្យជួយអ្នក ដើម្បីធ្វើការរាប់មនុស្សគ្មានផ្ទះសំបែងតែមួយយប់ឱ្យអស់ ។ អ្នកសុំទាន មនុស្សសាត់ព្រាត់គ្មានលំនៅពិតប្រាកដ និងមនុស្សវិកលចរិកដែលរស់នៅដោយគ្មានជំរកត្រូវរាប់ជាប្រជារាស្ត្រ គ្មានផ្ទះសំបែង ហើយមិនត្រូវភ្លេចឡើយ ។

130. សេចក្តីណែនាំសំរាប់បំពេញតារាង ខ តារាងសំណួរតាមគ្រួសារ សំរាប់គ្រួសារគ្មានផ្ទះសំបែងមានផ្តល់ជូនខាងក្រោមនេះ :

### *តារាង ខ តារាងសំណួរតាមគ្រួសារ*

#### *ផ្នែក I*

(i) សូមចុះលេខកូដ 3 នៅក្នុងប្រអប់ខាងក្រោម " ប្រភេទនៃគ្រួសារ / ប្រជារាស្ត្រ " ។

(ii) នៅក្នុងពកីមានសំគាល់ សូមបំពេញត្រង់អគារលេខដោយលេខកូដ ៩៩៩ សំរាប់សំគាល់គ្រួសារគ្មានផ្ទះសំបែង ។ លេខគ្រួសារអាចជា 01,02.....។ល។ សំរាប់គ្រួសារគ្មាន

ផ្ទះសំបែង នៅក្នុងមណ្ឌលជំរឿន ។ ម្យ៉ាងទៀតបើមាន 20 គ្រួសារបែបនេះ នៅក្នុងមណ្ឌលជំរឿន លេខអគារត្រូវសរសេរ ៩៩៩ សំរាប់អគារនីមួយៗ ហើយលេខគ្រួសារជាលេខ 01, 02.....20 ។

(iii) សេចក្តីណែនាំសំរាប់បំពេញពត៌មានផ្សេងៗទៀតក្នុងផ្នែកនីមួយៗគឺត្រូវបំពេញដូចគ្នា និងគ្រួសារធម្មតា លើកលែងតែគ្រួសារគ្មានផ្ទះសំបែងទេដែលនៅក្នុងតារាងសំណួរ 1.1, 1.2 ,1.3 និងតារាងសរុបនានាក្នុងផ្នែក 1 មិនបាច់បំពេញឡើយ ។ ហេតុនេះអ្នកត្រូវទុកផ្នែកនេះ ឱ្យនៅទំនេរស្អាតនៅក្នុងកំរងតារាងសំណួរ ។

***ផ្នែក 2***

ការជំរឿនស្រង់គ្រួសារគ្មានផ្ទះសំបែងក្នុងផ្នែកនេះនៃតារាងសំណួរតាមគ្រួសារ នឹងត្រូវធ្វើតាមវិធីសាស្ត្រដដែល ដូចគ្នានឹងគ្រួសារធម្មតា ឬគ្រួសារប្រក្រតី ។

***ផ្នែក 3***

ការជំរឿនស្រង់ពត៌មានអំពីភាពបង្កើតកូនបានរបស់ស្ត្រីមានអាយុ 15 ឆ្នាំឡើងទៅនៅក្នុងគ្រួសារគ្មានផ្ទះសំបែងក្នុងផ្នែកនេះនៃតារាងសំណួរតាមគ្រួសារ នឹងត្រូវធ្វើតាមវិធីសាស្ត្រដដែល ដូចគ្នានឹងគ្រួសារធម្មតា ឬគ្រួសារប្រក្រតី ។

***ផ្នែក 4***

ផ្នែកស្តីពីស្ថានភាពលំនៅដ្ឋាន និងប្រដាប់ប្រើប្រាស់នៅក្នុងផ្ទះនៃតារាងសំណួរតាមគ្រួសារនោះគ្មានលើកជាបញ្ហាសំរាប់គ្រួសារគ្មានផ្ទះសំបែងឡើយ ។ ហេតុនេះ អ្នកត្រូវរក្សាផ្នែកនេះឱ្យនៅទំនេរស្អាត ។

បើអ្នកបានឃើញក្រុមមនុស្សគ្មានផ្ទះសំបែងស្នាក់នៅក្នុងមណ្ឌលជំរឿនរបស់អ្នកដែលគេទាំងនេះគ្មានជាប់សាច់ឈាមអ្វីជាមួយគ្នា ( ឧ. ក្មេងអនាថា ) អ្នកត្រូវបំពេញលក្ខណៈសំគាល់របស់គេជាបន្តនៅក្នុងតារាង ខ ដដែល ( ដោយចាត់ទុកគេថាជាគ្រួសារគ្មានសមាជិកសាច់ឈាម ) ដោយផ្តើមពីមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនោះ ( សន្មតថា គេហាក់ដូចជាមេគ្រួសារ ) និងកត់ត្រាអ្នកទាំងអស់ផ្សេងទៀតដោយសំគាល់ថាគ្មានជាប់សាច់ញាតិ ( កូដ 7 ) សំរាប់បំពេញក្នុងបង្គោល ៖ ញាតិសន្តាន ។

## ប្រជារាស្ត្រនៅតាមទូក កាណូត កញ៉ាល់ និងផ្ទះទឹក

*131. មនុស្សដែលរស់នៅតាមទូក កាណូត កញ៉ាល់ត្រូវបានចាត់ទុកជាជាមនុស្សរស់នៅតាមទឹក (Boat population) ។* គេទាំងនោះនឹងធ្វើសំភាសន៍នៅពេលយប់ធ្វើជំរឿន ។ មុននឹងធ្វើការសំភាសន៍ ទូក កញ៉ាល់ ដែលបានប្រទះឃើញនៅក្នុងមណ្ឌលជំរឿនមួយនឹងត្រូវបានដាក់លេខដោយខ្សែកជា ៖ ខ្ទង់បួន

តទៅនេះ B001, B002 ....។ល។ អក្សរ B នៅពីមុខលេខវាសំគាល់លេខទូក ឬ កប៉ាល់ ។ លេខទាំងអស់នេះត្រូវ សរសេរឱ្យច្បាស់នៅលើទូក កប៉ាល់ដោយដីស ឬ សរសេរលើក្រដាសបិទ សូមកត់សំគាល់ថាតារាង ក មិនត្រូវបំពេញទេចំពោះទូក កប៉ាល់ ។ ទូក កាណូត កប៉ាល់ នឹងត្រូវបានដាក់លេខដោយឡែកជាលេខ 3 ខ្ទង់ ។ តារាង ខ ដោយឡែកនឹងត្រូវបានបំពេញសំរាប់មនុស្សរស់នៅតាមទូក កាណូត កប៉ាល់ ដោយសន្មត់ថា ទូក កាណូត កប៉ាល់ នីមួយៗនោះជាអគារ ឬ សំណង់ដាច់ដោយឡែក ។ នៅក្នុងការចុះសំគាល់ពីពត៌មានសំគាល់ ដោយឡែកក្នុងផ្នែក ၊ នៃតារាង ខ នោះលេខ ទូក កាណូត កប៉ាល់ នឹងត្រូវសរសេរក្រោមលេខ អគារ ។ ចុះកូដលេខ 4 នៅក្នុងប្រអប់ខាងក្រោម " ប្រភេទគ្រួសារ /ប្រជារាស្ត្រ " ។ សេចក្តីណែនាំសំរាប់សំភាសន៍មនុស្សរស់តាមទឹកនោះមានលក្ខណៈដូចគ្នានឹងការសំភាសន៍ជាមួយគ្រួសារធម្មតាលើកលែងតែៈ (1) តារាងសំណួរ 1.1, 1.2 និង 1.3 ហើយនិងសរុបតារាងសំណួរក្នុងផ្នែក ၊ នៃតារាង ខ នោះពុំចាំបាច់បំពេញ ។ (2) : ផ្នែក 4 តារាង ខ ក៏ពុំចាំបាច់បំពេញដែរ ។

## ប្រជារាស្ត្រឆ្លងកាត់

132. ប្រជារាស្ត្រក្នុងប្រភេទនេះរួមមានដូចតទៅ : (i) នៅពេលយប់ថ្ងៃធ្វើជំរឿន មនុស្សនៅព្រលានយន្តហោះ មនុស្សនៅចំណតអាយស្ម័យយាន មនុស្សនៅចំណតរថយន្ត មនុស្សនៅកំពង់ផែ កំពង់ចំលង មនុស្សនៅតាមរទេះ ( កំពុងធ្វើដំណើរ ) (ii) : ជនពនាចរដែលបានបោះជំរុំនៅក្នុងភូមិនៅយប់ធ្វើជំរឿន (iii) : មនុស្សដែលនៅយប់ធ្វើជំរឿនបានស្ថិតនៅលើនាវានៅក្នុងដែនទឹកនៃដែនដីកម្ពុជា ហើយនិង (iv) : មនុស្សដែលនៅយប់ធ្វើជំរឿនបានស្ថិតនៅប៉ុស្តិ៍ព្រំប្រទល់អន្តរជាតិ ។ ការធ្វើសំភាសន៍ជាមួយប្រជារាស្ត្រឆ្លងកាត់នឹងត្រូវធ្វើនៅក្នុងតារាង ខ នៅតាមការណែនាំដូចគ្នានឹងគ្រួសារគ្មានទីលំនៅ ។ តែយ៉ាងណាក៏ដោយត្រូវកត់សំគាល់ថា សំរាប់ករណីប្រជារាស្ត្រឆ្លងកាត់នោះ អ្នកត្រូវចុះលេខកូដ 5 នៅក្នុងប្រអប់ខាងក្រោម " ប្រភេទគ្រួសារ / ប្រជារាស្ត្រ " នៅក្នុងផ្នែក ၊ ។ អ្នកត្រូវសរសេរឈ្មោះទីតាំងនៅលើបន្ទាត់ចុចៗលើប្រអប់នូវទីកន្លែងដែលយើងជួបប្រទះមនុស្សនោះស្នាក់នៅ ( ឧៈ ស្ថានីយ៍រថភ្លើងនៅភ្នំពេញ,កប៉ាល់ឈ្មោះសូរិយានៅកំពង់ផែ ) ការសំរបសំរួលជាពិសេសនឹងត្រូវបានធ្វើឡើងសំរាប់សំភាសន៍ជាមួយប្រជារាស្ត្រឆ្លងកាត់នៅយប់ថ្ងៃធ្វើជំរឿន ។

# ជំពូក VI

# ការរៀបចំតារាងសរុបសង្ខេបរបស់អ្នកសំភាសន៍ ( ធ្វើតាមគ្រួសារ)

133. ក្រោយពីបានបំពេញការរាប់តាមគ្រួសារចប់សព្វគ្រប់ អ្នកត្រូវបំពេញក្នុងតារាង 2 ឈ្មោះថា តារាងសរុបសង្ខេបរបស់អ្នកសំភាសន៍ ( មើលឧបសម្ព័ន្ធ " ឆ " ) ។ អ្នកត្រូវបំពេញដោយប្រុងប្រយត្ន័អំពីពត៌មានសំគាល់ ។ តួលេខដែលអ្នកផ្តល់ក្នុងតារាងសរុបសង្ខេបនេះគេនិងប្រើសំរាប់ការចងក្រងលទ្ធផលជាបណ្តោះអាសន្ន ។ ហេតុដូច្នេះអ្នកពុំគួរមានការភាន់ច្រឡំ ឬបង្កកំហុសថែមក្នុងការបំពេញតារាងនោះឡើយ ។ គេបានផ្តល់ 30 បន្ទាត់ក្នុងតារាងសរុបសង្ខេបរបស់អ្នកសំភាសន៍ ។ អ្នកអាចទាញយកពត៌មានដែលត្រូវការពីគ្រួសារនីមួយៗចេញពីបង្គោលដែលពាក់ព័ន្ធក្នុងតារាង "ខ " ផ្នែក 2 និងកត់ត្រាឱ្យបានត្រឹមត្រូវនៅក្នុងតារាងនេះ ។ ចំនួនកំរងតារាងត្រូវការ គឺអាស្រ័យទៅនឹងចំនួនគ្រួសារនៅក្នុងមណ្ឌលជំរឿន ។ សូមចុះលេខទំព័រខាងលើ ខាងស្តាំដៃនៃតារាងនីមួយៗដែលបានប្រើ ។ បន្ទាត់នីមួយៗក្នុងតារាងនេះត្រូវប្រើសំរាប់តែមួយគ្រួសារ ។ បន្ទាត់ចុងក្រោយបង្អស់ទុកសំរាប់ដាក់លេខសរុបតាមបង្គោលនីមួយៗ ។ នៅក្នុងបង្គោល 3 អ្នកត្រូវរាប់ចំនួនគ្រួសារ ហើយចុះចំនួននោះក្នុងបង្គោលសរុប ។ នៅទំព័រនីមួយៗសរុបសំរាប់ទំព័រនីមួយៗ នោះត្រូវបានផ្តល់ជូន ។ សរុបរួមសំរាប់មណ្ឌលជំរឿនទាំងអស់ដែលត្រូវដាក់លេខមាននៅក្នុងបន្ទាត់ចុងក្រោយ ។ វិធីសាស្ត្របំពេញបង្គោល 2 ដល់ 8 នៃតារាងសរុបសង្ខេបរបស់អ្នកសំភាសន៍ ត្រូវបានណែនាំដូចខាងក្រោមនេះ ។

## បង្គោល 2 និង 3 : អគារលេខ និងគ្រួសារលេខ

134. នៅក្នុងបង្គោលទាំងពីរនេះ សូមចំលងអគារលេខ និងគ្រួសារលេខនៃគ្រួសារនីមួយៗពីពត៌មានសំគាល់ ដែលផ្តល់ជូននៅដើមទំព័រនៃតារាងខផ្នែក 1 បំពេញស្រាប់សំរាប់គ្រួសារ ។

## បង្គោល 4 : ចំនួនតារាងសំណួរសំរាប់គ្រួសារដែលបានប្រើប្រាស់

135. អ្នកត្រូវសរសេរនៅទីនេះនូវចំនួនតារាង "ខ "ដែលបានប្រើសំរាប់គ្រួសារ ។ អ្នកត្រូវកត់ត្រាចំនួននេះចូលទៅក្នុងប្រអប់នៅខាងក្រោមទំព័រឆ្វេងដៃនៃទំព័រទី 1 នៃតារាងទី 1 "ខ " ដែលបានប្រើប្រាស់សំរាប់គ្រួសារ ។

**បង្គោល 5 ដល់ 7 ៖ ចំនួនប្រជារាស្ត្របានពីជំរឿន**

136. អ្នកត្រូវរាប់ចំនួនមនុស្សប្រុស ( លេខកូដ 1 ) ពីបង្គោល 4 នៃតារាង "ខ" ផ្នែក 2 រួចកត់ត្រាចំនួននោះនៅក្នុងបង្គោល 5 នៃតារាងនេះ ។ សូមរាប់ចំនួនមនុស្សស្រី ( លេខកូដ 2 ) ពីបង្គោល 4 នៃតារាង (ខ) ផ្នែក 2 រួចកត់ចំនួននោះនៅក្នុងបង្គោល 6 នៃតារាងនេះ ។ សូមបូកបង្គោល 5 និងបង្គោល 6 រួចកត់ចំនួនមនុស្សសរុបចូលក្នុងបង្គោល 7 ។ សូមពិនិត្យចំនួនសរុបនេះ ជាមួយនឹងលេខរៀងចុងក្រោយនៅក្នុងបង្គោល 1 នៃតារាង ខ ផ្នែក 2 ។ *សូមកុំកត់ចម្លងកូលេខប្រជារាស្ត្រពីតារាងសរុបសង្ខេបបញ្ជីផ្ទះ ។ អ្វីដែលអ្នកត្រូវការនៅពេលនេះគឺចំនួនប្រជារាស្ត្រដែលជំរឿនបាន មិនមែនចំនួនប្រជារាស្ត្រនៃបញ្ជីផ្ទះទេ ។*

**បង្គោល 8 ៖ ប្រភេទគ្រួសារ / ប្រជារាស្ត្រ**

137. ចំពោះគ្រួសារនីមួយៗ អ្នកត្រូវបញ្ជាក់ប្រាប់នៅក្នុងបង្គោលនេះនូវប្រភេទរបស់គ្រួសារនោះ ។ សូមចុះលេខកូដ 1 សំរាប់គ្រួសារធម្មតា ឬ គ្រួសារប្រក្រតី លេខកូដ 2 សំរាប់គ្រួសារស្ថាប័ន លេខកូដ 3 សំរាប់គ្រួសារគ្មានផ្ទះសំបែង លេខកូដ 4 សំរាប់ប្រជារាស្ត្ររស់នៅតាមទឹក និងលេខកូដ 5 សំរាប់ប្រជារាស្ត្រឆ្លងកាត់ ។

**បង្គោល 9 ៖ សេចក្តីផ្សេងៗ**

138. នៅក្នុងបង្គោលសេចក្តីផ្សេងៗ អ្នកត្រូវចុះពត៌មានដែលមានសារៈប្រយោជន៍នៅតាមមូលដ្ឋានដែលអ្នកបានសង្កេតឃើញ ។

**ឯកសារត្រូវប្រគល់ដល់អ្នកត្រួតពិនិត្យ**

139. នៅពេលបញ្ចប់ការធ្វើសំភាសន៍ អ្នកត្រូវធ្វើការរាប់នូវតារាងសំណួរដែលបានទទួលក្នុងតារាង 3 ក្នុងឧបសម្ព័ន " ឈ " ។ អ្នកត្រូវទទួលការបញ្ជាក់ពីប្រធានភូមិដែលពាក់ព័ន្ធក្នុងតារាង 4 ក្នុងឧបសម្ព័ន្ធ " ញ " អំពីចំនួនគ្រួសារដែលអ្នកបានធ្វើការសំភាសន៍បានបំពេញចប់សព្វគ្រប់ ។ បន្ទាប់មកអ្នកត្រូវពិនិត្យដោយយកចិត្តទុកដាក់ក្នុងការកត់ចូល និងសរុបក្នុងតារាងសំណួរនិងតារាងសរុបសង្ខេបដូចបានរៀបរាប់ក្នុងសេចក្តីណែនាំ អ្នកត្រូវតែប្រគល់ជូនវិញនូវសំភារៈទាំងឡាយដែលដាក់ក្នុងសឺមីដល់មន្ត្រីត្រួតពិនិត្យនិងធ្វើបញ្ជីរាយមុខសំភារៈ ។

ក. តារាងសំណួរទាំងអស់ ពោលគឺតារាង ក និងតារាង ខ ដោយរៀបទុកដោយឡែកៗពីគ្នានូវតារាងបំពេញហើយ តារាងឆូតចោល និងតារាងមិនបានប្រើប្រាស់ ។ កត់សំគាល់ថាចំនួនសរុបដែលបានប្រគល់ជូនវិញ ត្រូវតែស្មើនឹងចំនួនសរុបដែលបានទទួលដោយអ្នក ។

ខ. តារាង 1 តារាងសរុបសង្ខេបបញ្ជីផ្ទះបំពេញបានចប់

គ. តារាង 2 តារាងសរុបសង្ខេបរបស់មន្ត្រីសំភាសន៍បំពេញហើយ

ឃ. តារាង 3 បញ្ជីទទួលនិងការប្រើប្រាស់តារាងដោយមន្ត្រីសំភាសន៍

ង. តារាង 4 លិខិតបញ្ជាក់ពីប្រធានភូមិ បំពេញហើយ

ច. ផែនទីមណ្ឌលជំរឿន

ឆ. សេចក្តីណែនាំរបស់មន្ត្រីសំភាសន៍

ប្រសិនបើ អ្នកអនុវត្តតាមការណែនាំដែលបានចែងនៅក្នុងអត្ថបទណែនាំមកនេះដោយប្រុងប្រយត្ន័នោះ អ្នកនឹងមានមោទនភាពថាបានបំពេញភារកិច្ចជូនជាតិមួយបានយ៉ាងល្អប្រសើរ ។ ក្នុងឧបសម្ព័ន្ធ ៨ អ្នកនឹងឃើញនូវឧទាហរណ៍ក្នុងការកត់ចូលក្នុងតារាង ក បញ្ជីផ្ទះ តារាង ខ តារាងសំណួរតាមគ្រួសារ តារាង 1 សរុបសង្ខេបបញ្ជីផ្ទះ តារាង 2 តារាងសរុបសង្ខេបរបស់មន្ត្រីសំភាសន៍ និងតារាង 3 បញ្ជីទទួលនិងការប្រើប្រាស់តារាងសំណួរដែលបានទទួល ។

# ឧបសម្ព័ន្ធ

តារាង ក បញ្ជី

# រាជរដ្ឋាភិបាលកម្ពុជា

## ជំរឿនទូទៅនៃប្រជាជនកម្ពុជា ខែ មីនា ឆ្នាំ ១៩៩៨

តំបន់ជំរឿន

ទីតាំងសំគាល់

ទំព័រលេខ........
ចំនួនទំព័រសរុបសំរាប់មណ្ឌលជំរឿន..........

| | ខេត្ត / ក្រុង | ស្រុក / ខណ្ឌ | ឃុំ / សង្កាត់ | ភូមិ / មណ្ឌល | មណ្ឌលជំរឿនលេខ. |
|---|---|---|---|---|---|
| ឈ្មោះ | | | | | |
| លេខកូដ | | | | | |

បញ្ជីអគារ / សំណង់ និងគ្រួសារ

| ល.រ | អគារ / សំណង់ លេខ | សំភារៈសំខាន់ក្នុងការសាងសង់ អគារ / សំណង់ៈ ជញ្ជាំង | ដំបូល | កំរាល | គោលបំណងនៃការប្រើប្រាស់ អគារ / សំណង់ 1: សំរាប់នៅ 2: សំរាប់នៅ & អាជីវកម្មផ្សេងៗ 3: សំរាប់នៅ & រោងជាង 4: សំរាប់នៅ & គ្រឹះស្ថានណា មួយផ្សេងទៀត (បញ្ជាក់) (គូសរង្វង់) | គ្រួសារលេខ | ករណីមានអ្នកដឹកនាំគ្រួសារ: នាមត្រកូលនិងនាមខ្លួន | ភេទ 1: ប្រុស 2: ស្រី (គូសរង្វង់) | ចំនួនមនុស្សដែលរស់នៅជាប្រចាំក្នុងគ្រួសារ: ប្រុស | ស្រី | ចំនួន មនុស្ស | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 | 13 |
| 1 | | | | | | | | | | | | |
| 2 | | | | | | | | | | | | |
| 3 | | | | | | | | | | | | |
| 4 | | | | | | | | | | | | |
| 5 | | | | | | | | | | | | |
| 6 | | | | | | | | | | | | |
| 7 | | | | | | | | | | | | |
| 8 | | | | | | | | | | | | |
| 9 | | | | | | | | | | | | |
| 10 | | | | | | | | | | | | |
| | | | | | (*រាប់ចំនួនដែលកត់ត្រូវនិងគេចំនួនសរុប) **សរុប | | | សរុប | | | |

លេខកូដសំគាល់លេខកូដ

| សំភារៈធ្វើជញ្ជាំង (ជួរឈរ 3) | សំភារៈធ្វើដំបូល (ជួរឈរ 4) | សំភារៈកំរាល (ជួរឈរ 5) |
|---|---|---|
| 1. ឬស្សី / ស្លឹក ស្បូវ / ស្មៅ / ព្រៃង ប្រហុស | 1. ឬស្សី / ស្លឹក ស្បូវ / ស្មៅ | 1 ដី / ដីឥដ្ឋ |
| 2. | 2. ក្បឿង | 2 ក្តារឈើ / សោឬស្សី |
| 3. ក្តារឈើ / ក្តារបន្ទះ | 3. ក្តារឈើ / ក្តារបន្ទះ | 3 បេតុង / ឥដ្ឋ / ថ្ម |
| 4. បេតុង / ឥដ្ឋ / ថ្ម | 4 បេតុង / ឥដ្ឋ / ថ្ម | 4 ថ្មរ |
| 5. ស័ង្កសី / អាល្លុយមីញ៉ូម / បន្ទះលោហៈធាតុផ្សេងៗ | 5. ស័ង្កសី / អាល្លុយមីញ៉ូម / បន្ទះលោហៈធាតុផ្សេងៗ | 5 ក្តារ / ក្តារនេត |
| 6. ហ្វ៊ីប្រូស៊ីម៉ង់ត៍ | 6. ហ្វ៊ីប្រូស៊ីម៉ង់ត៍ | 6 ឥដ្ឋក្បាច់ / ឥដ្ឋការ៉ូ |
| 7. សំភារៈប្រើប្រាស់ហើយ / ធុងស បង្គុម ថង់ជ័រ | 7 បន្ទះចម្រុះ / បន្ទះជ័រ | 7 ផ្សេងទៀត (សូមបញ្ជាក់) |
| 8. ផ្សេងទៀត (សូមបញ្ជាក់) | 8 ផ្សេងទៀត (សូមបញ្ជាក់) | |

ឈ្មោះអ្នកជំរឿនសំភាសន៍ ............................................

________________ ហត្ថលេខា ____/____/____ ថ្ងៃ ខែ ឆ្នាំ

ឈ្មោះអ្នកត្រួតពិនិត្យ ............................................

________________ ហត្ថលេខា ____/____/____ ថ្ងៃ ខែ ឆ្នាំ

| ឈ្មោះ | ភ្នំពេញ | | ដង្កោ | | ព្រៃសរ | | អន្លង់គង | | | |
|---|---|---|---|---|---|---|---|---|---|---|
| លេខកូដ | 1 | 2 | 0 | 5 | 1 | 0 | 0 | 6 | 0 | 1 |

ផែនទីមណ្ឌលជំរឿនភូមិ (ទីជនបទ) មិនទាន់កែលំអ

សញ្ញាផែនទី



# ការពិពណ៌នាពីមណ្ឌលជំរឿន

| ចំណុចចេញដំណើរ | របៀបឆ្ពោះទៅរក | ចំណុចទៅដល់ |
|---|---|---|
| ភ្នំ (ទិសពាយ័ព្យ) | ឆ្ពោះទៅទិសខាងកើតរហូតដល់ចំការចេកក្បែរដងទន្លេ | ចំការចេក |
| ចំការចេក | តាមដងទន្លេចុះទៅទិសនិរតីរហូតដល់ត្រពាំងទឹក | ត្រពាំង |
| ត្រពាំង | ឆ្ពោះទៅទិសខាងជើង រហូតដល់ភ្នំ | ភ្នំ |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

| | ខេត្ត / ក្រុង | | ស្រុក / ខណ្ឌ | | ឃុំ / សង្កាត់ | | ភូមិ / មណ្ឌល | | មណ្ឌលជំរឿនលេខ | |
|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះ | ភ្នំពេញ | | ចំការមន | | ទួលស្វាយព្រៃ២ | | ភូមិ១០ | | | |
| លេខកូដ | 1 | 2 | 0 | 1 | 0 | 7 | [illegible] | 0 | 1 | 9 |

ផែនទីមណ្ឌលជំរឿនតូច ( មិនប្រើប៉ុន្មាន ) មិនទាន់កែលំអ

## សញ្ញាផែនទី

- ព្រំប្រទល់ភូមិ
- ព្រំប្រទល់មណ្ឌលជំរឿន
- ទីតាំងលំនៅដ្ឋាន — R
- ផ្លូវធំ
- ផ្លូវរទេះ
- ផ្លូវដែក
- ស្ពាន, ព្រែកទឹក — Canal
- ទន្លេ បឹង / ត្រពាំង
- ភ្នំ / ដំបូក
- ព្រៃឈើ
- វាលស្រែ
- វត្តអារាម
- មន្ទីរពេទ្យ
- សាលារៀន

ចំណាំ:

១. សូមសរសេរឈ្មោះផ្លូវធំ ផ្លូវ ទន្លេ ស្ទឹង ។ល។
២. សូមសរសេរឈ្មោះភូមិជិតខាងនៅលើផែនទី
៣. សូមបញ្ជាក់ទិសខាងជើង N

សូមសរសេរពណ៌នាព្រំមណ្ឌលជំរឿន

សូមមើលទំព័រខាងក្រោយ

ឈ្មោះភ្នាក់ងារជំរឿន:......................

ហត្ថលេខា:......................

ឈ្មោះអ្នកត្រួតពិនិត្យ:......................

ហត្ថលេខា:......................




ផែនទី ១ (ក)

## ការពិពណ៌នាពីមណ្ឌលជំរឿន

| ចំណុចចេញដំណើរ | វិធីឆ្ពោះទៅរក | ចំណុចទៅដល់ |
|---|---|---|
| ផ្ទះ សុខ បូរិទ្ធ (ពាយ័ព្យ ) | ឆ្ពោះទៅទិសខាងកើតទៅផ្លូវលេខ 286 | ហាងលក់គេសផ្ទះ |
| ហាងលក់គេសផ្ទះ | ឆ្ពោះទៅទិសខាងត្បូងរហូតដល់ផ្សារនៅផ្លូវលេខ 205 | ផ្សារ |
| ផ្សារ | ឆ្ពោះទៅទិសខាងលិចរហូតដល់ការិយាល័យ NGO នៅផ្លូវលេខ 318 | ការិយាល័យ NGO |
| ការិយាល័យ NGO | ឆ្ពោះមកទិសខាងជើងរហូតដល់ផ្ទះ សុខ បូរិទ្ធ នៅមហាវិថី សម្តេចប៉ុក្តីរ៉ែក | ផ្ទះ សុខ បូរិទ្ធ |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

| | ខេត្ត / ក្រុង | | ស្រុក / ខណ្ឌ | | ឃុំ / សង្កាត់ | | ភូមិ / មណ្ឌល | | មណ្ឌលជំរឿនលេខ | |
|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះ | ភ្នំពេញ | | ដង្កោ | | ព្រៃសរ | | | | | |
| លេខកូដ | 1 | 2 | 0 | 5 | 1 | 0 | 0 | 6 | 0 | 1 |



# ការពិពណ៌នាពីចណ្ដូលជំរឿន

| ចំណុចចេញដំណើរ | ផ្លូវឆ្ពោះទៅរក | ចំណុចទៅដល់ |
|---|---|---|
| ភ្នំ (ទិសពាយ័ព្យ) | ឆ្ពោះទៅទិសខាងកើតរហូតដល់ចំការចេកក្បែរដងទន្លេ | ចំការចេក |
| ចំការចេក | តាមដងទន្លេចុះទៅទិសនិរតីរហូតដល់ត្រពាំងទឹក | ត្រពាំង |
| ត្រពាំង | ឆ្ពោះទៅទិសខាងជើង រហូតដល់ភ្នំ | ភ្នំ |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

| | ខេត្ត / ក្រុង | | ស្រុក / ខណ្ឌ | | ឃុំ / សង្កាត់ | | ភូមិ / មណ្ឌល | | មណ្ឌលជំរឿនលេខ | |
|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះ | ភ្នំពេញ | | ចំការមន | | [illegible] | | ភូមិ១០ | | [illegible] | |
| លេខកូដ | 1 | 2 | 0 | | [illegible] | | 1 | 0 | 1 | 9 |

ផែនទីមណ្ឌលជំរឿនគំរូ ( ទិន្នន័យ ) បន្ទាប់ពីការកែលំអ

## សញ្ញាផែនទី



# ការពិពណ៌នាពីមណ្ឌលជំរឿន

| ចំណុចចេញដំណើរ | ដើរឆ្ពោះទៅរក | ចំណុចទៅដល់ |
|---|---|---|
| ផ្ទះ សុខ បូរិទ្ធ (ពាយ័ព្យ ) | ឆ្ពោះទៅទិសខាងកើតតាមផ្លូវលេខ 286 | ហាងលក់ភេសជ្ជៈ |
| ហាងលក់ភេសជ្ជៈ | ឆ្ពោះទៅទិសខាងត្បូងរហូតដល់ផ្សារតាមផ្លូវលេខ 205 | ផ្សារ |
| ផ្សារ | ឆ្ពោះទៅទិសខាងលិចរហូតដល់ការិយាល័យ NGO តាមផ្លូវលេខ 318 | ការិយាល័យ NGO |
| ការិយាល័យ NGO | ឆ្ពោះមកទិសខាងជើងរហូតដល់ផ្ទះ សុខ បូរិទ្ធ តាមមហាវិថី សម្តេចមុន្នីរ៉េត | ផ្ទះ សុក បូរិទ្ធ |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

## ជំរឿនទូទៅនូវប្រជារាស្ត្រនៃប្រទេសកម្ពុជា ខែមីនា ឆ្នាំ ១៩៩៨

### តារាងសរុបសង្ខេបបញ្ជីផ្ទះ ( ធ្វើតាមទំព័រ )

ពត៌មានសំគាល់

តារាង 1:

| | ខេត្ត / ក្រុង | | ស្រុក / ខណ្ឌ | |
|---|---|---|---|---|
| ឈ្មោះ | | | | |
| លេខកូដ | | | | |

| | ឃុំ / សង្កាត់ | | ភូមិ / មណ្ឌល | | មណ្ឌលជំរឿនលេខ | |
|---|---|---|---|---|---|---|
| ឈ្មោះ | | | | | | |
| លេខកូដ | | | | | | |

| លេខទំព័រនៃតារាង ក បញ្ជីផ្ទះ | ចំនួនគ្រួសារ | ចំនួនមនុស្សពិតប្រាកដដែលរស់នៅក្នុងគ្រួសារ | | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | |
| 1 | 2 | 3 | 4 | 5 | 6 |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| សរុប | | | | | |

ឈ្មោះអ្នកសំភាសន៍

ហត្ថលេខា

ថ្ងៃខែឆ្នាំ

ឈ្មោះអ្នកត្រួតពិនិត្យ

ហត្ថលេខា

ថ្ងៃខែឆ្នាំ

# បែបបទកែតម្រូវតារាង ក ក្នុងកំឡុងពេលកំពុងធ្វើជំរឿន នៅពេលអ្នកជួបប្រទះ និង គ្រួសារថ្មីមួយចំនួនដែលមិនទាន់បានកត់ចូលក្នុងតារាង ក

ដំបូងអ្នកត្រូវដឹងប្រាកដថា គ្រួសារទាំងនេះបានស្នាក់នៅទីនោះនៅយប់ធ្វើជំរឿន។បើសិនមានគ្រួសារទាំងនេះស្នាក់នៅចំពេលយប់ធ្វើជំរឿនមែន អ្នកត្រូវសំភាសន៍មនុស្សនានានៅក្នុងគ្រួសារទាំងនេះតាមបែបបទដែលបានដាក់ចុះ ។ នៅក្នុងពេលជាមួយគ្នានេះដែរ អ្នកត្រូវកែតម្រូវតារាង ក តាមបែបបទដូចតទៅ :

(i) ***គ្រួសារថ្មី ឬ គ្រួសារជួបប្រទះនៅក្នុងអគារមួយដែលបានចុះបញ្ជីក្នុងតារាង ក រួចហើយ***

ឧបមាថា លេខរៀងបន្ទាត់ និងលេខរៀងអគារ ( បង្គោល 1 និង 2 ) នៃអគារនេះមាន លេខ 6 និងលេខ 004 ហើយមានគ្រួសារមួយកត់ចូលជាមួយអគារនេះរួចជាស្រេច ម្យ៉ាងទៀតឧបមាថា លេខរៀងបន្ទាត់ចុងក្រោយរបស់ EA មានលេខ 110 និង 103 អ្នកត្រូវចុះលេខគ្រួសារថ្មីជាគ្រួសារទី (2) ហើយកត់លេខរៀងបន្ទាត់ជាលេខ 111 នៃតារាង ក ដូចបានបង្ហាញបញ្ជាក់ក្នុងឧទាហរណ៍ I (មើលទំព័របន្ទាប់)។
សូមអនុវត្តតាមបែបបទដដែល បើសិនមានគ្រួសារថ្មីច្រើនជាងមួយគ្រួសារនៅក្នុងអគារនេះដោយមានការខុសប្លែកតែត្រង់លេខគ្រួសារជាលេខ (3), (4) ។ល។ ក្នុងបង្គោល 7 ។
សូមកត់សំគាល់ថា គេពន្យល់យ៉ាងពិស្តារតែពត៌មាននៅក្នុងបង្គោល 8 ដល់ 12 តែប៉ុណ្ណោះ ។

(ii) ***គ្រួសារថ្មី ឬ គ្រួសារជួបប្រទះនៅក្នុងអគារមួយដែលមិនទាន់បានចុះបញ្ជីក្នុងតារាង ក***

ឧបមាថា លេខរៀងបន្ទាត់ 91 និងលេខរៀងអគារ 089 ដែលបានកត់ក្នុងតារាង ក នៃមណ្ឌលជំរឿន EA។ អ្នកអាចចុះលេខអគារថ្មី ជាលេខរៀង 090 ដោយមិនចាំបាច់គិតគូរពីទីតាំងនៃអគារនោះ ហើយចុះនៅទីបញ្ចប់នៃតារាង ក ដូចបានបង្ហាញបញ្ជាក់ក្នុងឧទាហរណ៍ II (មើលទំព័របន្ទាប់ )។ សូមអនុវត្តតាមបែបបទដដែល បើសិនមានអគារថ្មីច្រើនជាងមួយអគារ ។ អ្នកអាចប្រើតារាង ក បន្ថែម បើសិនចាំបាច់ ។
សូមកត់សំគាល់ថា គេពន្យល់យ៉ាងពិស្តារតែពត៌មាននៅក្នុងបង្គោល 3 ដល់ 12 តែប៉ុណ្ណោះ ។

ឧទាហរណ៍ I

| លេខបន្ទាត់ | អគារ/សំណង់ លេខ | | | សំភារៈសំខាន់ក្នុងការសាងសង់ អគារ/សំណង់* | | | គោលដៅក្នុងការប្រើប្រាស់ អគារ / សំណង់<br>1: លំនៅដ្ឋាន<br>2: លំនៅដ្ឋាន & ហាងលក់ទំនិញ<br>3: លំនៅដ្ឋាន & រោងជាង<br>4: លំនៅដ្ឋាន & គ្រឹះស្ថានណាមួយផ្សេងទៀត (បញ្ជាក់)<br>(ចុះលេខកូដ) | គ្រួសារលេខ. | | ពត៌មានអំពីលក្ខណៈនៃមេគ្រួសារ | | ចំនួនមនុស្សដែលរស់នៅជាប្រចាំក្នុងគ្រួសារ. | | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ជញ្ជាំង | ដំបូល | កំរាល | | | | នាមត្រកូលនិងនាមខ្លួន | ភេទ<br>1: ប្រុស<br>2: ស្រី<br>(ចុះលេខកូដ) | ប្រុស | ស្រី | ចំនួនមនុស្ស | |
| 1 | 2 | | | 3 | 4 | 5 | 6 | 7 | | 8 | 9 | 10 | 11 | 12 | 13 |
| 110 | 1 | 0 | 3 | 4 | 5 | 3 | 1 | 0 | 1 | ទៀវ សារី | 1 | 2 | 2 | 4 | |
| | | | | | | | | | | | | | | | |
| | | | | | | | ចុះគ្រួសារបន្ថែមដែលបានកត់សំគាល់ក្នុងពេលធ្វើការសំភាសន៍ | | | | | | | | |
| | | | | | | | | | | | | | | | |
| 111 | 0 | 0 | 4 | - | - | - | - | 0 | 2 | ហុក ណារិន | 1 | 3 | 2 | 5 | គ្រួសារដែលពុំមានរាប់បញ្ចូលក្នុងបញ្ជីផ្ទះ |
| | | | | | | | | | | | | | | | សូមមើលក្នុងបន្ទាត់ទី .... |
| | | | | | | | | | | | | | | | |

ឧទាហរណ៍ II

| លេខបន្ទាត់ | អគារ/សំណង់ លេខ | | | សំភារៈសំខាន់ក្នុងការសាងសង់ អគារ/សំណង់* | | | គោលដៅក្នុងការប្រើប្រាស់ អគារ / សំណង់<br>1: លំនៅដ្ឋាន<br>2: លំនៅដ្ឋាន & ហាងលក់ទំនិញ<br>3: លំនៅដ្ឋាន & រោងជាង<br>4: លំនៅដ្ឋាន & គ្រឹះស្ថានណាមួយផ្សេងទៀត (បញ្ជាក់)<br>(ចុះលេខកូដ) | គ្រួសារលេខ. | | ពត៌មានអំពីលក្ខណៈនៃមេគ្រួសារ | | ចំនួនមនុស្សដែលរស់នៅជាប្រចាំក្នុងគ្រួសារ. | | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
